ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការទប់ស្កាត់ និគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក
# ខេត្តបន្ទាយមានជ័យ
# ឆ្នាំ២០២២ - ២០២៦



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក
# ខេត្តបន្ទាយមានជ័យ
# ឆ្នាំ២០២២ - ២០២៦

**រដ្ឋបាលជលផល និងរដ្ឋបាលខេត្តបន្ទាយមានជ័យ**

# អារម្ភកថា

ព្រះរាជាណាចក្រកម្ពុជាសម្បូរធនធានធម្មជាតិយ៉ាងស្ដុកស្ដម្ភ ជាពិសេសបឹងទន្លេសាប មានធនធានជលផលជាច្រើនប្រភេទ ដូចជា មច្ឆជាតិ ថនិកសត្វ ល្មូន បក្សីទឹក រុក្ខជាតិ និងព្រៃលិចទឹក ក្នុងការទ្រទ្រង់ជីវៈចម្រុះ និងជីវភាពរស់នៅរបស់មនុស្សជាតិ ដែលចាំបាច់ត្រូវគ្រប់គ្រង និងការពារ ដើម្បីរក្សាតុល្យភាពរវាងការប្រើប្រាស់ និងការអភិរក្សប្រកបដោយចីរភាព។ ធនធានជលផលក្នុងបឹងទន្លេសាប មិនត្រឹមតែមានតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់សាច់ត្រីជារៀងរាល់ថ្ងៃដល់ប្រជាពលរដ្ឋកម្ពុជាប៉ុណ្ណោះទេ ថែមទាំងការពារ និងរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីនៃបឹងទន្លេសាប ព្រមទាំងផ្ដល់សេវាកម្មផ្នែកទេសចរណ៍ដ៏ល្អប្រសើរផងដែរ។

ជានិច្ចកាល រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការ និងរៀបចំគោលនយោបាយសំខាន់ៗជាច្រើនទាក់ទងនឹងការការពារ ការអភិរក្ស និងការគ្រប់គ្រងធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីជលផលប្រកបដោយចីរភាព ដែលជាទីពំនាក់អាស្រ័យរបស់ប្រជាពលរដ្ឋកម្ពុជាជាច្រើនរយពាន់គ្រួសារ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅក្នុង និងជុំវិញតំបន់បឹងទន្លេសាប ក្នុងការប្រកបរបរចិញ្ចឹមជិវិត ការធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

នៅក្រោមសសរស្ដម្ភទី១ស្ដីពី **“ ការនេសាទ និងការគ្រប់គ្រង”** នៃក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រជលផលសម្រាប់ឆ្នាំ២០១៥-២០២៤ គឺត្រូវសម្រេចឱ្យបាននូវចក្ខុវិស័យ **“ ធនធានជលផល និងប្រព័ន្ធអេកូឡូស៊ីដែលបានខូចខាត ត្រូវបានស្ដារ អភិរក្ស និងការពារ ដើម្បីចូលរួមធានានូវសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងអនាគត”** ។

ខេត្តបន្ទាយមានជ័យមានវិសាលភាពមួយផ្នែក ស្ថិតនៅក្នុងតំបន់ទំនាបនៃបឹងទន្លេសាប មានសក្ដានុពលខ្ពស់ក្នុងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈផលនេសាទ ផលិតកម្មកសិកម្ម និងការអភិវឌ្ឍអេកូទេសចរណ៍ ប៉ុន្តែធនធានទាំងនេះកំពុងទទួលរងនូវការគំរាមកំហែង ជាពិសេស ភ្លើងឆេះព្រៃលិចទឹក កើតមានជារៀងរាល់ឆ្នាំ ដែលបានបង្កឱ្យបាត់បង់ទីជម្រកមច្ឆជាតិ ប៉ះពាល់ដល់ផលស្ដុកធនធានជលផល បរិស្ថាន និងសង្គម។ អាស្រ័យហេតុនេះ ទើបរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយអង្គការ FAO ក្រោមកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ) ដោយមានការចូលរួមពីរដ្ឋបាល ថ្នាក់ក្រោមជាតិ និងសមត្ថកិច្ចពាក់ព័ន្ធ រៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក រយៈពេល៥ឆ្នាំ នេះ។

តាងនាមរដ្ឋបាលជលផល ខ្ញុំសូមគាំទ្រទាំងស្រុងចំពោះការរៀបចំ និងដាក់ឱ្យអនុវត្តផែនការគ្រប់គ្រងដ៏មានសារៈសំខាន់នេះ ដើម្បីធានាបាននូវការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងការស្ដារព្រៃលិចទឹកឡើងវិញប្រកបដោយប្រសិទ្ធភាពសម្រាប់ជាប្រយោជន៍ដល់ការអភិរក្សធនធានជលផល និងរួមចំណែកលើកស្ទួយជីវភាពរបស់សហគមន៍មូលដ្ឋាន។

ក្នុងនាមរដ្ឋបាលខេត្តបន្ទាយមានជ័យ ខ្ញុំសូមគាំទ្រ និងប្រកាសជាផ្លូវការក្នុងការដាក់ឱ្យប្រើប្រាស់ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹករយៈពេល៥ឆ្នាំ សម្រាប់ខេត្តបន្ទាយមានជ័យ។ រដ្ឋបាលខេត្តត្រៀមជានិច្ចនូវកិច្ចអន្តរាគមន៍ក្នុងការអនុវត្តផែនការនេះ ដើម្បីធានាឱ្យប្រាកដថា ធនធានជលផលរបស់យើងនឹងត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព សម្រាប់គាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ន និងអនាគត។

ថ្ងៃ១៤កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២២
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល**

**ពុំ សុធា**

ថ្ងៃសុក្រ ១៣រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
បន្ទាយមានជ័យ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២
**អភិបាល**
**នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ**

**អ៊ុំ រាត្រី**

# សេចក្តីថ្លែងអំណរគុណ

ក្រុមការងាររៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក នៃរដ្ឋបាលជលផល សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** ដែលបានគាំទ្រកម្មវិធី □**ជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ)**□ ហៅកាត់ថា CAPFISH-Capture សម្រាប់ការគ្រប់គ្រងធនធានជលផលនៅកម្ពុជា ព្រមទាំងការបង្កើត និងសម្របសម្រួលការងារគណៈកម្មការតម្រង់ទិសកម្មវិធី ដើម្បីជានានូវកិច្ចសហការល្អ រវាងរដ្ឋបាលជលផល ជាមួយស្ថាប័ន/អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្រុមការងារសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាប្រធានគណៈកម្មការតម្រង់ទិសកម្មវិធី CAPFISH-Capture ចំពោះការគាំទ្រដោយផ្ទាល់ និងកិច្ចប្រឹងប្រែងផ្តល់យោបល់ក្នុងការតម្រង់ទិស លើការអនុវត្តកម្មវិធីឱ្យស្របទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ទន្ទឹមនឹងនេះ ក្រុមការងារក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម **អ៊ុំ រាត្រី** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ព្រមទាំងមន្ត្រីបច្ចេកទេស ដែលបានគាំទ្រ និងសម្របសម្រួលរាល់បេសកកម្មរបស់មន្ត្រីរដ្ឋបាលជលផល ក្នុងការប្រមូលព័ត៌មាន និងទិន្នន័យសម្រាប់រៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ព្រមទាំងការផ្តល់ធាតុចូលតាមរយៈកិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធអំពីមូលហេតុ និងបញ្ហាដែលបង្កឱ្យមានភ្លើងឆេះព្រៃ ផលប៉ះពាល់នៃភ្លើងឆេះព្រៃ បទពិសោធន៍ល្អៗនៃការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃ យន្តការគ្រប់គ្រងភ្លើងឆេះព្រៃ និងការស្តារព្រៃលិចទឹកឡើងវិញ ជាការរួមចំណែកដ៏សំខាន់ក្នុងរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនេះ។

ក្រុមការងារក៏សូមសម្តែងការកោតសរសើរចំពោះ ឯកឧត្តម **ពុំ សុថា** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល ថ្នាក់ដឹកនាំរដ្ឋបាលជលផល លោក លោកស្រី ជាប្រធាន និងអនុប្រធាននាយកដ្ឋានអភិរក្សជលផល នាយកដ្ឋានកិច្ចការជលផល និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ និងសហការី ព្រមទាំងលោក លោកស្រី ជាមន្ត្រីខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការជួយរៀបចំបង្កើតឱ្យចេញជាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនេះឡើង ក្រោមការជួយសម្របសម្រួលពីមន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទខេត្ត។

សូមថ្លែងអំណរគុណជូនកញ្ញា **Rebekah Bell** តំណាងអង្គការ **FAO** ប្រចាំប្រទេសកម្ពុជា ព្រមទាំងលោក **David Brown** ប្រធានទីប្រឹក្សាបច្ចេកទេស និងមន្ត្រីបច្ចេកទេសនៃអង្គការ **FAO** ដែលបានជួយគាំទ្រ និងសម្របសម្រួលការងារបច្ចេកទេសក្នុងការរៀបចំផែនការនេះឡើង។

ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកសម្រាប់ខេត្តបន្ទាយមានជ័យ ក៏បានទទួលធាតុចូលពីអង្គការមួយចំនួនដែលមានសកម្មភាពក្នុងតំបន់បឹងទន្លេសាប ដូចជា UNESCO, FACT និង WCS ក្នុងការចែករំលែកព័ត៌មានពីការងារ និងបទពិសោធន៍តាមតំបន់គោលដៅរៀងៗខ្លួនផងដែរ។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណជាអនេក ជូនប្រតិភូសហភាពអឺរ៉ុបប្រចាំនៅប្រទេសកម្ពុជា ជាពិសេស លោកជំទាវ **Carmen Moreno** ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប លោក **Bryan Fornari** ប្រធានសហប្រតិបត្តិការនៃប្រតិភូសហភាពអឺរ៉ុប និងលោក **Sebastien Copin** អ្នកគ្រប់គ្រងកម្មវិធី CAPFISH-Capture និងជាសហប្រធាននៃក្រុមការងារបច្ចេកទេសសម្រាប់វិស័យជលផល ផ្តល់ការគាំទ្រថវិកាដល់ព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តសកម្មភាពនៃ □**កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្ន (ផ្នែកនេសាទ)**□ ។

# មាតិកា


**អារម្ភកថា** ........ I

**សេចក្តីថ្លែងអំណរគុណ** ........ II

**មាតិកា** ........ III

**១. សេចក្តីផ្តើម** ........ ១

**២. ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះក្នុងខេត្តបន្ទាយមានជ័យ** ........ ២

**២.១ ស្ថានភាពភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គមក្នុងខេត្តបន្ទាយមានជ័យ** ........ ២

**២.២ ស្ថានភាពជីវៈចម្រុះនៃតំបន់ទំនាបបឹងទន្លេសាបក្នុងខេត្តបន្ទាយមានជ័យ** ........ ៣

**៣. ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះ ក្នុងស្រុកគោលដៅ** ........ ៤

**៣.១ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះ ក្នុងស្រុកព្រះនេត្រព្រះ** ........ ៤

៣.១.១ ទិដ្ឋភាពភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គម ក្នុងស្រុកព្រះនេត្រព្រះ ........ ៤

៣.១.២ ទិដ្ឋភាពជីវៈចម្រុះ និងភ្លើងឆេះព្រៃលិចទឹកក្នុងស្រុកព្រះនេត្រព្រះ ........ ៥

**៣.២ ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះ ក្នុងស្រុកមង្គលបូរី** ........ ៧

៣.២.១ ទិដ្ឋភាពភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គម ក្នុងស្រុកមង្គលបូរី ........ ៧

៣.២.២ ទិដ្ឋភាពជីវៈចម្រុះ និងភ្លើងឆេះព្រៃលិចទឹកក្នុងស្រុកមង្គលបូរី ........ ៨

**៣.៣ ស្រុក និងឃុំគោលដៅនៃការគ្រប់គ្រងភ្លើងឆេះព្រៃ** ........ ៨

**៤. បញ្ហាប្រឈមនៃការគ្រប់គ្រងព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យ** ........ ៩

**៤.១ មូលហេតុនៃភ្លើងឆេះព្រៃលិចទឹក** ........ ៩

**៤.២ ទីតាំងភ្លើងឆេះព្រៃលិចទឹក** ........ ១០

**៤.៣ ស្ថាប័ន/អង្គភាពពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក** ........ ១០

**៤.៤ បញ្ហាប្រឈមក្នុងការចាត់វិធានការពន្លត់ភ្លើងឆេះព្រៃលិចទឹក** ........ ១៤

**៤.៥ ការអនុវត្តច្បាប់ជលផលដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក** ........ ១៥

**៥. ដំណើរការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក** ........ ១៦

**៥.១ ការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក** ........ ១៦

៥.១.១ ការពិនិត្យឡើងវិញ ........ ១៦

៥.១.២ ការកាត់បន្ថយហានិភ័យ ........ ១៧

៥.១.៣ ការត្រៀមរួចជាស្រេច ........ ១៨

**៥.២ ការពន្លត់ភ្លើងឆេះព្រៃលិចទឹក** ........ ២២

**៥.៣ការស្តារព្រៃលិចទឹក** ........ ២៣

**៦. សមភាពយេនឌ័រក្នុងការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក** ........ ២៩

**៧. ក្របខណ្ឌការងារនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក** ........ ៣០

**៧.១ ពេលវេលាអនុវត្ត** ........ ៣០

**៧.២ គោលបំណង** ........ ៣០

**៧.៣ គោលដៅ** ........ ៣០

**៧.៤ លទ្ធផលរំពឹងទុក** ........ ៣១

**៧.៥ ថវិកាប៉ាន់ស្មានសរុប** ........ ៣១

**៨. ការត្រួតពិនិត្យ និងវាយតម្លៃ** ........ ៣២

**៩. សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ខេត្តបន្ទាយមានជ័យ (២០២២-២០២៦)** ....... ៣៤
**១០. សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក ឆ្នាំ ២០២២-២០២៦** ....... ៣៩
**១០.១ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃ ស្រុកព្រះនេត្រព្រះ ឆ្នាំ២០២២-២០២៦** ....... ៣៩
**១០.២ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃ ស្រុកព្រះនេត្រព្រះ ឆ្នាំ២០២២-២០២៦** ....... ៤៤
**១១. ឧបសម្ព័ន្ធ** ....... ៤៩
**ឧបសម្ព័ន្ធ១៖ តារាងឈ្មោះព្រៃលិចទឹកនៅក្នុងតំបន់ទំនាបបឹងទន្លេសាប** ....... ៤៩
**ឧបសម្ព័ន្ធ២៖ តារាងឈ្មោះជីវៈចម្រុះនៅក្នុងតំបន់ទំនាបបឹងទន្លេសាប ខេត្តបន្ទាយមានជ័យ** ៥២
**ឧបសម្ព័ន្ធ៣៖ ផែនទីតំបន់ភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យ** ....... ៥៤

# ១. សេចក្តីផ្តើម

បឹងទន្លេសាបត្រូវបានពិពណ៌នាដោយប្រជាពលរដ្ឋកម្ពុជាថា ជាបេះដូងនៃវប្បធម៌ និងសេដ្ឋកិច្ចជាតិរបស់ខ្លួន ហើយតាមទស្សនៈពិភពលោកក៏បានទទួលស្គាល់ថា ជាបេះដូងនៃធនធានជលផលទឹកសាបរបស់កម្ពុជា ជាបឹងទឹកសាបដ៏ធំនៅអាស៊ីអាគ្នេយ៍ និងជាតំបន់ដីសើម ដែលមានផលិតភាពខ្ពស់ក្នុងចំណោមតំបន់ដីសើមជាច្រើននៅលើពិភពលោក។ ព្រៃលិចទឹក និងវាលទំនាបលិចទឹកនៅជុំវិញបឹងទន្លេសាបផ្តល់ជម្រកដ៏ល្អប្រសើរដល់មច្ឆជាតិ និងសត្វបក្សីទឹកដែលរងការគំរាមកំហែងមួយចំនួនសម្រាប់បង្កាត់ពូជ ពងកូន និងជាប្រភពផ្តល់ចំណីផងដែរ។ យោងតាមទិន្នន័យរបស់រដ្ឋបាលជលផល បង្ហាញថា ត្រីដែលចាប់បានពីបឹងទន្លេសាប ផ្តល់នូវប្រូតេអ៊ីនជាង៨០ភាគរយនៅក្នុងរបបអាហារក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយសារចំនួនប្រជាពលរដ្ឋ និងសេដ្ឋកិច្ចនៃព្រះរាជណាចក្រកម្ពុជាមានការរីកចម្រើនលូតលាស់ជាលំដាប់ ធ្វើឱ្យធនធានជលផលក្នុងបឹងទន្លេសាបរងការគំរាមកំហែងពីមួយថ្ងៃទៅមួយថ្ងៃ ដែលបង្កឡើងដោយសកម្មភាពរបស់មនុស្សក្នុងការប្រកួតប្រជែងប្រើប្រាស់ធនធានជលផល កាប់ឆ្ការ និងឈូសឆាយព្រៃលិចទឹកយកដីធ្វើកសិកម្ម ជាហេតុបណ្តាលឱ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់មច្ឆជាតិ សត្វព្រៃ សត្វស្លាប និងជីវៈចម្រុះនៃបឹងទន្លេសាប។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពស់ទឹកបឹងទន្លេសាបបានឈានដល់កម្រិតទាប ដោយសារតែការប្រែប្រួលអាកាសធាតុ ជាពិសេស ការឡើងកំដៅ ខ្យល់ព្យុះ និងគ្រោះរាំងស្ងួត។ កត្តាទាំងនេះបានបង្កឱ្យភ្លើងឆេះព្រៃលិចទឹកកាន់តែមានសភាពធ្ងន់ធ្ងរ ហើយជាលទ្ធផលបានធ្វើឱ្យប៉ះពាល់អវិជ្ជមានដល់កន្លែងអភិរក្សជលផល ជម្រកត្រី និងសត្វស្លាប សម្រាប់បង្កកំណើត និងផ្គត់ផ្គង់ចំណី ជាពិសេសតំបន់រ៉ាមសារព្រែកទាល់ ដែលជាដែនជម្រករបស់បក្សីទឹកធំជាងគេនៅអាស៊ីអាគ្នេយ៍។

មានកត្តាសំខាន់ចម្បងពីរ ដែលត្រូវបានគេចាត់ទុកថា ជាមូលហេតុបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់ទំនាបបឹងទន្លេសាប គឺដោយសារឧប្បត្តិហេតុអចេតនា និងចេតនារបស់មនុស្ស។ ករណីភ្លើងឆេះព្រៃលិចទឹកដែលកើតឡើងដោយអចេតនារួមមាន ការប្រើភ្លើងផ្សែងប្រមូលទឹកឃ្មុំ បោះចោលកន្ទុយបារីដែលនៅមានភ្លើង ចំអិនអាហារដោយមិនបានពន្លត់ភ្លើងមុននឹងចាកចេញ។ ករណីភ្លើងឆេះព្រៃដែលកើតឡើងដោយចេតនារួមមាន ការកាប់និងដុតព្រៃលិចទឹកដើម្បីយកដីធ្វើកសិកម្ម ដុតស្មៅ/ព្រៃដើម្បីចាប់សត្វនិងរកសត្វគោ-ក្របីដែលបានលែងឱ្យស៊ីស្មៅនៅក្នុងព្រៃ និងការត្រួសត្រាយដុតព្រៃដើម្បីដាក់ឧបករណ៍នេសាទបរ ឬដាយតូចៗកាត់អូរ ឬព្រែក។

ភ្លើងឆេះព្រៃគឺជាការគំរាមកំហែងដ៏ធ្ងន់ធ្ងរបំផុតចំពោះព្រៃលិចទឹក។ ការបាត់បង់ព្រៃលិចទឹកនឹងនាំឱ្យមានការថយចុះទាំងប្រភេទ និងចំនួនមច្ឆជាតិ ពពួកសត្វល្មូន និងសត្វស្លាប ហើយប្រសិនជាព្រៃលិចទឹកត្រូវបានរងនូវការឆេះជាញឹកញាប់ វានឹងប្រែក្លាយទៅជាវាលស្មៅ។

ដូចគ្នានេះដែរ ផលវិបាកនៃភ្លើងឆេះព្រៃលិចទឹកនៅតំបន់ទំនាបលិចទឹកបឹងទន្លេសាបក្នុងខេត្តបន្ទាយមានជ័យក៏ជះឥទ្ធិពលដល់ការថយចុះជាលំដាប់នូវធនធានជលផល ទាំងបរិមាណ និងប្រភេទត្រី វារីរុក្ខជាតិ សត្វស្លាប ពពួកសត្វល្មូន និងថនិកសត្វ ដែលបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជានេសាទ។

ដោយមើលឃើញនូវផលវិបាកនេះហើយ ទើបរដ្ឋបាលជលផល សហការជាមួយផ្នែកគាំទ្របច្ចេកទេសរបស់អង្គការFAO ដែលកំពុងអនុវត្តកម្មវិធី **ជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកនេសាទ** បានកំណត់ និងធ្វើការជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដែលទាក់ទងនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ស្រុក ឃុំ និងសហគមន៍នៅក្នុងខេត្តបន្ទាយមានជ័យ ដើម្បីរៀបចំ និងអនុវត្តផែនការទប់ស្កាត់និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក សំដៅកាត់បន្ថយហានិយភ័យនៃភ្លើងឆេះព្រៃនៅក្នុងខេត្ត។ ការបង្កើតឱ្យមានផែនការទប់ស្កាត់និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក គឺបង្កើតឱ្យមានការចូលរួម ដើម្បីធានាថា ការឆ្លើយតប ឬបទអន្តរាគមន៍ឱ្យទាន់ពេលវេលា និងដោយមានភាពបត់បែនតាមសភាពជាក់ស្តែង។

ក្រុមការងារបច្ចេកទេសគាំទ្រការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យ រួមមានមន្ត្រីចំនួន ១២នាក់ មកពីនាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល នៃរដ្ឋបាលជលផល ខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ និងទីប្រឹក្សាបច្ចេកទេសអង្គការ FAO បានចុះដល់ទីតាំងភ្លើងឆេះព្រៃ ប្រមូលព័ត៌មានបឋម និងព័ត៌មានដែលមានស្រាប់នៅមូលដ្ឋាន ដើម្បីរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកសម្រាប់។

បេសកកម្មនៅមូលដ្ឋានបានចាប់ផ្ដើមនៅក្នុងខែមិថុនា ឆ្នាំ២០២១ ដោយបានជួបប្រជុំជាមួយនឹងសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធនៅក្នុងឃុំ និងស្រុកគោលដៅ ដើម្បីប្រមូលព័ត៌មានអំពីមូលហេតុនៃភ្លើងឆេះព្រៃលិចទឹក សកម្មភាពដែលបានឆ្លើយតបទៅនឹងភ្លើងឆេះព្រៃ ស្ថាប័ន/អង្គភាពពាក់ព័ន្ធនឹងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក យន្តការគ្រប់គ្រងភ្លើងឆេះព្រៃដែលមានស្រាប់ វិធីសាស្ត្រស្តារព្រៃលិចទឹកដែលត្រូវភ្លើងឆេះ តម្រូវការសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់គាំទ្រការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។ ទន្ទឹមនឹងនេះដែរ និយាមកានៃទីតាំងភ្លើងឆេះព្រៃលិចទឹកត្រូវបានប្រមូល ហើយបានយកមករៀបចំជាផែនទីភ្លើងឆេះព្រៃលិចទឹក។

# ២. ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះក្នុងខេត្តបន្ទាយមានជ័យ

## ២.១ ស្ថានភាពភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គមក្នុងខេត្តបន្ទាយមានជ័យ

ខេត្តបន្ទាយមានជ័យ មានផ្ទៃដីសរុបទំហំ៦៦៧ ៨១៧ហិកតា ស្ថិតនៅប៉ែកពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា ចម្ងាយ៣៦០គ.ម ពីរាជធានីភ្នំពេញ។ ខេត្តនេះជាខេត្តធំទី១៣នៅក្នុងប្រទេស ដោយផ្អែកលើទំហំផ្ទៃដី និងជាខេត្តធំទី ១០ បើគិតអំពីចំនួនប្រជាពលរដ្ឋសរុប និងជាខេត្តដែលមានសក្តានុពលសេដ្ឋកិច្ចសំខាន់មួយនៅផ្នែកពាយ័ព្យ។

ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងជាប់នឹងស្រុកបន្ទាយអំពិល ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ និងខេត្តប៊ុរីរ៉ាំ នៃប្រទេសថៃ ខាងកើតជាប់នឹងស្រុកស្រីស្នំ និងស្រុកក្រឡាញ់ ខេត្តសៀមរាប ខាងត្បូងជាប់នឹងស្រុកសំពៅលូន ស្រុកបាវិល ស្រុកថ្មគោល និងស្រុកឯកភ្នំ ខេត្តបាត់ដំបង និងខាងលិចជាប់នឹងខេត្តសាកែវនៃប្រទេសថៃ។ ខេត្តនេះមានក្រុងចំនួនពីរគឺ ក្រុងសិរីសោភ័ណ្ឌ និងក្រុងប៉ោយប៉ែតដែលស្ថិតនៅភាគខាងលិច ជាចំណុចច្រកចេញចូលឆ្លងព្រំដែនអន្តរជាតិរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសថៃ។

ខេត្តបន្ទាយមានជ័យ បានចែកចេញជា២ក្រុង ៧ស្រុក ១០សង្កាត់ ៥៥ឃុំ ៧២២ភូមិ និងមានប្រជាពលរដ្ឋសរុបចំនួន៨១៥ ៥២២នាក់ (ស្ត្រី៤០៦ ៤៨១នាក់) ស្មើនឹង១៩៤ ៨៦៣គ្រួសារ ជាមួយនឹងអត្រាកំណើនប្រជាពលរដ្ឋប្រចាំឆ្នាំជាមធ្យម០,៥៥ភាគរយ) ដែលក្នុងនោះ៦៦,៩០ភាគរយ ជាកសិករប្រកបមុខរបរកសិកម្មរយៈពេលវែង (កៅស៊ូ ដូងប្រេង ស្វាយចន្ទី ស្វាយ ធូរេន មៀន ក្រូចពោធិ៍សាត់ ម្រេច អំពៅ) កសិកម្មរយៈពេលខ្លី (ស្រូវ ពោត ដំឡូងមី ដំឡូងជ្វា ល្ង សណ្តែកបាយ សណ្តែកសៀង សណ្តែកដី) ចិញ្ចឹមសត្វ (គោ ក្របី ពពែ ជ្រូក មាន់ និងទា) នេសាទ (០,៣៣ភាគរយ) និងវារីវប្បកម្មរួមមានក្រពើ ត្រី បង្កង និងបង្គា *(ប្រភព៖ ឯកសារព័ត៌មានស្តីពីសេដ្ឋកិច្ច-សង្គមកិច្ចខេត្តបន្ទាយមានជ័យ ឆ្នាំ២០២១ មន្ទីរផែនការ ខេត្តបន្ទាយមានជ័យ)*។

ផ្អែកលើទិដ្ឋភាពភូមិសាស្ត្រ ខេត្តនេះភាគច្រើនគ្របដណ្តប់ដោយតំបន់ខ្ពង់រាប ដែលមានភ្នំមួយចំនួនស្ថិតនៅភាគខាងជើង និងខាងកើតនៃភូមិសាស្ត្រខេត្ត ហើយមានផ្នែកមួយតូច (ប្រហែល១២ភាគរយនៃផ្ទៃដីខេត្តសរុប) នៅទិសអាគ្នេយ៍ក្នុងស្រុកព្រះនេត្រព្រះ និងស្រុកមង្គលបូរី គឺជាតំបន់ទំនាបបឹងទន្លេសាប ដែលមានព្រៃលិចទឹកស្ទើរតែទាំងអស់ស្ថិតនៅក្នុងតំបន់៣។

ស្ទឹងសំខាន់ៗនៅក្នុងខេត្តមានចំនួនពីរគឺ ស្ទឹងមង្គលបុរី និងស្ទឹងសិរីសោភ័ណ។ ស្ទឹងមង្គលបូរីមានប្រភព

មកពីភ្នំសាយខាវកម្ពស់១ ៤៧០ម៉ែត្រ នៅក្នុងប្រទេសថៃ ហើយបានទទួលទឹកភ្លៀងបន្ថែមពីស្ទឹងសិរីសោភ័ណ ដែលមានប្រភពមកពីប្រទេសថៃមុននឹងហូរចាក់ចូលស្ទឹងសង្កែ ដែលមានប្រភពនៅភ្នំតាលរ កម្ពស់៧០០ម៉ែត្រ នៅក្នុងខេត្តបាត់ដំបង ហើយជាចុងក្រោយហូរចាក់ទៅក្នុងបឹងទន្លេសាប។

## ២.២ ស្ថានភាពជីវៈចម្រុះនៃតំបន់ទំនាបបឹងទន្លេសាបក្នុងខេត្តបន្ទាយមានជ័យ

ខេត្តបន្ទាយមានជ័យគឺជាខេត្តទី៦ នៃបណ្តាខេត្តស្ថិតនៅជុំវិញបឹងទន្លេសាប ដែលមានតំបន់ទំនាបលិចទឹកបឹងទន្លេសាបតូចជាងគេបង្អស់ និងមិនជាប់ផ្ទាល់នឹងផ្ទៃបឹងទន្លេសាប។ តំបន់ទំនាបនេះស្ថិតនៅភាគខាងលិចនៃខេត្ត ក្នុងស្រុកព្រះនេត្រព្រះ និងស្រុកមង្គលបូរី ដែលគ្រប់ដណ្តប់លើផ្ទៃដីប្រហែលជា១៥ភាគរយ នៃផ្ទៃដីសរុបរបស់ខេត្ត។ ការគ្រប់គ្រងវិស័យជលផលរបស់ខណ្ឌរដ្ឋបាលជលផលនៅក្នុងខេត្តបន្ទាយមានជ័យមានការវិវត្តន៍ និងភាពរីកចម្រើនជារៀងរាល់ឆ្នាំ។ កិច្ចការជលផលសំខាន់ៗនៅក្នុងខេត្តនេះរួមមាន ការគ្រប់គ្រងកន្លែងអភិរក្សជលផល សហគមន៍នេសាទ សហគមន៍ស្រះជម្រកត្រី ការផលិតកូនត្រីពូជ វារីវប្បកម្មទឹកសាប និងអធិការកិច្ចលើការដឹកជញ្ជូនផលនេសាទនៅទូទាំងខេត្ត។

យោងតាមអនុក្រឹត្យលេខ១៩៧ អនក្រខេត្ត ៣ព្រៃលិចទឹកក្នុងតំបន់ ២០១១ខែសីហា ឆ្នាំ ២៩បក ចុះថ្ងៃទី. បក.អនក្រ ១០៦ហិកតា និងអនុក្រឹត្យលេខ០៤៧ ១២បន្ទាយមានជ័យ មានទំហំចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ ស្តីពីការកែសម្រួលផ្ទៃដីទំហំ៥៨ហិកតា ១៦អា និង ៦៨សង់ទីអា ចេញពីតំបន់៣ បញ្ចូលមកតំបន់២ នៃតំបន់ទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រខេត្តបន្ទាយមានជ័យ និងប្រគល់ជូនប្រជាពលរដ្ឋប្រើប្រាស់ និងអាស្រ័យផល។ ខេត្តនេះមានកន្លែងអភិរក្សជលផលចំនួន២ សហគមន៍នេសាទចំនួន១៩ និងសហគមន៍ស្រះជម្រកត្រីចំនួន៥៤។

នៅក្នុងចំណោមសហគមន៍នេសាទទាំង១៩ មានសហគមន៍នេសាទភ្លៀតកោះពងសត្វ បានបង្កើតឡើងក្នុងឆ្នាំ ២០០១ មានទំហំ៤ ៨៦៧ហិកតា គ្របដណ្តប់លើផ្នែកមួយនៃស្ទឹងសេរីសោភ័ណ ស្ថិតភូមិកោះពងសត្វ ភូមិព្រះអង្គ និងភូមិស្នាយដង្គត់ ឃុំកោះពងសត្វ ក្រុងសេរីសោភ័ណ ត្រូវបានគេស្គាល់ថា ជាតំបន់ទេសចរណ៍ធម្មជាតិដ៏ល្បីមួយនៅក្នុងខេត្ត ហើយមានភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិជាច្រើនបានមកទស្សនា។ ក្នុងសហគមន៍នេះដែរក៏មានវត្តមានត្រីមេពូជធំៗដូចជា ត្រីឆ្តិន ក្រុស ប៉ាលុង ឆ្លាំង លិញ ក្អែក ប្រា ពោ ក្រាយ ស្លាត រៀល រ៉ស់ អណ្តែង ។ល។ ដែលផ្តុំគ្នានៅវត្តភ្លៀត។ នៅរដូវទឹកឡើង ត្រីមេពូជទាំងនោះបម្លាស់ទីទៅតាមប្រព័ន្ធផ្លូវទឹកធម្មជាតិ វាលស្រែ វាលស្មៅ ព្រៃលិចទឹក ដើម្បីបន្តពូជ ពងកូន និងសាយភាយកូនពាសពេញវាលទំនាបបឹងទន្លេសាប។

មុនឆ្នាំ១៩៩៩ ខេត្តបន្ទាយមានជ័យ មានឡូត៍នេសាទចំនួន០៣៖ ឡូត៍លេខ១ ឡូត៍លេខ២ និងឡូត៍លេខ៣។ ក្នុងឆ្នាំ២០០០ ឡូត៍នេសាទលេខ៣ ត្រូវបានលុបចោល ដើម្បីពង្រីកវិសាលភាពដែននេសាទសាធារណៈសម្រាប់ប្រជានេសាទ។ ក្នុងឆ្នាំ២០១២ ឡូត៍នេសាទលេខ១ និងលេខ២ ត្រូវបានត្រូវបានរំសាយចោលជាស្ថាពរ ដោយបានរក្សាទុកទីតាំងដែលមានតម្លៃជីវៈចម្រុះខ្ពស់ជាកន្លែងអភិរក្សជលផល (កន្លែងអភិរក្សជលផលរហាលកំព្រឹងក្នុងអតីតឡូត៍លេខ១ និងកន្លែងអភិរក្សជលផលរហាលស្ទឹងកំបុត ក្នុងអតីតឡូត៍លេខ២) ហើយក្រៅពីនេះ ត្រូវបានកំណត់ជាដែននេសាទសាធារណៈ ស្របទៅតាមការចង់បានរបស់ប្រជានេសាទ។

មុនឆ្នាំ២០១០ ប្រហែលជា៦៥ភាគរយ នៃផ្ទៃដីសរុបនៃវាលទំនាបនេះគ្របដណ្តប់ដោយព្រៃលិចទឹក ប៉ុន្តែបច្ចុប្បន្នប្រហែលជា៩០ភាគរយ នៃផ្ទៃដីទំនាបសរុប គ្របដណ្តបដោយវាលស្រែស្រូវវស្សា ស្រូវប្រាំង ស្រូវបណ្តែញទឹក និងវាលស្រែស្រូវវារ ព្រមទាំងប្រព័ន្ធស្រោចស្រប់ជាច្រើន (អាង និងប្រឡាយទឹក) ត្រូវបានរៀបចំដើម្បីប្រើប្រាស់សម្រាប់ធ្វើស្រែក្នុងតំបន់នេះ។ ក្រៅពីស្រូវ គេសង្កេតឃើញមានការដាំដំណាំរួមផ្សំជាលក្ខណៈគ្រួសារតិចតួច ដូចជា ល្ង ល្ពៅ និងឪឡឹក ។ល។

ក្រៅពីវាលស្រែ ប្រហែលជា១០ភាគរយ នៃផ្ទៃដីទំនាបលិចទឹកសរុប គឺជាព្រៃលិចទឹកដែលភាគច្រើនស្ថិតនៅក្នុងតំបន់គ្រប់គ្រងរបស់សហគមន៍នេសាទ កន្លែងអភិរក្សជលផល និងនៅតាមដងស្ទឹង/អូរ។ ព្រៃលិចទឹកដែលនៅសល់ក្នុងតំបន់២ មានប្រហែលជា២០០ហិកតា ស្ថិតក្នុងឃុំរហាល ស្រុកព្រះនេត្រព្រះ ក្រៅពីនោះស្ថិតនៅក្នុងតំបន់៣។

ចំពោះទិដ្ឋភាពព្រៃលិចទឹកស្ថិតនៅក្នុងដែនគ្រប់គ្រងរបស់សហគមន៍នេសាទប្រហែល៩០ភាគរយ លុបដោយព្រៃគុម្ពោត[1]/រនាម ក្នុងនោះមានប្រភេទ ដើមដៃខ្លា ថ្លើមអណ្តើក ដង្កៀបក្តាម អញ្ចាញ ប្របួយ ប្រផេញញី ប្រផេញឈ្មោល ផ្ទេញត្រី ភ្អែកព្រាប ឈ្មៀលមាន់។ល។ និង១០ភាគរយទៀត ជាប្រភេទព្រៃលិចទឹកធំៗដូចជា ដើមរាំង ត្លួ ខ្ទុំ និងច្រកែង ដុះរាយប៉ាយក្នុងព្រៃគុម្ពោត មានគម្លាតប្រហែល២៥-៥០ម៉ែត្រពីគ្នា ជាមួយនឹងដង់ស៊ីតេឈើឈរដែលមានមុខកាត់ធំជាង៣០ស.ម ប្រហែលជា១៦ដើម/ហិកតា។

ទោះបីជាមានការការពារជាប្រចាំដោយសហគមន៍ ព្រៃលិចទឹកកំពុងស្ថិតនៅក្រោមការគម្រាមកំហែងដោយកាប់ទន្ទ្រានយកដីធ្វើស្រែ និងភ្លើងឆេះព្រៃលិចទឹកដែលបានកើតឡើងជារៀងរាល់ឆ្នាំ ភាគច្រើនបង្កឡើងដោយការដុតព្រៃលិចទឹកយកដីធ្វើស្រែ និងសកម្មភាពធ្វេសប្រហែសនៃការចំអិនអាហារ និងយកទឹកឃ្មុំ។ ភ្លើងឆេះព្រៃលិចទឹកត្រូវបានឃើញកើតមានជាញឹកញាប់នៅក្នុងឃុំភ្នំលៀប និងឃុំប្រាសាទ នៃស្រុកព្រះនេត្រព្រះ និងឃុំសំបួរ នៃស្រុកមង្គលបូរី។ មានភ្លើងឆេះព្រៃលិចទឹកតិចតួចនៅក្នុងឃុំរហាល នៃស្រុកព្រះនេត្រព្រះ ព្រោះតំបន់ព្រៃលិចទឹកស្ថិតនៅក្បែរភូមិ ងាយទប់ស្កាត់ និងពន្លត់។

ភ្លើងឆេះព្រៃលិចទឹកដែលបានកើតឡើងជារៀងរាល់ឆ្នាំ ធ្វើឱ្យទម្រង់ធនធានគម្របដីព្រៃលិចទឹក និងប្រព័ន្ធអេកូឡូស៊ីមានការប្រែប្រួល។ នេះមានន័យថា ដង់ស៊ីតេព្រៃលិចទឹកបានថយចុះ ប៉ុន្តែបង្កើនដង់ស៊ីតេនៃព្រៃគុម្ពោតស្រទាប់ក្រោម។ ប្រភេទតិណជាតិ វល្លិ៍ និងស្មៅនៅស្រទាប់ក្រោម ក៏បានកើនឡើងផងដែរនៅក្នុងទីតាំងដែលមិនមាន ឬមានដុះព្រៃគុម្ពោតតិចតួច។

ផ្អែកលើស្ថានភាព និងលក្ខខណ្ឌជីវៈចម្រុះនៅក្នុងខេត្តនេះ ជាពិសេសវត្តមាននៃព្រៃលិចទឹក និងការកើតមានឡើងនូវភ្លើងឆេះព្រៃលិចទឹក ស្រុកចំនួន០២ក្នុងចំណោមស្រុកទាំង០៧ គឺស្រុកព្រះនេត្រព្រះ និងស្រុកមង្គលបូរី ត្រូវបានកំណត់ និងជ្រើសរើសជាស្រុកគោលដៅសម្រាប់ការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ ផ្នែកខាងក្រោមនេះនឹងរៀបរាប់អំពីទិដ្ឋភាពនៃស្ថានភាពព្រៃលិចទឹក និងភ្លើងឆេះព្រៃលិចទឹកនៅក្នុងឃុំនីមួយៗ។

## ៣. ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះ ក្នុងស្រុកគោលដៅ

ស្រុកព្រះនេត្រព្រះ និងស្រុកមង្គលបូរី ត្រូវបានជ្រើសរើសជាស្រុកគោលដៅ ហើយផ្នែកនេះនឹងបញ្ជាក់អំពីលក្ខណៈពិសេសដែលនឹងត្រូវយកមកបង្ហាញ និងវិភាគ ដើម្បីកំណត់ឃុំគោលដៅក្នុងស្រុកនីមួយៗ ដែលនឹងចូលរួមចំណែកក្នុងការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយផ្ទាល់នៅក្នុងរយៈពេល០៥ឆ្នាំខាងមុខនេះ។

### ៣.១ ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះ ក្នុងស្រុកព្រះនេត្រព្រះ

#### ៣.១.១ ទិដ្ឋភាពភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គម ក្នុងស្រុកព្រះនេត្រព្រះ

ស្រុកព្រះនេត្រព្រះស្ថិតនៅភាគអគ្នេយ៍ នៃខេត្តបន្ទាយមានជ័យ មានចម្ងាយប្រហែលជា២៩គ.ម ពីក្រុងសេរីសោភ័ណ។ ស្រុកនេះមានព្រំប្រទល់ខាងជើងជាប់នឹងស្រុកភ្នំស្រុក និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ខាងកើតជាប់នឹងស្រុកក្រឡាញ់ ខេត្តសៀមរាប ខាងត្បូងជាប់នឹងស្រុកឯកភ្នំ ខេត្តបាត់ដំបង និងខាងលិចជាប់នឹងក្រុងសេរីសោភ័ណ និងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

ស្រុកព្រះនេត្រព្រះមានឃុំចំនួន០៩ និងភូមិចំនួន១៣០ ដែលមានចំនួនប្រជាពលរដ្ឋសរុប១០៩ ៩៥៥នាក់ (ស្រី៥៤ ៩៤៧នាក់) ស្មើនឹង២៥ ២១៨គ្រួសារ ក្នុងនោះមាន៨១,៦០ភាគរយ ជាកសិករប្រកបមុខរបរកសិកម្ម ដាំដំណាំរយៈពេលខ្លី និងវែង (ស្រូវ ពោត សណ្តែកបាយ សណ្តែកដី ល្ង ដំឡូងមី អំពៅ កៅស៊ូ ស្វាយចន្ទី និងស្វាយ) ការចិញ្ចឹមសត្វ (គោ ក្របី ជ្រូក ពពែ មាន់ និងទា) វារីវប្បកម្ម (ចិញ្ចឹមត្រី និងក្រពើ) និងប្រកបរបរនេសាទ (១,៩ភាគរយ)។ ក្រៅពីនេះ មានប្រជាពលរដ្ឋចំនួន១៧,៤០ភាគរយ ប្រកបមុខរបរផ្តល់សេវាកម្ម (មន្ត្រីរាជការ បុគ្គលិកក្រុម

[1] ការបែងចែកធនធានគម្របដីព្រៃឈើ (ប្រភព៖ធនធានគម្របព្រៃឈើនៅកម្ពុជា ឆ្នាំ២០១៤ កម្មវិធីរេដបូកកម្ពុជា)

ហ៊ុន បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល កម្មកររោងចក្រ កម្មករសំណង់ ជំនួញ លក់ដូរ ជួសជុលបរិក្ខារអគ្គិសនីនិងគ្រឿងយន្ត។ល។) និង១ភាគរយទៀត ពាក់ព័ន្ធនឹងវិស័យសិប្បកម្ម ដូចជាគ្រឿងសង្ហារឹម និងរូបចម្លាក់។

នៅក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ ស្រុកព្រះនេត្រព្រះមានផ្ទៃដីស្រែសរុបទំហំ៦៨ ០០៨ហិកតា គិតទាំងស្រូវវស្សា ស្រូវប្រាំង ស្រូវបង្កើនរដូវ និងស្រូវចំការ ក្នុងនោះមានដីស្រែប្រាំងទំហំ១២ ៨៧០ហិកតា ដែលមានទិន្នផលស្រូវជាមធ្យម៣,៤០តោន/ហិកតា និងដីស្រែវស្សាទំហំ៥៦ ១៤៣ហិកតា ដែលមានទិន្នផលស្រូវជាមធ្យម១,៧០តោន/ហិកតា *(ប្រភពព័ត៌មាន៖ ឯកសារព័ត៌មានពីស្ថានភាពស្តីពីសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០២១ ស្រុកព្រះនេត្រព្រះ មន្ទីរផែនការខេត្តបន្ទាយមានជ័យ)*។

ប្រហែលជា៣០ភាគរយ នៃផ្ទៃដីស្រែប្រាំងសរុបក្នុងស្រុកព្រះនេត្រព្រះ ស្ថិតនៅខាងលើផ្លូវជាតិលេខ៦ ដែលបានទទួលទឹកពីទំនប់ទឹកធំៗពីរគឺ ទំនប់ទឹកអាងត្រពាំងថ្ម ស្ថិតនៅក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ និងទំនប់ទឹកស្ទឹងស្រែងទី២ "អាតោ" ស្ថិតនៅក្នុងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ។ រីឯផ្ទៃដីស្រែប្រាំងប្រហែលជា៧០ភាគរយទៀត ស្ថិតនៅក្នុងតំបន់២ និងតំបន់៣ បានទទួលរបបទឹកពីស្ទឹងមង្គលបូរី និងស្ទឹងសេរីសោភ័ណ្ឌ និងប្រព័ន្ធស្រោចស្រប់ដែលបានរៀបចំនៅទីនោះ។

### ៣.១.២ ទិដ្ឋភាពជីវៈចម្រុះ និងភ្លើងឆេះព្រៃលិចទឹកក្នុងស្រុកព្រះនេត្រព្រះ

ផ្អែកលើទីតាំងភូមិសាស្ត្រ និងវត្តមានជាក់ស្តែងនាពេលបច្ចុប្បន្ននៃធនធានជលផល ជាពិសេសព្រៃលិចទឹក និងបញ្ហាប្រឈមនឹងភ្លើងឆេះព្រៃលិចទឹក ក្នុងចំណោមឃុំទាំង០៩ ក្នុងស្រុកព្រះនេត្រព្រះ មានឃុំតែ៥ប៉ុណ្ណោះ ដែលមានទីតាំងដីលំនៅដ្ឋានស្ថិតនៅជាប់ និងក្នុងតំបន់ទំនាបបឹងទន្លេសាប ហើយប្រជាកសិករស្ទើរតែទាំងអស់ដែលរស់នៅក្នុងឃុំទាំងនោះមានការពាក់ព័ន្ធនឹងការប្រើប្រាស់ដីសម្រាប់កសិកម្ម និងធនធានជលផល។ ឃុំទាំង៥រួមមាន ឃុំប្រាសាទ ភ្នំលៀប រហាល ព្រះនេត្រព្រះ និងឃុំឈ្នួរមានជ័យ។

ស្រុកព្រះនេត្រព្រះមានសហគមន៍នេសាទចំនួន០៩ គ្របដណ្តប់លើផ្ទៃដីទំហំ៤០ ១៩២ហិកតា ស្ថិតនៅឃុំព្រះនេត្រព្រះ ឃុំភ្នំលៀប ឃុំប្រាសាទ និងឃុំរហាល និងកន្លែងអភិរក្សជលផលចំនួន០១ (រហាលស្ទឹងកំបុត) ដែលមានផ្ទៃដីទំហំ១៧១ហិកតា ព្រមទាំងកន្លែងអភិរក្សត្រីមេពូជ និងសត្វស្លាបរហាលកេះមួយទៀត។ នៅក្នុងចំណោមសហគមន៍នេសាទទាំង៩ មានតែសហគមន៍នេសាទចំនួន០៥ប៉ុណ្ណោះ ដែលមានព្រៃលិចទឹក។ ក្រៅពីនេះ ស្រុកព្រះនេត្រព្រះមានសហគមន៍ស្រះជម្រកត្រីចំនួន០៧ទៀត ស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ជប់វារី ទានកាំ និងឃុំបុស្សរូវ។

**តារាងទី១៖ បញ្ជីឈ្មោះសហគមន៍នេសាទ កន្លែងអភិរក្សត្រីមេពូជ និងកន្លែងអភិរក្សជលផល ដែលមានព្រៃលិចទឹកក្នុងស្រុកព្រះនេត្រព្រះ**

| ល.រ | សហគមន៍នេសាទ/កន្លែងអភិរក្សត្រីមេពូជ/កន្លែងអភិរក្សជលផល | ឃុំ | ផ្ទៃដី (ហ.ត) | ទំហំព្រៃលិចទឹកដែលមាន (ហ.ត) |
|---|---|---|---|---|
| ១ | សហគមន៍នេសាទដង្កៀបក្តាមមានជ័យ | ប្រាសាទ | ១៤ ៣០០ | ≈ ១ ០០០ |
| ២ | សហគមន៍នេសាទទំនប់អូរតាសោម | ភ្នំលៀប | ៦ ៧០០០ | ≈ ៧០០ |
| ៣ | សហគមន៍នេសាទស្ទឹងកំបុតមានជ័យ | រហាល | ២ ៦៦០ | < ៥០០ |
| ៤ | សហគមន៍នេសាទកំបោរ | ភ្នំលៀប | ៦ ៨៧០ | < ៣០០ |
| ៥ | សហគមន៍នេសាទអូរអន្ទះបាញ់ | ព្រះនេត្រព្រះ | ៤ ៨៦៧ | < ១០០ |
| ៦ | កន្លែងអភិរក្សជលផលរហាលស្ទឹងកំបុត | ព្រះនេត្រព្រះ និងរហាល | ៧៨ | ≈ ៤០ |
| ៧ | កន្លែងអភិរក្សពូជត្រីរហាលកេះ | ឈ្នួរមានជ័យ | ៣០ | ២៥ |
| ៨ | សហគមន៍នេសាទរហាលលិចស្រះ | ព្រះនេត្រព្រះ | ២ ១៦៨ | គ្មានព្រៃលិចទឹក |

| | | | | |
|---|---|---|---|---|
| ៩ | សហគមន៍នេសាទគុយម៉ែងព្រះនេត្រព្រះ | ព្រះនេត្រព្រះ | ១ ៤៧៦ | គ្មានព្រៃលិចទឹក |
| ១០ | សហគមន៍នេសាទតាឡមព្រះនេត្រព្រះ | ព្រះនេត្រព្រះ | ១ ២២៨ | គ្មានព្រៃលិចទឹក |
| ១១ | សហគមន៍នេសាទសាមគ្គីមានជ័យ | រហាល និងជប់វារី | ២៣,៣០ | គ្មានព្រៃលិចទឹក |

កន្លែងអភិរក្សជលផលរហាលស្ទឹងកំបុត ស្ថិតនៅតាមបណ្តោយដងស្ទឹងកំបុត (នៅក្នុងអតីតឡូត៍នេសាទលេខ ២) ក្នុងឃុំព្រះនេត្រព្រះ និងឃុំរហាល។ ដោយសារកន្លែងអភិរក្សនេះជាតំបន់ដីសើម និងត្រូវបានការពារជាប្រចាំដោយផ្នែករដ្ឋបាលជលផលព្រះនេត្រព្រះ គេឃើញមានព្រៃលិចទឹកធំៗ ខ្ពស់ៗ ដែលមានដង់ស៊ីតេក្រាស់ ប្រហែល ១៥០ដើមក្នុង១ហិកតា និងមានមុខកាត់ពី២០ស.ម រហូតដល់៧០ស.ម គ្របដណ្តប់នៅជុំវិញមាត់បឹងអភិរក្ស។ ប្រភេទព្រៃលិចទឹកនៅក្នុងកន្លែងអភិរក្សនេះរួមមានដើមរាំង (ប្រភេទលប់) ត្នួរ ត្រសេក ខ្ទុំ និងសណ្តាន់។ យោងតាមរបាយការណ៍ពីផ្នែករដ្ឋបាលជលផលព្រះនេត្រព្រះ នៅក្នុងឆ្នាំ២០១៨ មានភ្លើងឆេះព្រៃលិចទឹកមួយករណី លើផ្ទៃដីប្រហែលជា៥ហិកតា បានកើតមានឡើងនៅក្នុងកន្លែងអភិរក្សនេះ។

ស្ថានភាពព្រៃលិចទឹក និងភ្លើងឆេះព្រៃលិចទឹកនៅក្នុងឃុំពាក់ព័ន្ធនៅក្នុងស្រុកព្រះនេត្រព្រះត្រូវបានរៀបរាប់សង្ខេបដូចខាងក្រោម៖

- **ឃុំឈ្នួរមានជ័យ៖** នៅក្នុងឃុំនេះគេឃើញមានព្រៃលិចទឹកប្រហែល២៥ហិកតា ស្ថិតនៅក្នុងកន្លែងអភិរក្សពូជត្រីរហាលកេះ និងអភិរក្សសត្វស្លាប និងនៅត្រង់ចំណុចដៃអូរអារៀន ក្នុងភូមិរពាក់ មានផ្ទៃសរុបប្រហែល៣០ហិកតា។ កន្លែងអភិរក្សទាំងពីរនេះស្ថិតនៅក្រោមសមត្ថកិច្ចរបស់អាជ្ញាធរឃុំ តាមរយៈការគ្រប់គ្រងដោយសហគមន៍សាមី។ ដោយសារព្រៃលិចទឹកនៅទីនោះមានទំហំតូច សហគមន៍គ្រប់គ្រងបានល្អ ជាពិសេសមានអូរអារៀនព័ទ្ធជុំវិញ ដែលជាប្រព័ន្ធផ្លូវភ្លើងធម្មជាតិដ៏មានប្រសិទ្ធភាពមួយ ការពារព្រៃលិចទឹកនៅទីនោះមិនឱ្យទទួលរងនូវភ្លើងឆេះបានឡើយ។
- **ឃុំព្រះនេត្រព្រះ៖** នៅក្នុងឃុំនេះមានព្រៃលិចទឹកនៅសល់តិចតួច ស្ថិតនៅរាយប៉ាយតាមដងស្ទឹង និងដងអូរធម្មជាតិ ព័ទ្ធជុំវិញទៅដោយវាលស្រែ ដូច្នេះករណីភ្លើងឆេះព្រៃលិចទឹកមិនមានកើតឡើងទេ។ ប៉ុន្តែដោយសារឃុំនេះមានប្រជាកសិករជាច្រើនគ្រួសារមានដីអាស្រ័យផលនៅក្នុងតំបន់៣ ដែលស្ថិតនៅជាប់ និងក្បែរព្រៃលិចទឹក អាជ្ញាធរស្រុក និងខណ្ឌរដ្ឋបាលជលផលតម្រូវឱ្យប្រជាពលរដ្ឋនៅក្នុងឃុំនេះ ចូលរួមក្នុងការទប់ស្កាត់ការកាប់ទន្ទ្រានព្រៃលិចទឹក និងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ជាពិសេសចូលរួមក្នុងការផ្សព្វផ្សាយដល់សាធារណៈជន អំពីការចូលរួមទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។
- **ឃុំរហាល៖** មានសហគមន៍នេសាទចំនួន២ ក្នុងនោះមានតែសហគមន៍នេសាទស្ទឹងកំបុតមានជ័យមួយប៉ុណ្ណោះ ដែលមានព្រៃលិចទឹក។ ព្រៃលិចទឹកនៅទីនោះលប់ដោយប្រភេទព្រៃគុម្ពោត មានកម្ពស់រហូតដល់ជិត៥ម៉ែត្រ កម្រិតម្លប់ប្រហែលជា៨០ភាគរយ។ ប្រភេទដើមព្រៃលិចទឹកមាន រាំង ត្នួរ ខ្ទុំ ច្រកែង កន្ទ្រែង និងត្រសេកទឹក ដែលមានមុខកាត់រហូតដល់៥០ស.ម ភាគច្រើននៅផ្តុំគ្នានៅតាមដងអូរ និងស្ទឹង និងដុះនៅរាយប៉ាយក្នុងចន្លោះព្រៃគុម្ពោត។ ដោយសារព្រៃលិចទឹកស្ថិតនៅនៅក្បែរភូមិ ត្រូវបានឃ្លាំមើល និងការពារជាប្រចាំដោយសហគមន៍នេសាទ ករណីភ្លើងឆេះព្រៃលិចទឹក និងការកាប់ទន្ទ្រានព្រៃលិចទឹករានយកដីធ្វើកសិកម្មនៅក្នុងឃុំនេះកម្រនឹងកើតមានឡើងណាស់។
- **ឃុំភ្នំលៀប និងឃុំប្រាសាទ៖** ឃុំទាំងពីរនេះមានសហគមន៍នេសាទសរុបចំនួន៣ ដែលមានព្រៃលិចទឹក និងមានស្ថានភាពប្រហាក់ប្រហែលគ្នា។ ឃុំប្រាសាទមានសហគមន៍នេសាទចំនួន១គឺ "ដង្កៀបក្តាមមានជ័យ" មានព្រៃលិចទឹកប្រហែល១ ០០០ហិកតា។ ឃុំភ្នំលៀបវិញមានសហគមន៍នេសាទចំនួន២គឺ សហគមន៍នេសាទទំនប់អូរតាសោម មានព្រៃលិចទឹកប្រហែល៧០០ហិកតា និងសហគមន៍នេសាទកំបោរ មានព្រៃលិច

ទឹកប្រហែលជា៣០០ហិកតា។ ព្រៃលិចទឹកគ្របដណ្ដប់ស្ទើរតែពាសពេញផ្ទៃដីរបស់សហគមន៍នេសាទទាំង៣។ ប្រភេទព្រៃលិចទឹករួមមាន រាំង ខ្ទុំ កន្សែង ត្នួរ និងត្រសេកទឹក ដែលមានមុខកាត់រហូតដល់៥០ស.ម ដុះនៅលាយឡំជាមួយប្រភេទព្រៃគុម្ពោតក្រាស់ ដែលមានដង់ស៊ីតេនៃកម្រិតម្លប់ប្រហែលជា៨០ភាគរយ។ នៅក្នុងព្រៃលិចនៃឃុំទាំងពីរ គេឃើញមានវាលស្មៅ និងស្រង៉ែ ជាច្រើនកន្លែងដែលជាទីកន្លែងស្នាក់នៅបណ្ដោះអាសន្នរបស់អ្នកចិញ្ចឹមគោ និងក្របីនៅរដូវប្រាំង ព្រោះមានបឹង/ត្រពាំង និងទឹកសម្រាប់មនុស្ស និងសត្វ។ ក្រុមអ្នកគង្វាលសត្វត្រូវបានចាត់ទុកថាជាមុខសញ្ញាហានិភ័យមួយនៃការបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកផងដែរ។

បើប្រៀបធៀបរវាងឃុំ និងសហគមន៍នេសាទដ៏ទៃទៀតនៅក្នុងស្រុកព្រះនេត្រព្រះ គឺឃុំភ្នំលៀប និងឃុំប្រសាទ មានព្រៃលិចទឹកច្រើនជាងគេ។ ដោយសារទីតាំងព្រៃលិចទឹកស្ថិតនៅឆ្ងាយដាច់ស្រយាលពីភូមិដ្ឋានរួមទាំងការខ្វះខាតថវិកា និងមធ្យោបាយដើម្បីត្រួតពិនិត្យបទល្មើសកាប់ព្រៃលិចទឹក និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ធ្វើឱ្យគណៈកម្មការគ្រប់គ្រងសហគមន៍នេសាទទាំងបី មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការយាមល្បាតជាប្រចាំ បង្កឱ្យមានបទល្មើសកាប់ទន្ទ្រាន និងករណីភ្លើងឆេះព្រៃលិចទឹកកើតមានឡើងជារឿយៗ។

## ៣.២ ទិដ្ឋភាពភូមិសាស្ត្រ សេដ្ឋកិច្ច-សង្គម និងជីវៈចម្រុះ ក្នុងស្រុកមង្គលបូរី

### ៣.២.១ ទិដ្ឋភាពភូមិសាស្ត្រ និងសេដ្ឋកិច្ច-សង្គម ក្នុងស្រុកមង្គលបូរី

ស្រុកមង្គលបូរីស្ថិតនៅភាគអាគ្នេយ៍នៃខេត្តបន្ទាយមានជ័យ ចម្ងាយប្រហែល២៩គ.ម ពីក្រុងសេរីសោភ័ណ។ ស្រុកនេះមានព្រំប្រទល់ខាងជើងជាប់នឹងស្រុកអូរជ្រៅ ស្រុកព្រះនេត្រព្រះ និងក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ ខាងកើតជាប់នឹងស្រុកព្រះនេត្រព្រះ ខាងត្បូងជាប់នឹងស្រុកថ្មគោល និងស្រុកបវិល ខេត្តបាត់ដំបង និងខាងលិចជាប់នឹងមោង់ឬស្សី ខេត្តបាត់ដំបង។

ស្រុកមង្គលបូរីមានឃុំចំនួន១៣ និងភូមិចំនួន១៥៧ ដោយមានប្រជាពលរដ្ឋសរុបចំនួន១៧៧ ៧៥០នាក់ (ស្រី ៨៩ ៥០០នាក់) ស្មើនឹង៤១ ៩៨២គ្រួសារ ដែលក្នុងនោះមាន៧០ភាគរយ ប្រកបមុខរបរកសិកម្មជាចម្បងរួមមាន ដំណាំរយៈពេលខ្លី និងវែង (ស្រូវ ពោត សណ្ដែកបាយ សណ្ដែកដី ល្ង ដំឡូងមី អំពៅ កៅស៊ូ ស្វាយចន្ទី ស្វាយ ក្រូចពោធិ៍សាត់) ការចិញ្ចឹមសត្វ (គោ ក្របី ជ្រូក មាន់ និងទា) វារីវប្បកម្ម (ចិញ្ចឹមត្រី) និងប្រកបរបរនេសាទ (០,៣០ភាគរយ)។

ក្រៅពីនោះមានប្រជាពលរដ្ឋចំនួន២៩,៥០ភាគរយទៀត ប្រកបមុខរបរផ្ដល់សេវាកម្ម (បម្រើការងាររដ្ឋ/ក្រុមហ៊ុន/អង្គការក្រៅរដ្ឋាភិបាល ធ្វើជំនួញ ដឹកជញ្ជូន ជួសជុលគ្រឿងយន្ត និងគ្រឿងអគ្គិសនី កម្មករសំណង់ កម្មកររោងចក្រ ចំណាកស្រុកដើម្បីស្វែងរកការងារ ។ល។) និង១ភាគរយទៀត ពាក់ព័ន្ធនឹងវិស័យសិប្បកម្មដូចជា គ្រឿងសង្ហារឹម និងរូបចម្លាក់។

នៅក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ ស្រុកមង្គលបូរីមានផ្ទៃដីស្រែសរុបទំហំ៨១ ១៩១ហិកតា គិតទាំងស្រូវវស្សា ស្រូវប្រាំង ស្រូវប្រដេញទឹក និងស្រូវចំការ ក្នុងនោះមានដីស្រែប្រាំងទំហំ៣៦ ២៤៦ហិកតា ដែលមានទិន្នផលស្រូវជាមធ្យមប្រហែល៤តោន/ហិកតា និងដីស្រែវស្សាទំហំ១២ ០០៩ហិកតា ដែលមានទិន្នផលស្រូវជាមធ្យម១,៦០តោន/ហិកតា *(ប្រភពព័ត៌មាន៖ ឯកសារព័ត៌មានពីស្ថានភាពស្ដីពីសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០២១ ស្រុកមង្គលបូរី មន្ទីរផែនការខេត្តបន្ទាយមានជ័យ)*។

ផ្ទៃដីស្រែប្រាំងប្រហែល៨០ភាគរយ នៃផ្ទៃដីស្រែប្រាំងសរុបក្នុងស្រុកមង្គលបូរី ស្ថិតនៅខាងកើតផ្លូវជាតិលេខ៥ ក្នុងតំបន់២ និងតំបន់៣ ក្នុងនោះមានមួយចំនួនស្ថិតនៅក្នុងសហគមន៍នេសាទ។ ដីស្រែប្រាំងមួយចំនួនតូចក្នុងតំបន់២ មានប័ណ្ណកាន់កាប់កម្មសិទ្ធិដីធ្លី (ប្រកាស០១) ក្រៅពីនោះមិនទាន់មានប័ណ្ណកាន់កាប់នៅឡើយ។

ការធ្វើស្រូវប្រាំងនៅទីនោះពឹងផ្អែកទាំងស្រុងទៅលើការបូមទឹកស្ទឹងមង្គលបូរីដែលហូរពេញមួយឆ្នាំ តាមរយៈប្រព័ន្ធស្រោចស្រប់ប្រឡាយជើងក្អែប។ មុនឆ្នាំ២០១៣ ដីស្រូវប្រាំងមួយចំនួនត្រូវបានស្រោចស្រប់ដោយអាងទឹកចំនួន២ ដែលបានសាងសង់ក្នុងស្រុកព្រះនេត្រព្រះ ប៉ុន្តែក្នុងឆ្នាំ២០១៤ អាងទឹកទាំងពីរត្រូវបានរំលាយចោលដោយអាជ្ញាធរទន្លេសាប ដោយហេតុថា ការសាងសង់នេះមិនមានច្បាប់អនុញ្ញាត និងមានផលប៉ះពាល់ដល់ព្រៃលិចទឹក។

### ៣.២.២ ទិដ្ឋភាពជីវៈចម្រុះ និងភ្លើងឆេះព្រៃលិចទឹកក្នុងស្រុកមង្គលបូរី

ផ្អែកលើស្ថានភាពភូមិសាស្ត្រ និងជលសាស្ត្រ ស្រុកមង្គលបូរីស្ថិតនៅក្នុងទីជម្រាលស្ទឹងមង្គលបូរី ដែលមានកម្រិតជម្រាលជាមធ្យមតិចទាបជាង១០ភាគរយ នាំទឹកភ្លៀងហូរពីទិសខាងជើង និងខាងលិច ទៅទិសអាគ្នេយ៍ឆ្ពោះទៅកាន់បឹងទន្លេសាប ដូច្នេះធនធានជលផល ជាពិសេសព្រៃលិចទឹកភាគច្រើនមាននៅភាគអាគ្នេយ៍ ក្នុងភូមិសាស្ត្រឃុំសំបួរ ជាប់នឹងព្រំប្រទល់ស្រុកព្រះនេត្រព្រះនៃខេត្តបន្ទាយមានជ័យ និងស្រុកឯកភ្នំនៃខេត្តបាត់ដំបង ដែលមានរយៈកម្ពស់ទាបជាងឃុំដ៏ទៃទៀតនៅក្នុងស្រុកមង្គលបូរី។

ស្រុកមង្គលបូរីមានសហគមន៍នេសាទចំនួន០៧ គ្របដណ្ដប់លើផ្ទៃដីសរុបទំហំ១៩ ០១២ហិកតា ស្ថិតនៅក្នុងឃុំចំនួន០៤ គឺឃុំសំបួរ គយម៉ែង គោកបល្ល័ង្គ និងឃុំតាឡំ។ ស្រុកនេះនៅមានសហគមន៍ស្រះជម្រកត្រីចំនួន១៤ និងកន្លែងអភិរក្សជលផលរហាលស្ទឹងកំបុតដែលមានផ្ទៃដីទំហំ៧៨ហិកតា ស្ថិតនៅក្នុងអតីតឡូត៍នេសាទលេខ១។ ចំពោះវត្តមាននៃព្រៃលិចទឹក គឺមានតែនៅក្នុងកន្លែងអភិរក្សជលផល និងសហគមន៍នេសាទចំនួន៤ ក្នុងចំណោមសហគមន៍នេសាទទាំង៧។

នៅក្នុងឆ្នាំ២០២០ នាយកដ្ឋានអភិរក្សជលផលបានសាងសង់បង្គោលព្រំជុំវិញកន្លែងអភិរក្សជលផលរហាលស្ទឹងកំបុតចំនួន១៥បង្គោល ក្រោមការឧបត្ថម្ភថវិកាពីសហគមន៍អឺរ៉ុប តាមរយៈកម្មវិធី CAPFISH-Capture និងមានផែស្នាក់ការយាមអចិន្ត្រៃយ៍មួយដែលបានសាងសង់នៅក្នុងឆ្នាំ២០១៩។ ព្រៃលិចទឹកនៅក្នុងអភិរក្សជលផលនេះត្រូវបានការពារយ៉ាងតឹងរឹង មិនឱ្យមានការកាប់រានព្រៃលិចទឹកធ្វើកសិកម្ម និងភ្លើងឆេះព្រៃលិចទឹកកើតមានឡើង។

ឃុំសំបួរ ត្រូវបានកំណត់ជាឃុំគោលដៅពាក់ព័ន្ធនឹងដំណើរការគ្រប់គ្រងភ្លើងឆេះព្រៃនៅក្នុងស្រុកមង្គលបូរី ដោយសារមានករណីកាប់រានព្រៃលិចទឹក និងភ្លើងឆេះព្រៃលិចទឹកកើតមានឡើងបន្តបន្ទាប់ក្នុងឆ្នាំកន្លងមក ជាពិសេសនៅក្នុងសហគមន៍នេសាទទាំង៤។

## ៣.៣ ស្រុក និងឃុំគោលដៅនៃការគ្រប់គ្រងភ្លើងឆេះព្រៃ

ដោយផ្អែកលើស្ថានភាពភូមិសាស្ត្រ រូបសាស្ត្រ ភាពពាក់ព័ន្ធនឹងការប្រើប្រាស់ និងគ្រប់គ្រងធនធានជលផល និងលក្ខខណ្ឌការងារសម្រាប់ការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ដូចបានវិភាគជូនខាងលើ ខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យបានជ្រើសរើសឃុំគោលដៅចំនួន០៦ នៅក្នុងស្រុកចំនួន០២ សម្រាប់ការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដូចមានបញ្ជាក់ជូននៅក្នុងតារាងខាងក្រោម។

**តារាងទី២៖ ឃុំគោលដៅនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យ**

| ស្រុក/ក្រុងគោលដៅ | ឃុំគោលដៅ | |
|---|---|---|
| ១. ស្រុកមង្គលបូរី | ១ | ឃុំសំបួរ |
| ២. ស្រុកព្រះនេត្រព្រះ | ២ | ឃុំភ្នំលៀប |
| | ៣ | ឃុំរហាល |
| | ៤ | ឃុំឈ្នួរមានជ័យ |
| | ៥ | ឃុំប្រាសាទ |
| | ៦ | ឃុំព្រះនេត្រព្រះ |
| ២ ស្រុក | ៦ ឃុំ | |

## ៤. បញ្ហាប្រឈមនៃការគ្រប់គ្រងព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យ

ជាងមួយទសវត្សមកហើយ ភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់ទំនាបបឹងទន្លេសាប បានកើតឡើងជារៀងរាល់ឆ្នាំក្នុងទ្រង់ទ្រាយតូច និងធំ ហើយភាគច្រើនមិនអាចគ្រប់គ្រងបាន។ តាមសេចក្តីរាយការណ៍ពីសហគមន៍បានឱ្យដឹងថា គ្រប់ករណីនៃភ្លើងឆេះព្រៃលិចទឹកដែលកើតឡើងគឺ បណ្តាលមកពីសកម្មភាពដោយចេតនា និងអចេតនារបស់មនុស្ស។ ជាទម្លាប់ដ៏យូរលង់ណាស់មកហើយ ភ្លើងត្រូវបានគេប្រើជាមធ្យោបាយសម្រាប់ដុតសំអាតព្រៃដែលទើបនឹងកាប់ឆ្ការដើម្បីយកដីដាំដំណាំ សំអាតសំណល់ដំណាំនៅក្នុងដីស្រែ និងចំការក្រោយពេលប្រមូលផល ត្រួសត្រាយ និងដុតព្រៃគុម្ពោតដើម្បីដាក់ឧបករណ៍នេសាទ ចាប់សត្វ និងប្រមូលទឹកឃ្មុំ។

ភ្លើងឆេះព្រៃលិចទឹកដែលបានកើតកន្លងមក មានផលប៉ះពាល់អវិជ្ជមានដល់ធនធានជលផល រួមមាន ព្រៃលិចទឹក ស្មៅ និងព្រៃតាមមាត់អូរ/បឹង ដែលជាជម្រកដ៏សមស្រប និងមានសុវត្ថិភាពសម្រាប់បង្កាត់ពូជ ពងកូន និងចិញ្ចឹមជីវិតរបស់មច្ឆជាតិ ពពួកសត្វ ល្មូន និងសត្វស្លាប។ ផលប៉ះពាល់អវិជ្ជមានចុងក្រោយបំផុតគឺ ប្រភេទត្រីមួយចំនួនស្ទើរផុតពូជ ការថយចុះនូវទំហំ និងបរិមាណផលត្រីចាប់ និងការធ្លាក់ចុះនូវប្រាក់ចំណូលប្រចាំថ្ងៃរបស់ប្រជានេសាទ ដែលជាកត្តាបង្ខំឱ្យពួកគាត់បង្វែរមុខរបរពីការនេសាទទៅធ្វើកសិកម្មវិញ ហើយឈានទៅដល់ការឈូសឆាយព្រៃលិចទឹកយកដីធ្វើស្រូវប្រាំង និងដាំដំណាំផ្សេងៗទៀតតាមតម្រូវការទីផ្សារ។

តាមរយៈកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ ស្រុក និងខេត្ត មូលហេតុសំខាន់ៗដែលបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកត្រូវបានកំណត់ ដូចមានរៀបរាប់ជូនខាងក្រោមនេះ។

### ៤.១ មូលហេតុនៃភ្លើងឆេះព្រៃលិចទឹក

ផ្អែកលើរបាយការណ៍ដែលចងក្រងដោយក្រុមការងារ ដែលមានសមាសភាពមកពីនាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល នៃរដ្ឋបាលជលផល ទទួលបន្ទុកការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យ ក្រោយពីកិច្ចប្រជុំលើកទី១ នៅក្នុងឃុំគោលដៅទាំង៦ បានបញ្ជាក់អំពីមូលហេតុសំខាន់ៗនៃភ្លើងឆេះព្រៃលិចទឹកនៅរដូវប្រាំង ក្នុងនេះគឺបណ្តាលមកពី៖

- ការដុតគល់ជញ្ជ្រាំង ឬស្មៅនៅក្នុងដីស្រែដើម្បីបង្កើនជី និងសំអាតដីមុនពេលភ្ជួររាស់ ធ្វើឱ្យភ្លើងរាលដាលឆេះរាលស្មៅ ឬព្រៃលិចទឹកដែលនៅក្បែរនោះដោយអចេតនា
- ការដុតព្រៃលិចទឹក និងព្រៃគុម្ពោតដែលទើបនឹងបានកាប់ឆ្ការ ក្នុងគោលបំណងពង្រីកផ្ទៃដីស្រែ និងចំការ ការកាប់ឆ្ការ និងដុតព្រៃគុម្ពោតដើម្បីបើកធ្លាដាក់ឧបករណ៍នេសាទ "បរ"
- ការចំអិនអាហារដោយមិនបានពន្លត់ភ្លើងមុនពេលចាកចេញដោយអ្នកនេសាទ អ្នកប្រមាញ់សត្វ អ្នករកអុស អ្នកយកទឹកឃ្មុំ និងក្រុមអ្នកឃ្វាលគោ-ក្របី
- ការបោះចោលកន្ទុយបារីដោយមិនបានពន្លត់ ទៅក្នុងស្មៅ ព្រៃគុម្ពោត និងគំនរសរីរាង្គស្ងួត ដែលជាសកម្មភាពធ្វេសប្រហែសរបស់អ្នកជក់បារី បានបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកជាញឹកញាប់ ជាពិសេសនៅតាមដងផ្លូវធ្វើដំណើរក្នុងតំបន់ទំនាបព្រៃលិចទឹក
- ការប្រើភ្លើង និងផ្សែងដើម្បីប្រមូលទឹកឃ្មុំនៅរដូវប្រាំង ប៉ុន្តែដោយសារការធ្វេសប្រហែស ភ្លើងបានរាលដាលក្នុងទ្រង់ទ្រាយធំ មិនអាចគ្រប់គ្រងបាន ឆេះបំផ្លាញព្រៃលិចទឹក និងវាលស្មៅ
- ការប្រែប្រួលអាកាសធាតុ ជាពិសេសការអូសបន្លាយនៃភាពរាំងស្ងួតក្នុងរដូវប្រាំង បានបន្តភាពស្ងួតសំណល់រុក្ខជាតិនៅលើស្រទាប់ដី បង្កើនភាពដែលអាចកើតមានឡើងនូវភ្លើងឆេះព្រៃលិចទឹក។

មូលហេតុដែលបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹកដូចបានរៀបរាប់ខាងលើ គឺជាសកម្មភាពរបស់មនុស្សដែលបានប្រព្រឹត្តទៅដោយចេតនា អចេតនា និងការធ្វេសប្រហែស ចំពោះការប្រើប្រាស់ភ្លើងនៅក្នុងតំបន់ទំនាបព្រៃលិចទឹក។

ព័ត៌មានលម្អិតអំពីឫសគល់នៃមូលហេតុទាំងអស់នេះ ត្រូវបានគេស្រាវជ្រាវឱ្យកាន់តែស៊ីជម្រៅសម្រាប់ប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការវិភាគ ការបកស្រាយ និងការកំណត់សកម្មភាពសមស្រប ដើម្បីដោះស្រាយបញ្ហាភ្លើងឆេះព្រៃលិចទឹកនៅក្នុងទីតាំងជាក់លាក់ក្នុងឃុំគោលដៅឱ្យមានប្រសិទ្ធភាព។

រាល់មូលហេតុ និងបញ្ហានៃភ្លើងឆេះព្រៃលិចទឹកដែលបានលើកឡើងដោយអ្នកពាក់ព័ន្ធ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកសម្រាប់ខេត្តបន្ទាយមានជ័យ ដើម្បីធានាថា បញ្ហាទាំងអស់នឹងត្រូវបានដោះស្រាយដោយជោគជ័យនៅក្នុងរយៈពេល៥ឆ្នាំនៃការអនុវត្តផែនការនេះ។

## ៤.២ ទីតាំងភ្លើងឆេះព្រៃលិចទឹក

ផ្អែកលើផែនទីភ្លើងឆេះព្រៃលិចទឹកនៅក្នុងខេត្តបន្ទាយមានជ័យ ដែលបានរៀបចំដោយរដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ បានបង្ហាញឱ្យដឹងថា ទីតាំងភ្លើងឆេះព្រៃលិចទឹកចំនួន០៦កន្លែង មានផ្ទៃសរុបទំហំ២៤៥ហិកតា ស្ថិតនៅក្នុងឃុំគោលដៅទាំង៦ នៃស្រុកទាំង២ ដូចមានបញ្ជាក់ជូននៅក្នុងតារាងខាងក្រោមនេះ។

**តារាងទី៣៖ បញ្ជីឈ្មោះទីតាំង និងផ្ទៃដីព្រៃលិចទឹកដែលបានឆេះនៅក្នុងខេត្តបន្ទាយមានជ័យ**

| ល.រ | ឈ្មោះទីតាំង | ឃុំ | ពេលវេលាឆេះ | ផ្ទៃដីព្រៃឆេះ (ហ.ត) | ប្រភេទព្រៃដែលឆេះ | មូលហេតុនៃ | | ស្ថានភាពដំណុះធម្មជាតិ |
|---|---|---|---|---|---|---|---|---|
| | | | | | | ការឆេះព្រៃ | ការរលត់ | |
| ស្រុកមង្គលបូរី | | | | | | | | |
| ១ | វាលអារបង (បឹងអារបង) | សំបូរ | មេសា ២០១៧ (២ថ្ងៃ) | ១៥ | ព្រៃគុម្ពោត | មិនដឹងមូលហេតុ | រលត់ខ្លួនឯងដោយសារទីតាំងព្រៃនៅដាច់ពីគ្នា | ដុះវិញបានកម្ពស់ប្រហែល១ម |
| | | | មេសា ២០២០ (២ថ្ងៃ) | ១០ | ព្រៃគុម្ពោត | មិនដឹងមូលហេតុ | រលត់ខ្លួនឯងដោយសារទីតាំងព្រៃនៅដាច់ពីគ្នា | ដុះវិញបានកម្ពស់ប្រហែល១ម |
| ២ | អាងតាម៉ាក់ | សំបូរ | មេសា ២០១៦ (៤-៥ថ្ងៃ) | ១០០ | ព្រៃគុម្ពោត | ដុតចាប់សត្វព្រៃ | រលត់ដោយខ្លួនឯង | ដុះវិញបានកម្ពស់ប្រហែល១ម |
| | | | ឧសភា២០២០ (១ថ្ងៃ) | ២០ | ព្រៃគុម្ពោត | ដុតចាប់សត្វព្រៃ | រលត់ដោយខ្លួនឯង | ដុះវិញបានកម្ពស់ប្រហែល១ម |
| ស្រុកព្រះនេត្រព្រះ | | | | | | | | |
| ៣ | ទំនប់តាសោម | ភ្នំលាប | មេសា ២០២០ (១ថ្ងៃ) | ១០ | ព្រៃគុម្ពោត | រានដុតព្រៃធ្វើស្រែប្រាំង | រលត់ដោយខ្លួនឯង | ក្លាយជាវាលស្រែប្រាំង |
| ៤ | ព្រៃក្រចាប់ (មុខកំព្រឹង) | ភ្នំលាប | មេសា ២០១៦ (៣ថ្ងៃ) | ៦០ | ព្រៃគុម្ពោតនិងវាលស្មៅ | - ចំអិនអាហារ<br>- យកទឹកឃ្មុំ | រលត់ដោយខ្លួនឯង | ព្រៃគុម្ពោតដុះដោយខ្ទែង (កម្ពស់២ម) |
| ៥ | ព្រៃក្រចាប់ (ខាងលិចស្ទឹង) | រហាល | មិនា ២០១៨ | | | | | |
| ៦ | ក្បាលអាឈូន (រហាលកំព្រឹង) | រហាល | មេសា ២០១៩ (៣ថ្ងៃ) | ៣០ | ព្រៃគុម្ពោត | ឆេះឆ្លងពីចំនុចអាឈូន (បាត់ដំបង) | អន្តរាគមន៍ពីក្រុមការងារដឹកនាំដោយអភិបាលស្រុក | ព្រៃគុម្ពោតដុះលាយស្មៅ |
| | ៦ ទីតាំង | | | ២៤៥ | | | | |

## ៤.៣ ស្ថាប័ន/អង្គភាពពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក

ព្រៃលិចទឹក ព្រៃគុម្ពោត/រនាម វារីជាតិ វាលស្មៅ វាលទំនាប ប្រព័ន្ធផ្លូវទឹក និងតំបន់ដីសើម មានសារៈសំខាន់សម្រាប់ជីវិតសត្វ រុក្ខជាតិដែលអាចរស់នៅលើដី និងក្នុងទឹក ជីវៈចម្រុះនៃអាងទន្លេសាបដែលមានសារៈប្រយោជន៍សម្រាប់ការរស់នៅ និងការចិញ្ចឹមជីវិតរបស់មនុស្ស ដូចជាការផ្តល់ប្រភពអាហារដែលមានប្រូតេអ៊ីនខ្ពស់ ប្រភពចំណូលប្រចាំគ្រួសារ និងជាផ្នែកមួយជួយគាំទ្រដល់សេដ្ឋកិច្ចជាតិផងដែរ។

ដោយសារតែសក្តានុពលនៃធនធានជលផល ជាពិសេសព្រៃលិចទឹកក្នុងតំបន់ទំនាបបឹងទន្លេសាប ដែលផ្តល់សារប្រយោជន៍ដោយផ្ទាល់ និងប្រយោលចំពោះប្រជាពលរដ្ឋជាច្រើន ដែលរស់នៅក្នុងតំបន់នោះ ទើបពួកគាត់ត្រូវបានកំណត់ជាអ្នកពាក់ព័ន្ធក្នុងការចូលរួមការពារ ថែរក្សា និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក។ យោងតាមលទ្ធផលនៃការសិក្សាបានកំណត់ អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការចូលរួមជាមួយសហគមន៍មូលដ្ឋានដើម្បីការពារ និងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក ដូចមានភ្ជាប់ក្នុងតារាងខាងក្រោម៖

**តារាងទី៤៖ ស្ថាប័ន អង្គភាពពាក់ព័ន្ធនឹងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក**

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | ការកាត់បន្ថយហានិភ័យ | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| ប្រជាពលរដ្ឋក្នុងមូលដ្ឋាន | តាមដានព័ត៌មានស្តីពីការព្យាករណ៍អាកាសធាតុដែលទាក់ទងនឹងការអូសបន្លាយរដូវប្រាំង និងការ ពន្យាពេលរដូវវស្សា។ | កាត់បន្ថយការចេញ-ចូលទៅក្នុងតំបន់ព្រៃលិចទឹក។ | ផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក និងផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិចទឹកដល់ជីវៈចម្រុះ អេកូឡូស៊ីសត្វព្រៃ និងជីវភាពរស់នៅរបស់មនុស្ស។ | ចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>គាំទ្រមធ្យោបាយ និងសម្ភារពន្លត់ភ្លើងឆេះព្រៃលិចទឹក (គោយន្ត ត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ធុងទឹក ។ល។) តាមដែលអាចធ្វើទៅបាន។ | សហការរួមគ្នាដាំកូនឈើព្រៃលិចទឹកនៅក្នុងទីតាំងព្រៃលិចទឹកដែលខូចខាតដោយភ្លើងឆេះ និងការកាប់រានធ្វើកសិកម្ម ការពារ និងថែរក្សាដំណុះរុក្ខជាតិ និងកូនឈើដែលបានដាំថែទាំបង្គោល និងស្លាកសញ្ញាដែលដាក់នៅតាមព្រំប្រទល់តំបន់ស្តារព្រៃលិចទឹក។ |
| ប្រជាការពារភូមិ | សិក្សា និងអង្កេតអត្ត-សញ្ញាណកម្មមនុស្សចេញចូលក្នុងតំបន់ព្រៃលិចទឹក។ | ចូលរួមក្នុងការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក និងផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃ និងជួយផ្សព្វផ្សាយបន្ត<br>ចូលរួមក្នុងការពង្រឹងការអនុវត្តច្បាប់ជលផល។ | ផ្តល់សម្ភារល្បាតនិងពន្លត់ភ្លើងឆេះព្រៃដល់ក្រុមល្បាត<br>អនុវត្តការល្បាត និងត្រួតពិនិត្យភ្លើងឆេះព្រៃដោយមានការចូលរួម។ | កៀរគរប្រជាពលរដ្ឋចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>ចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>គាំទ្រមធ្យោបាយ និងសម្ភារពន្លត់ភ្លើងឆេះព្រៃលិចទឹក (គោយន្ត ត្រាក់ទ័រ ម៉ាស៊ីនបូមទឹក ធុងទឹក ទុយោ ។ល។) ដែលអាចធ្វើទៅបាន។ | ចូលរួមក្នុងការដាំ ការពារ និងថែទាំកូនឈើព្រៃលិចទឹកក្នុងតំបន់ស្តារព្រៃលិចទឹក<br>ចូលរួមបោះ និងថែរក្សាបង្គោលព្រំ និងស្លាកសញ្ញានៅតាមព្រំប្រទល់តំបន់ស្តារព្រៃលិចទឹក។ |
| សហគមន៍នេសាទ | កត់ត្រាឈ្មោះមនុស្ស និងគោលបំណងនៃការចេញចូលក្នុងតំបន់ទំនាបព្រៃលិចទឹកនៅក្នុងរដូវប្រាំងនៅក្នុងដែនគ្រប់គ្រងរបស់សហគមន៍។ | ចូលរួមក្នុងការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក និងផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិចទឹក។ | ចូលរួមក្នុងការស្តារបឹង/អូរ រក្សាទឹកសម្រាប់ពន្លត់ភ្លើងឆេះព្រៃ<br>បោះបង្គោលព្រំទីតាំងដែលប៉ះពាល់ដោយភ្លើងឆេះដើម្បីស្តារឡើងវិញ។ | ចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>កៀរគរឱ្យប្រជាពលរដ្ឋចូលរួម និងគាំទ្រមធ្យោបាយ សម្ភារពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | ចូលរួមក្នុងការដាំ ការពារ និងថែទាំកូនឈើព្រៃលិចទឹកក្នុងតំបន់ស្តារព្រៃលិចទឹក<br>ចូលរួមបោះ និងថែរក្សាបង្គោលព្រំ និងស្លាកសញ្ញានៅតាមព្រំប្រទល់តំបន់ស្តារព្រៃលិចទឹក។ |
| ក្រុមប្រឹក្សាឃុំ | សិក្សា និងអង្កេតអត្តសញ្ញាណកម្មមនុស្សដែលចេញចូលតំបន់ព្រៃលិចទឹក។ | ផ្សព្វផ្សាយពីវិធានការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក និងផ្តល់សម្ភារជូនក្រុមល្បាត<br>បញ្ជូនកម្លាំងគាំទ្រក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកតាមការស្នើរបស់ | បម្រុងថវិកាមូលនិធិឃុំ/សង្កាត់មួយចំនួនសម្រាប់ចំណាយលើការពន្លត់ភ្លើងឆេះព្រៃលិចទឹក (ប្រេងឥន្ធនៈ សម្ភារ ស្តារបឹង/អូរ...)<br>ជួសជុល និងត្រៀម | កៀរគរប្រជាពលរដ្ឋចូលរួម និងគាំទ្រមធ្យោបាយ សម្ភារដើម្បីពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>ចូលរួមចាត់ចែងពន្លត់ភ្លើងឆេះព្រៃ | ចូលរួមសហការដាំកូនឈើព្រៃលិចទឹកនៅក្នុងតំបន់ភ្លើងឆេះព្រៃលិចទឹក<br>គាំទ្រថវិកាក្នុងការផលិត និងដាក់ស្លាកសញ្ញាការពារព្រៃលិចទឹក |

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | ការកាត់បន្ថយហានិភ័យ | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| | | ក្រុមល្បាត<br>ពង្រឹងការអនុវត្តច្បាប់ជលផលដោយផ្អែកទៅលើអនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការតួនាទីអំណាច និងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់។ | ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកសម្រាប់តម្រូវការបន្ទាន់។ | ប្រមូលផ្តុំ និងបញ្ជូនឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកទៅកន្លែងកើតហេតុនៅពេលមានសំណើពីក្រុមល្បាត។ | ផ្សព្វផ្សាយអំពីការការពារ និងថែទាំតំបន់ស្តារព្រៃលិចទឹកដល់ប្រជា ពលរដ្ឋ។ |
| សង្គមស៊ីវិល | សិក្សាអំពីស្ថានភាពព្រៃលិចទឹក និងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ទំនាបព្រៃលិចទឹក ដើម្បីរៀបចំផែនការគាំទ្រការអនុវត្តផែនការគ្រប់គ្រងព្រៃលិចទឹករបស់រដ្ឋបាលជលផល និងក្រសួង បរិស្ថាន។ | ផលិតសម្ភារ និងជួយផ្សព្វផ្សាយអំពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិចទឹក និងបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។ | ផ្តល់ថវិកា និងធនធានមនុស្សដើម្បីគាំទ្រវគ្គបណ្តុះបណ្តាលស្តីពីវិធានការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដល់ក្រុមល្បាត។ | គាំទ្រថវិកា និងភស្តុភារ តាមដែលអាចធ្វើបាន។ | គាំទ្រថវិកា និងចូលរួមក្នុងការពារ ថែទាំ និងដាំកូនឈើព្រៃលិចទឹកក្នុងតំបន់ស្តារព្រៃលិចទឹក។ |
| នគរបាលប៉ុស្តិ៍រដ្ឋបាល និងអធិការនគរបាលស្រុក | រៀបចំបញ្ជីឈ្មោះម្ចាស់ត្រាក់ទ័រ សត្វពាហនៈស្រែ-ចំការ និងអ្នកស្នាក់អាស្រ័យបណ្តោះអាសន្ននៅក្នុងតំបន់៣ ដើម្បីងាយស្រួលក្នុងការស្វែងរកអត្ត-សញ្ញាណកម្មជនសង្ស័យដែលបង្កភ្លើងឆេះព្រៃ។ | សហការជាមួយខណ្ឌរដ្ឋបាលជលផល ហាមឃាត់ និងត្រួតពិនិត្យយ៉ាងតឹងរឹងនូវការប្រើប្រាស់ដី និងព្រៃលិចទឹកនៅក្នុងតំបន់៣។ | រៀបចំ ត្រៀមកម្លាំង និងរថយន្តពន្លត់អគ្គិភ័យដើម្បីគាំទ្រការពន្លត់ភ្លើងឆេះព្រៃលិចទឹកជាបន្ទាន់។ | គាំទ្រ និងចូលរួមក្នុងការល្បាតភ្លើងឆេះព្រៃលិចទឹក<br>ផ្តល់មធ្យោបាយ និងសម្ភារសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | គាំទ្រ និងចូលរួមក្នុងការដាំកូនឈើព្រៃលិចទឹក។ |
| រដ្ឋបាលស្រុក | ប្រមូល និងរក្សាទុកឯក-សារនិងទិន្នន័យដែលទាក់ទងនឹងការគ្រប់គ្រងព្រៃលិចទឹក<br>ចេញសេចក្តីប្រកាស ឬការណែនាំអំពីការគ្រប់គ្រងព្រៃលិចទឹក រួមទាំងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ | ផ្សព្វផ្សាយពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់បណ្តាលពីភ្លើងឆេះព្រៃ និងបទដ្ឋានច្បាប់ ពាក់ព័ន្ធ រួមទាំងច្បាប់ស្តីពីជលផល។ | សហការជាមួយខណ្ឌរដ្ឋបាលជលផលផ្តល់គ្រូបង្គោលនៃក្រុមពន្លត់អគ្គិភ័យសម្រាប់វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | បញ្ជូនសម្ភារពន្លត់អគ្គិភ័យ និងមន្ត្រីឱ្យចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | ចូលរួមក្នុងការដាំកូនឈើព្រៃលិចទឹក និងជំរុញឱ្យអាជ្ញាធរភូមិ ឃុំ ជួយការពារ និងថែរក្សាតំបន់ស្តារព្រៃលិចទឹក។ |
| មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ត្រួតពិនិត្យរបាយការណ៍ភ្លើងឆេះព្រៃលិចទឹក ដែលរៀបចំដោយខណ្ឌរដ្ឋបាលជលផលដើម្បីផ្តល់អនុសាសន៍ និងចាត់វិធានការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកឱ្យមានប្រសិទ្ធិ-ភាព។ | គាំទ្រការផ្សព្វផ្សាយស្តីពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃ លិចទឹក និងបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក<br>គាំទ្រ និងពង្រឹងការអនុវត្តច្បាប់។ | រាយការណ៍ជូនអភិបាលនៃគណៈអភិបាលខេត្តអំពីបញ្ហាភ្លើងឆេះព្រៃលិចទឹក ដើម្បីឱ្យអង្គភាពពាក់ព័ន្ធនៅថ្នាក់ខេត្តត្រៀមជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | ចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងស្នើសុំកម្លាំងអន្តរាគមន៍ពីអភិបាលនៃគណៈអភិបាលខេត្ត និងស្រុក។ | ចូលរួម និងគាំទ្រការដាំកូនឈើ និងជំរុញឱ្យអាជ្ញាធរភូមិ ឃុំ ស្រុក ជួយការពារ និងថែរក្សាទីតាំងស្តារព្រៃលិចទឹកឡើងវិញ។ |
| អង្គភាពពាក់ព័ន្ធនៅថ្នាក់ខេត្ត | កំណត់អង្គភាពពាក់ព័ន្ធ និងរៀបចំគោលនយោ-បាយគាំទ្រការងារគ្រប់គ្រងភ្លើងឆេះព្រៃ | ជួយផ្សព្វផ្សាយអំពីការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដល់អង្គភាពពាក់ព័ន្ធ | ត្រៀមកម្លាំង មធ្យោ-បាយ និងសម្ភារពន្លត់ភ្លើងឆេះព្រៃលិចទឹក ដើម្បីធ្វើអន្តរាគមន៍ជា | បញ្ជូនមធ្យោបាយពន្លត់អគ្គិភ័យ និងកម្លាំងចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃលិច | ចូលរួមក្នុងពិធីដាំកូនឈើព្រៃលិចទឹក<br>គាំទ្រថវិកាក្នុងការស្តារព្រៃលិចទឹក។ |

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | ការកាត់បន្ថយហានិភ័យ | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| | លិចទឹក។ | ចាត់វិធានការដល់រូបវន្តបុគ្គល និងនិតិបុគ្គលដែលបានបំផ្លាញព្រៃលិចទឹក តាមនិតិវិធីច្បាប់។ | បន្ទាន់<br>ផ្តល់សម្ភារពន្លត់ភ្លើងឆេះព្រៃលិចទឹកដល់ក្រុមល្បាត និងសហគមន៍នេសាទ។ | ទឹក។ | |
| អាជ្ញាធរទន្លេសាប | សិក្សាអំពីស្ថានភាពព្រៃលិចទឹក និងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ទំនាបព្រៃលិចទឹក ដើម្បីរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងព្រៃលិចទឹក។<br>ត្រួតពិនិត្យបង្គោលព្រំប្រទល់តំបន់៣ និងបោះបង្គោលបន្ថែមនៅទីតាំងដែលគម្លាតពីបង្គោល១ ទៅបង្គោល១ទៀតស្ថិតនៅឆ្ងាយពីគ្នាពេក។ | ផលិតសម្ភារ និងរៀបចំការផ្សព្វផ្សាយ ពីសារៈសំខាន់ព្រៃលិចទឹក ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកដល់មនុស្ស សត្វ ជីវៈចម្រុះ និងអេកូឡូស៊ីនៃទំនាប់បឹងទន្លេសាប។ | ផ្តល់សម្ភារពន្លត់ភ្លើងឆេះព្រៃដល់ក្រុមល្បាតភ្លើងឆេះព្រៃ និងសហគមន៍នេសាទ។ | ចូលរួមអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក។ | ចូលរួម និងគាំទ្រការដាំកូនឈើ និងជំរុញឱ្យអង្គភាពពាក់ព័ន្ធជួយការពារ និងថែរក្សាទីតាំងស្តារព្រៃលិចទឹក។ |
| រដ្ឋបាលជលផល និងខណ្ឌរដ្ឋបាលជលផល | ប្រមូល និងរក្សាទុកឯកសារដែលទាក់ទងនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម និងកំណត់អំពីមូលហេតុ ទំហំនៃការខូចខាត វិធីសាស្ត្រពន្លត់ភ្លើងឆេះព្រៃលិចទេក និងផែនទីភ្លើងឆេះព្រៃលិចទឹក<br>ចុះត្រួតពិនិត្យព្រៃលិចទឹកដាំទៀងទាត់ដើម្បីធ្វើបច្ចុប្បន្នភាពស្ថានភាពព្រៃលិចទឹក<br>សិក្សាស្រាវជ្រាវ និងចងក្រងឯកសារ អំពីធនធានជលផល អេកូឡូស៊ី និងការចិញ្ចឹមជីវិតនៅក្នុងតំបន់ព្រៃលិចទឹកជាពិសេសនៅក្នុងតំបន់៣។ | ផលិតសម្ភារ និងរៀបចំការផ្សព្វផ្សាយ ស្តីពីសារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិចទឹក និងបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។<br>ពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល។ | សម្របសម្រួល និងគាំទ្រសកម្មភាពល្បាតភ្លើងឆេះព្រៃលិចទឹក<br>សម្របសម្រួលនិងស្វែងរកថវិកាសម្រាប់គាំទ្រសកម្មភាពទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក<br>ផ្តល់សម្ភារ មធ្យោបាយ និងត្រួតពិនិត្យការប្រើប្រាស់ និងថែរក្សាសម្ភារពន្លត់ភ្លើងឆេះព្រៃលិចទឹកសម្រាប់តម្រូវការ បន្ទាន់។ | ដឹកនាំ និងសម្របសម្រួលពន្លត់ភ្លើងឆេះព្រៃលិចទឹក<br>រាយការណ៍ទៅអង្គភាព ពាក់ព័ន្ធ ដើម្បីស្នើសុំកិច្ចអន្តរាគមន៍ បន្ទាន់។<br>ស៊ើបអង្កេត តាមដានស្រាវជ្រាវ និងកសាងសំណុំរឿងទៅតាមនីតិវិធីច្បាប់ស្តីពីជលផល។ | រៀបចំ ដាំកូនឈើព្រៃលិចទឹកឡើងវិញ<br>ការពារ និងថែរក្សាកូនឈើព្រៃលិចទឹកបានដាំ និងទីកន្លែងព្រៃលិចទឹកដែលបានឆេះ<br>វាយតម្លៃអត្រារស់ និងលូតលាស់របស់កូនឈើនៅក្នុងទីកន្លែងស្តារព្រៃលិចទឹក។ |
| ក្រសួងបរិស្ថាន | ធ្វើការសិក្សាស្តីពីប្រព័ន្ធអេកូឡូស៊ី និងការចិញ្ចឹមជីវិតនៅក្នុងតំបន់ទំនាបព្រៃលិចទឹក ដើម្បីរៀបចំផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកសម្រាប់តំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាបដោយផ្សារភ្ជាប់ទៅនឹងផែនការទប់ស្កាត់និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹករបស់រដ្ឋបាលជលផល។ | ផលិតសម្ភារ និងធ្វើការផ្សព្វផ្សាយស្តីពីសារៈសំខាន់ព្រៃលិចទឹក ផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិចទឹក ច្បាប់ស្តីពីតំបន់ការពារ និងបទដ្ឋានគតិយុទ្ធពាក់ព័ន្ធនឹងការគ្រប់គ្រងព្រៃលិចទឹក។ | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសល្បាតដល់មន្ត្រីឧទ្យានុរក្សនិងសហគមន៍តំបន់ការពារធម្មជាតិ<br>ផ្គត់ផ្គង់ និងត្រួតពិនិត្យការប្រើប្រាស់ និងការថែទាំឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ សម្រាប់តម្រូវការបន្ទាន់។ | ចាត់កម្លាំងមន្ត្រីឧទ្យានុរក្សឱ្យចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃដែលកើតមានទាំងនៅក្នុង និងក្រៅ ឋបនីយជីវមណ្ឌល<br>ជូនដំណឹងឱ្យមន្ទីរបរិស្ថានតាមដាន និងចូលរួមនៅក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកទៅតាមសំណើពី | ចូលរួមដាំកូនឈើ និងថែទាំទីកន្លែង ស្តារព្រៃលិចទឹកនៅក្នុង និងក្រៅតំបន់រ៉ាមសារ និងឋបនីយជីវមណ្ឌលបឹងទន្លេសាប។ |

| អ្នកពាក់ព័ន្ធ | ការពិនិត្យឡើងវិញ | ការកាត់បន្ថយហានិភ័យ | ការត្រៀមទុកជាមុន | ការឆ្លើយតប | ការស្តារ |
|---|---|---|---|---|---|
| | | | | រដ្ឋបាលខេត្ត។ | |

ការកំណត់អត្តសញ្ញាណរបស់អ្នកពាក់ព័ន្ធ គឺជាការចាំបាច់មិនអាចខ្វះបាន សម្រាប់ការរៀបចំផែនការដែលគិតអំពីក្រុមគោលដៅ និងការចូលរួមរបស់ពួកគាត់នៅក្នុងដំណាក់កាលផ្សេងៗគ្នា (ការទប់ស្កាត់ ការពន្លត់ភ្លើងឆេះព្រៃ និងការស្តារព្រៃលិចទឹក) នៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដែលបានលើកឡើងនៅក្នុងផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹករយៈពេល៥ឆ្នាំ។

អ្នកពាក់ព័ន្ធនឹងការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹករួមមាន៖ ក្រុមដែលសង្ស័យថាបានបង្កឱ្យមានភ្លើងឆេះព្រៃ សហគមន៍នេសាទ ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក អ្នកប្រើប្រាស់ធនធានជលផល ប្រជាកសិករ អ្នកនេសាទ អាជ្ញាធរមូលដ្ឋាន មន្ត្រីរាជការ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃថ្នាក់ស្រុក និងខេត្ត។

## ៤.៤ បញ្ហាប្រឈមក្នុងការចាត់វិធានការពន្លត់ភ្លើងឆេះព្រៃលិចទឹក

យោងតាមប្រវត្តិនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅក្នុងខេត្តបន្ទាយមានជ័យ បានបង្ហាញឱ្យដឹងថា រហូតមកដល់បច្ចុប្បន្ន មិនទាន់មានរចនាសម្ព័ន្ធគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ស្រុក ឬឃុំត្រូវបានបង្កើតឡើងដើម្បីដោះស្រាយបញ្ហាភ្លើងឆេះព្រៃលិចទឹកនៅឡើយ។ បញ្ហាប្រឈមទាំងនេះគឺបណ្តាលមកពីកត្តា និងបុព្វហេតុមួយចំនួនដូចខាងក្រោមនេះ៖

- **<u>មិនមានយន្តការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក</u>**៖ ភ្លើងឆេះព្រៃលិចទឹកកើតមានឡើងជារៀងរាល់ឆ្នាំ និងជាច្រើនទស្សវត្សមកហើយ ជាពិសេសនៅក្នុងទស្សវត្សទី២០ និងទី២១ ខណៈពេលដែលតម្លៃដីបានឡើងខ្ពស់។ តាមការរាយការណ៍ដោយសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានទៅសង្កាត់រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋានភូមិ ឃុំ ស្រុក និងសមត្ថកិច្ចជំនាញពាក់ព័ន្ធ ដើម្បីស្វែងរកអន្តរាគមន៍សម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹកផងដែរ ប៉ុន្តែមានការអន្តរាគមន៍មួយចំនួនប៉ុណ្ណោះ។ នេះប្រហែលជាបណ្តាលមកពីការមិនមានយន្តការគ្រប់គ្រងភ្លើងឆេះព្រៃបានបង្កើតនៅថ្នាក់ឃុំ ឬស្រុក ដើម្បីត្រៀមកម្លាំង សម្ភារ និងថវិកាសម្រាប់ការទប់ស្កាត់ និងការពន្លត់ភ្លើងឆេះព្រៃលិចទឹកឱ្យបានទាន់ពេលវេលា។
- **<u>មិនមានផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក</u>**៖ ដោយសារអវត្តមាននៃយន្តការ ឬក្រុមចម្រុះដែលមានភាគីពាក់ព័ន្ធសំខាន់ៗបានបង្កើតឡើងសម្រាប់ការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ដូច្នេះផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក មិនត្រូវបានបង្កើត ធ្វើឱ្យភ្លើងឆេះព្រៃនៅតែកើតមានឡើង និងពិបាកក្នុងការគ្រប់គ្រង។ កន្លងមក ទោះបីជាមានការខិតខំប្រឹងប្រែងពីសហគមន៍នេសាទ ដើម្បីពន្លត់ភ្លើងឆេះព្រៃលិចទឹកនៅក្នុងដែនគ្រប់គ្រងរបស់ខ្លួនក៏ដោយ ក៏មិនសូវទទួលបានជោគជ័យច្រើនដែរ ដោយហេតុថាមិនមានកម្លាំងត្រៀម និងគ្មានឧបករណ៍ពន្លត់ភ្លើងឆេះព្រៃគ្រប់គ្រាន់។
- **<u>ចំណេះដឹងសហគមន៍អំពីច្បាប់ទាក់ទងភ្លើងឆេះព្រៃ និងផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹក</u>**៖ ប្រជាពលរដ្ឋមូលដ្ឋានភាគច្រើនយល់ដឹងអំពីច្បាប់ដែលទាក់ទងនឹងការនេសាទខុសច្បាប់ ដោយសារកន្លងមកមានការប្រជុំលើកកម្ពស់ការយល់ដឹងអំពីប្រធានបទនេះជាច្រើនលើក ដែលបានរៀបចំនៅមូលដ្ឋាន និងការចែករំលែកព័ត៌មានជាសាធារណៈតាមរយៈផ្ទាំងរូបភាព និងស្លាកសញ្ញាផ្សព្វផ្សាយ វិទ្យុ ទូរទស្សន៍ ប្រព័ន្ធផ្សព្វផ្សាយសង្គមដូចជា ហ្វេសប៊ុក និងតេឡេក្រាម ។ល។ ហេតុដូច្នេះហើយ ប្រជាសហគមន៍ហាក់ដូចជាមានការយល់ដឹងតិចតួចអំពីបទដ្ឋានច្បាប់ដែលពាក់ព័ន្ធនឹងភ្លើងឆេះព្រៃលិចទឹក។

ដោយសារការដឹងអំពីការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅមានកម្រិត ទើបនៅពេលដែលប្រជាកសិករ ឬប្រជានេសាទបានជួបប្រទះនឹងភ្លើងឆេះព្រៃដែលកំពុងកើតឡើង ហើយគាត់មាន

បំណាងចង់ពន្លត់ភ្លើងឆេះព្រៃ តែមិនមានយន្តការរាយការណ៍ច្បាស់លាស់ ដើម្បីសុំអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកឱ្យទាន់ពេលវេលា។

- **<u>បញ្ហាលំបាកក្នុងការចូលទៅដល់តំបន់កំពុងទទួលរងភ្លើងឆេះព្រៃលិចទឹក</u>**៖ ដោយសារភូមិសាស្ត្រតំបន់ព្រៃលិចទឹក មានព្រៃស្បាតដុះក្រាស់មិនមានផ្លូវសម្រាប់បើកបរម៉ូតូ គោយន្ត និងយានយន្តកែច្នៃ សូម្បីតែដើរថ្មើរជើង បង្កជាការលំបាក និងឧបសគ្គក្នុងការដឹកទឹក និងឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកចូលទៅដល់ទីតាំងកើតហេតុ ដើម្បីពន្លត់ភ្លើងឆេះព្រៃដែលកំពុងកើតឡើង នៅឆ្ងាយពីប្រភពទឹក។ ការមិនអាចចូលទៅដល់នេះ ជាហេតុនាំឱ្យភ្លើងឆេះព្រៃកាន់តែរីករាលដាលធំឡើងៗ មិនអាចគ្រប់គ្រងបាន និងទុកឱ្យភ្លើងឆេះព្រៃរលត់ដោយខ្លួនឯង។

- **<u>ខ្វះប្រភពទឹក</u>**៖ ដោយសារមានការប្រែប្រួលអាកាសធាតុ នាំឱ្យរដូវប្រាំងអូសបន្លាយរយៈពេលយូរ ធ្វើឱ្យទន្លេ បឹង ព្រែក ភាគច្រើនត្រូវបានរីងស្ងួត ពិសេសក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ធ្វើឱ្យបរិមាណទឹកក្នុងប្រព័ន្ធទឹកធម្មជាតិក្នុងតំបន់ព្រៃលិចទឹកនៅរដូវប្រាំងបានថយចុះគួរឱ្យកត់សម្គាល់ បណ្តាលឱ្យខ្វះខាតទឹកក្នុងការពន្លត់ពេលមានភ្លើងឆេះព្រៃលិចទឹក។

  ទឹកជាកត្តាចំបងសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹក ហើយកង្វះប្រភពទឹកនៅក្នុងតំបន់ព្រៃលិចទឹកគឺជាក្តីបារម្ភចំបង ដែលរាំងស្ទះដល់ការពន្លត់ភ្លើងឆេះព្រៃលិចទឹក។

- **<u>កង្វះថវិកា និងឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក</u>**៖ ការពន្លត់ភ្លើងឆេះព្រៃលិចទឹកគឺជាការងារដ៏លំបាក ដែលតម្រូវឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ (ឃុំ ស្រុក និងខេត្ត) ចូលរួមអនុវត្តក្រោមយន្តការគ្រប់គ្រងមួយប្រកបដោយប្រសិទ្ធភាពដោយមានថវិកា និងសម្ភារគ្រប់គ្រាន់។ ភាគីពាក់ព័ន្ធរួមមាន សមត្ថកិច្ចជំនាញ អាជ្ញាធរមូលដ្ឋាន អង្គការជាតិ និងអន្តរជាតិ សហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ ដោយឡែក អង្គភាពដែលនាំមុខក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកគឺ ខណ្ឌរដ្ឋបាលជលផល នៃមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរស្រុក និងឃុំ។ ប៉ុន្តែកន្លងមក អង្គភាពលើមិនអាចអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានពេញលេញក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក ដោយសារមូលហេតុពុំមានថវិកា និងសម្ភារគ្រប់គ្រាន់។

ដោយសារឧបសគ្គមួយចំនួនដូចបានរៀបរាប់ជូនខាងលើ នៅពេលមានភ្លើងឆេះព្រៃលិចទឹកកើតឡើង ស្ថាប័ន / អង្គភាពពាក់ព័ន្ធទាំងអស់គ្រាន់តែមានគំនិតអំពីវិធីសាស្ត្រទប់ស្កាត់ និងកាត់បន្ថយភ្លើងឆេះព្រៃលិចទឹកប៉ុណ្ណោះ ប៉ុន្តែមិនមានជម្រើសឯកភាពណាមួយជាអាទិភាព ត្រូវបានអនុវត្តឱ្យមានប្រសិទ្ធភាពនៅឡើយ។

## ៤.៥ ការអនុវត្តច្បាប់ជលផលដើម្បីទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក

ករណីភ្លើងឆេះព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យ កើតមានស្ទើររាល់ឆ្នាំ ដែលភាគច្រើនទំនងជាបង្កឡើងដោយប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិ ឃុំសាមី និងអ្នកដែលមកពីខាងក្រៅ។ ក្នុងនោះដែរ ក៏មានអ្នកនេសាទ និងកសិករមួយចំនួនមកពីតំបន់ខ្ពង់រាបចូលទៅក្នុងតំបន់២ និងតំបន់៣ នៃបឹងទន្លេសាបក្នុងរដូវប្រាំង ដើម្បីនេសាទត្រី រកអុស និងសំអាតសំណល់នៅក្នុងស្រែ ចំការ សម្រាប់ធ្វើការដាំដុះបន្ត។ ដូច្នេះភ្លើងឆេះព្រៃលិចទឹកមួយចំនួនអាចបង្កឡើងដោយក្រុមនេះផងដែរ តាមរយៈសកម្មភាពចំអិនអាហារ ដុតសំណល់នៅក្នុងដីស្រែ ចំការ និងបោះកន្ទុយបារី។

ការទន្ទ្រានយកដីព្រៃលិចទឹក និងការទិញ លក់ដីកសិកម្មនៅក្នុងតំបន់២ និងតំបន់៣ ក្នុងខេត្តបន្ទាយមានជ័យបានកើតឡើងជាទូទៅ។ ឈ្មួញដី ឬអ្នកមានមួយចំនួនបានឃុបឃិត និងជួលប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដោយផ្តល់ជាថវិកា និងគ្រឿងចក្រដើម្បីធ្វើការឈូសឆាយ និងបំលែងដីព្រៃលិចទឹកតាមដែលអាចធ្វើទៅបាន ឱ្យទៅជាដីស្រូវប្រាំងក្នុងគោលបំណងយកដីលក់។ បង្គោលព្រំមួយចំនួនដែលបានសាងសង់នៅតាមព្រំប្រទល់តំបន់៣ ត្រូវបានខូចខាត

មួយចំនួនដោយសកម្មភាពចេតនារបស់ជនល្មើស ក្នុងគោលបំណងបំភ័ន្តភ្នែកសមត្ថកិច្ចជំនាញដើម្បីទន្ទ្រានដីព្រៃ ពង្រីកដីស្រែ ចំការរបស់គាត់ចូលទៅក្នុងតំបន់៣។

ខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ កន្លងមកបានធ្វើការស៊ើបអង្កេត ស្រាវជ្រាវសាវតា និងចាប់ជនសង្ស័យមួយចំនួនដែលពាក់ព័ន្ធករណីភ្លើងឆេះព្រៃ និងការទន្ទ្រានព្រៃលិចទឹក ព្រមទាំងបានកសាងសំណុំរឿងបញ្ជូនជនសង្ស័យទៅតុលាការ ដើម្បីចាត់វិធានការតាមនីតិវិធីច្បាប់។

## ៥. ដំណើរការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក

ដើម្បីធានាការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដោយមានការចូលរួមប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ស្របតាមគោលការណ៍ 5"R" និង៣ដំណាក់កាលសំខាន់៖ ១. ការទប់ស្កាត់ (ការពិនិត្យឡើងវិញ ការកាត់បន្ថយហានិភ័យ និងការត្រៀមរួចជាស្រេច) ២. ការឆ្លើយតបនឹងភ្លើងឆេះព្រៃ និង ៣. ការស្តារព្រៃលិចទឹកឡើងវិញ ដែលមានចែងក្នុងគោលការណ៍ណែនាំសម្រាប់រៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់បឹងទន្លេសាប។ ផែនការនេះគួរតែត្រូវបានអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

### ៥.១ ការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក

ដំណាក់កាលទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកបានផ្តោតសំខាន់ទៅលើ 3"R" ក្នុងចំណោម 5"R" គឺ ១. ការពិនិត្យឡើងវិញ ២. ការកាត់បន្ថយហានិភ័យ និង ៣. ការត្រៀមរួចជាស្រេច ដែលនឹងត្រូវបានអនុវត្តតាមការណែនាំដូចខាងក្រោម៖

#### ៥.១.១ ការពិនិត្យឡើងវិញ

ការពិនិត្យឡើងវិញនូវបទពិសោធន៍ ព័ត៌មាន និងការយល់ដឹងអំពីមូលហេតុភ្លើងឆេះព្រៃលិចទឹក ដែលអាចបង្កឡើងដោយមនុស្ស ឬបាតុភូតធម្មជាតិ ឥរិយាបថនៃភ្លើងឆេះព្រៃលិចទឹក ការព្យាករណ៍ឧត្តុនិយម សារធាតុដែលងាយឆេះ អាកាសធាតុ ស្ថានភាពសំណើម និងផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកនៅកន្លែងផ្សេងៗគ្នារយៈពេលជាច្រើនឆ្នាំកន្លងមកក្នុងខេត្តបន្ទាយមានជ័យ មានសារៈសំខាន់ដល់ការរៀបចំផែនការយុទ្ធសាស្ត្រទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក សមស្របទៅនឹងស្ថានភាពវិវឌ្ឍន៍ និងស្ថានការណ៍នៃភ្លើងឆេះព្រៃលិចទឹកនាពេលបច្ចុប្បន្ន។

ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹក គឺជាទំហំនៃការខូចខាតចំពោះតម្លៃសង្គម សេដ្ឋកិច្ច វប្បធម៌ និងអភិរក្សជាពិសេសតំបន់ទេសភាពនៃទំនាបបឹងទន្លេសាបទាំងមូល។ ជារួម ភ្លើងឆេះព្រៃលិចទឹកបង្កផលប៉ះពាល់ដល់ទ្រព្យសម្បត្តិឯកជន និងសាធារណៈ ធនធានជលផល (ត្រី វារីរុក្ខជាតិ ព្រៃលិចទឹក បក្សី សត្វ ល្មូន ថនិកសត្វ និងឧរង្គសត្វ) ទីកន្លែងកំសាន្ត តំបន់ទេសចរណ៍ធម្មជាតិ បរិស្ថាន (ដី ទឹក រុក្ខជាតិ និងបរិយាកាស) ការស្តុកកាបូន សុខភាពមនុស្ស និងសត្វ និងជីវភាពរស់នៅរបស់ប្រជានេសាទ។ ការពិនិត្យឡើងវិញនេះ ត្រូវធ្វើឡើងទៅតាមសកម្មភាពមួយចំនួនដូចខាងក្រោម៖

**ក ) ការប្រជុំពិគ្រោះយោបល់ដើម្បីពិនិត្យឡើងវិញនូវបញ្ហាភ្លើងឆេះព្រៃលិចទឹក**

កិច្ចប្រជុំពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដូចជា៖ ខណ្ឌរដ្ឋបាលជលផល អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានត្រូវបានធ្វើឡើងជាបន្តបន្ទាប់ ដើម្បីពិភាក្សាប្រមូលព័ត៌មានដែលទាក់ទងទៅនឹងមូលហេតុ និងឥរិយាបថនៃភ្លើងឆេះព្រៃលិចទឹក ធាតុរួមផ្សំបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក (ភាពរាំងស្ងួត កំដៅ សំណើម ខ្យល់ សំណល់រុក្ខជាតិ សារធាតុ សរីរាង្គស្ងួត) អ្នកពាក់ព័ន្ធដែលសង្ស័យថា ជាអ្នកបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកចំពោះទ្រព្យសម្បត្តិ សុខភាព និងជីវិតរបស់មនុស្ស សត្វ បរិស្ថាន និងតំបន់ទេសភាពទាំងមូល ការទប់ស្កាត់ និងការពន្លត់ភ្លើងឆេះ

ព្រៃលិចទឹក វិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានអនុវត្តកន្លងមក ព្រមទាំងអ្នកពាក់ព័ន្ធនឹងដំណើរការនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។

ព័ត៌មានដែលប្រមូលបាន និងលទ្ធផលដែលបានរកឃើញនៅក្នុងដំណាក់កាលនេះ នឹងត្រូវប្រើប្រាស់ដើម្បីកំណត់វិធីសាស្ត្រដ៏មានប្រសិទ្ធិភាព សម្រាប់ទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។

**ខ) ការចុះអង្កេតទីតាំងភ្លើងឆេះព្រៃលិចទឹក**

ការចុះអង្កេតនៅទីតាំងភ្លើងឆេះព្រៃលិចទឹកដោយផ្ទាល់ត្រូវបានធ្វើឡើង បន្ទាប់ពីកិច្ចប្រជុំពិគ្រោះយោបល់បានបញ្ចប់ ដើម្បីប្រមូលព័ត៌មានបន្ថែមអំពីស្ថានភាពរូបសាស្ត្រ ការប្រើប្រាស់ដី ទីតាំងស្នាក់នៅបណ្តោះអាសន្ននៅក្នុង ឬក្បែរតំបន់ភ្លើងឆេះព្រៃលិចទឹក សញ្ញាណនៃមូលហេតុបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក រុក្ខជាតិគម្របដី ប្រភេទព្រៃលិចទឹក ទំហំនៃការខូចខាត។ និយាមកាព្រំប្រទល់នៃទីតាំងភ្លើងឆេះព្រៃលិចទឹក ត្រូវប្រមូលអំឡុងពេលនៃការអង្កេតនេះ ដើម្បីយកទៅផលិតជាផែនទីភ្លើងឆេះព្រៃលិចទឹក។

### ៤.១.២ ការកាត់បន្ថយហានិភ័យ

សកម្មភាពកាត់បន្ថយហានិភ័យនៃភ្លើងឆេះព្រៃលិចទឹក គឺមានបំណងចង់កាត់បន្ថយជាអតិបរិមានូវចំនួន/ករណីភ្លើងឆេះព្រៃលិចទឹក ចាប់ពីដើមរដូវប្រាំង ដែលនេះជាផ្នែកមួយដ៏សំខាន់បំផុតនៃការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដោយចំណាយតិចបំផុត ផ្តោតលើមូលហេតុជាអាទិភាពដែលបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក និងការពារកុំឱ្យមូលហេតុទាំងនោះកើតមានឡើង។

**ក) ការផលិតសម្ភារផ្សព្វផ្សាយ**

ក្នុងករណីមានសំណៅដើម (soft copy) នៃសម្ភារផ្សព្វផ្សាយដែលមានស្រាប់ ត្រូវនឹងប្រធានបទការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក និងការអនុវត្តច្បាប់ជលផលប្រឆាំងនឹងជនបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក ក្រុមការងារគួរផលិត/បោះពុម្ព និងប្រើប្រាស់វាដើម្បីផ្សព្វផ្សាយទៅតាមតម្រូវការចាំបាច់ ព្រោះចំណេញពេលវេលា និងចំណាយថវិកាតិចជាង។

ក្នុងករណីមិនមានសម្ភារផ្សព្វផ្សាយ ក្រុមការងារត្រូវពិចារណាលើការគ្រោងរចនារូបភាព និងសារសម្រាប់ផលិតសម្ភារផ្សព្វផ្សាយថ្មី ដោយសហការជាមួយទីប្រឹក្សាផ្នែកទំនាក់ទំនងនៃអង្គការ FAO ដែលសម្ភារផ្សព្វផ្សាយមានភាពសាមញ្ញ ងាយអាន ងាយយល់ និងមានអត្ថន័យគ្រប់គ្រាន់សម្រាប់លើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ។

**ខ) ប្រជុំនៅថ្នាក់ឃុំដើម្បីរៀបចំផែនការចុះផ្សព្វផ្សាយ**

ប្រជុំជាមួយតំណាងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក ឃុំ ភូមិ ក្រុមល្បាតភ្លើងឆេះព្រៃ និងសហគមន៍នេសាទ ដើម្បី៖

- កំណត់ទីតាំង បោះបង្គោលស្លាកសញ្ញាផ្សព្វផ្សាយ និងកំណត់ប្រជាពលរដ្ឋគោលដៅសម្រាប់ចែកចាយផ្ទាំងរូបភាពផ្សព្វផ្សាយ
- កំណត់ភូមិ ទីតាំង និងក្រុមគោលដៅ (កសិករដែលមានដីស្រែនៅក្នុងតំបន់២ និងតំបន់៣ អ្នកនេសាទ អ្នករកឃ្មុំ អ្នកប្រមាញ់សត្វ អ្នកឃ្វាលគោ-ក្របី) នៃយុទ្ធនាការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដើម្បីឱ្យមានការចូលរួម។ ចំនួនបុរស និងស្ត្រីនៃតំណាងក្រុមគោលដៅនីមួយៗដែលនឹងត្រូវចូលរួមក្នុងការផ្សព្វផ្សាយគួរពិចារណានូវចំនួនស្មើគ្នា។ ប្រើប្រាស់បញ្ជីឈ្មោះកសិករដែលមានដីចំការស្រែនៅក្នុងតំបន់៣ ម្ចាស់ត្រាក់ទ័រ អ្នកនេសាទ អ្នកឃ្វាលគោ-ក្របី អ្នករកឃ្មុំ អ្នកប្រមាញ់សត្វព្រៃ ដើម្បីងាយស្រួលកំណត់ភូមិ ទីតាំង និងក្រុមគោលដៅ
- ណែនាំអំពីរបៀបអាន និងប្រើប្រាស់សម្ភារផ្សព្វផ្សាយក្នុងការលើកកម្ពស់កម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋឱ្យចូលរួមទប់ស្កាត់ភ្លើងឆេះព្រៃ និងការកាប់ទន្រ្ទានរានដីព្រៃលិចទឹក

- រៀបចំផែនការផ្សព្វផ្សាយដោយមានការចូលរួមពីអាជ្ញាធរស្រុក ឃុំ ភូមិ ដោយបញ្ជាក់ពីតួនាទី និងភារកិច្ចរបស់ក្រុមការងារ សម្ភារចាំបាច់ដែលត្រូវប្រើប្រាស់ (ឯកសារថតចម្លងពីច្បាប់បទដ្ឋានពាក់ព័ន្ធ ផ្ទាំងរូបភាពផ្សព្វផ្សាយ ឧបករណ៍បំពងសម្លេង) ការជូនដំណឹង ការអញ្ជើញអ្នកចូលរួម ពេលវេលា និងទីតាំងសមស្រប
- ផ្តល់ផ្ទាំងរូបភាពផ្សព្វផ្សាយជូនរដ្ឋបាលស្រុក ឃុំ ភូមិ និងសហគមន៍នេសាទ ដើម្បីជួយបិទផ្សាយនៅកន្លែងទីប្រជុំជនមុននឹងមានកិច្ចប្រជុំផ្សព្វផ្សាយ។

**គ) ការផ្សព្វផ្សាយអំពីការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម**

- ដំឡើងស្លាកសញ្ញាផ្សព្វផ្សាយនៅទីតាំងដែលបានកំណត់
- ចែកជូននូវសម្ភារផ្សព្វផ្សាយដូចជា ខិត្តប័ណ្ណ ឬផ្ទាំងរូបភាពផ្សេងៗ ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ក្រុមគោលដៅនៅតាមភូមិ និងទីតាំងស្នាក់នៅបណ្ដោះអាសន្ន ស្តីពីការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម និងការអនុវត្តច្បាប់ប្រឆាំងនឹងជនល្មើសដែលបានកាប់ និងដុតបំផ្លាញព្រៃលិចទឹក
- ប្រមូលព័ត៌មានត្រលប់ដែលទាក់ទងនឹងបញ្ហានៃការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំផ្សព្វផ្សាយ ដើម្បីរួមគ្នាចាត់វិធានការដោះស្រាយបន្ត។

**ឃ) ធ្វើការល្បាតទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកជាប្រចាំ**

ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកត្រូវបានបង្កើតឡើង និងដំណើរការយាមល្បាតដោយផ្អែកលើផែនការល្បាតប្រចាំសប្តាហ៍ និងប្រចាំខែ ដែលបានរៀបចំដោយមានការព្រមព្រៀងគ្នារវាងសមាជិកក្រុមល្បាត និងក្រុមការងារថ្នាក់ឃុំ។ សមាជិកក្រុមល្បាតនីមួយៗត្រូវយកឧបករណ៍ពន្លត់ភ្លើងឆេះព្រៃចល័តទៅតាមជាមួយ ដើម្បីត្រៀមខ្លួនជាស្រេចក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកតាមដែលអាចធ្វើទៅបាននៅពេលបានជួបប្រទះក្នុងពេលល្បាត។ ក្រៅពីនេះ ក្នុងអំឡុងពេលល្បាត ក្រុមល្បាតនីមួយៗត្រូវកត់ត្រារាល់សកម្មភាព និងព្រឹត្តិការណ៍នានា ដែលបានឃើញ និងគិតថាអាចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក លើទម្រង់របាយការណ៍ដែលបានចែកជូន។ រូបភាពនៃភ្លើងឆេះព្រៃលិចទឹក ការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងសកម្មភាពដែលសង្ស័យថា អាចបង្កឱ្យភ្លើងឆេះព្រៃលិចទឹកត្រូវថតទុកជាភស្តុតាង និងកំណត់ចំនុចនិយាមការផងដែរ។ ប្រធានក្រុមល្បាតត្រូវផ្តល់ដំណឹងជូនមេឃុំ និងសង្កាត់រដ្ឋបាលជលផលពាក់ព័ន្ធដោយទៀងទាត់អំពីស្ថានភាពល្បាត ករណីសង្ស័យការកាប់ឆ្ការព្រៃលិចទឹក និងករណីភ្លើងឆេះព្រៃលិចទឹកជាក់ស្តែង ដើម្បីស្នើសុំអន្តរាគមន៍ឱ្យបានទាន់ពេលវេលា។

មេឃុំ និងនាយសង្កាត់រដ្ឋបាលជលផល ត្រូវចាត់ចែងការត្រៀមប្រចាំការ តាមដាន និងរក្សាទំនាក់ទំនងជាមួយក្រុមល្បាតតាមរយៈទូរស័ព្ទ ឬវិទ្យុទាក់ទងជាប្រចាំ ដូច្នេះពួកគាត់អាចចាត់វិធានការឆ្លើយតបនឹងសំណើសុំអន្តរាគមន៍បន្ទាន់ពីក្រុមល្បាតទាន់ពេលវេលា។ មេឃុំក៏ត្រូវស្នើសុំការអន្តរាគមន៍ជាបន្ទាន់ផងដែរពីក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក ឬខេត្ត ក្នុងករណីដែលភ្លើងឆេះព្រៃលិចទឹកមានទំហំធំ មិនអាចគ្រប់គ្រងបាន។

**៤.១.៣ ការត្រៀមរួចជាស្រេច**

ការត្រៀមរួចជាស្រេច គឺជាការរៀបចំទុកជាមុននូវរចនាសម្ព័ន្ធក្រុមការងារនៅថ្នាក់ភូមិ ឃុំ ស្រុក ខេត្ត ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការផ្គត់ផ្គង់សម្ភារ និងឧបករណ៍ចាំបាច់សម្រាប់ឆ្លើយតបជាបន្ទាន់ទៅនឹងករណីកើតមានភ្លើងឆេះព្រៃលិចទឹកជាយថាហេតុ។ ការត្រៀមនេះ មានគោលបំណង ដើម្បីធ្វើការវាយតម្លៃ កំណត់ភាគីពាក់ព័ន្ធ ហេដ្ឋារចនាសម្ព័ន្ធ និងឧបករណ៍ចាំបាច់ដែលត្រូវរៀបទុកជាមុនសម្រាប់ធ្វើអន្តរាគមន៍ទាន់ពេលវេលា និងសមស្របទៅនឹងទំហំនៃភ្លើងឆេះព្រៃដែលកើតមានឡើង ដើម្បីកាត់បន្ថយការចំណាយខ្ពស់សម្រាប់ការពន្លត់ភ្លើងឆេះព្រៃលិចទឹកដោយសារមិនបានត្រៀមទុកជាមុន។

**ក) បង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ឃុំ ស្រុក និងខេត្ត**

- រៀបចំសេចក្តីព្រាងអំពីសេចក្តីសម្រេចបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ឃុំ ស្រុក និងខេត្ត រួចហើយផ្ញើសេចក្តីព្រាងនេះទៅអភិបាលនៃគណៈអភិបាលខេត្ត អភិបាលនៃគណៈអភិបាលស្រុក និងមេឃុំពាក់ព័ន្ធដើម្បីពិនិត្យ និងចុះហត្ថលេខាសម្រេច
- សហការជាមួយរដ្ឋបាលខេត្ត និងរដ្ឋបាលស្រុកពាក់ព័ន្ធ រៀបចំកិច្ចប្រជុំជាមួយអង្គភាពពាក់ព័ន្ធនៅថ្នាក់ខេត្ត និងស្រុក ដើម្បីបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត និងស្រុកជាផ្លូវការ
- ប្រជុំជាមួយក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធ ដើម្បីបង្កើតក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំ។

**ខ) ប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត**

យោងទៅតាមតួនាទី និងភារកិច្ចរបស់ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ដែលមានចែងនៅក្នុងសេចក្តីសម្រេចចុះហត្ថលេខាដោយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត ខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ សហការជាមួយរដ្ឋបាលខេត្ត រៀបចំកិច្ចប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ក្រោមអធិបតីភាពរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ នៅរៀងរាល់ដើមឆ្នាំ ដើម្បីជួយជំរុញ និងពង្រឹងការអនុវត្តការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់មូលដ្ឋានឱ្យមានប្រសិទ្ធភាព និងទាន់ពេលវេលា ដោយមានកិច្ចសហការល្អពីអង្គភាពពាក់ព័ន្ធទាំងអស់។ អ្នកចូលរួមនៅក្នុងអង្គប្រជុំនេះរួមមាន សមាជិកទាំងអស់នៃក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ។

របៀបវារៈ និងគោលបំណងនៃកិច្ចប្រជុំគឺ ធ្វើបទបង្ហាញអំពីផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកប្រចាំឆ្នាំនៅថ្នាក់ខេត្ត និងស្រុក រំលឹកឡើងវិញអំពីតួនាទី និងភារកិច្ចរបស់ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក លើកបញ្ហាប្រឈមសំខាន់ៗ ដែលត្រូវដោះស្រាយចំពោះមុខ (ទំនាក់ទំនង ការពង្រឹងច្បាប់ មធ្យោបាយពន្លត់ភ្លើងឆេះព្រៃ និងថវិកា) ដាក់ជូនឯកឧត្តមអភិបាលខេត្តពិនិត្យ និងផ្តល់យោបល់ ដើម្បីធានាថា ការអនុវត្តកិច្ចទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកប្រព្រឹត្តទៅបានដោយរលូន និងមានភាពប្រសើរឡើង។

មុនពេលប្រជុំ មន្ត្រីបង្គោលរបស់ខណ្ឌរដ្ឋបាលជលផលគួរតែដាក់សំណើជាផ្លូវការសម្រាប់រៀបចំកិច្ចប្រជុំដោយភ្ជាប់ជាមួយនូវរបៀបវារៈនៃកិច្ចប្រជុំ សេចក្តីសម្រេចបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកប្រចាំឆ្នាំ របាយការណ៍ប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុក ផែនទីភ្លើងឆេះព្រៃលិចទឹកនៅក្នុងខេត្ត និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ដាក់ជូនឯកឧត្តមអភិបាលខេត្ត ដើម្បីជ្រាបជាព័ត៌មាន ហើយនឹងត្រូវចែកជូនបន្តទៅបណ្តាស្រុកពាក់ព័ន្ធ ជាមួយនឹងលិខិតអញ្ជើញឱ្យចូលរួមការប្រជុំនេះ។

ក្រោយពីការប្រជុំបានបញ្ចប់ ខណ្ឌរដ្ឋបាលជលផលត្រូវរៀបចំរបាយការណ៍ប្រជុំ ផ្ញើជូនប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឯកឧត្តមអភិបាលខេត្ត ដើម្បីពិនិត្យ និងចុះហត្ថលេខាឯកភាព។ បន្ទាប់មករបាយការណ៍នេះនឹងត្រូវផ្ញើជូនទៅរដ្ឋបាលជលផល និងស្ថាប័នពាក់ព័ន្ធទាំងអស់នៅថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បីជ្រាបជាព័ត៌មាន និងចាត់វិធានការអនុវត្ត។

**គ) ប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក**

ខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ សហការជាមួយអាជ្ញាធរស្រុក រៀបចំប្រជុំប្រចាំត្រីមាស ឬតាមការចាំបាច់នៅថ្នាក់ស្រុក ដើម្បីផ្តល់ឱកាសឱ្យក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក និងខណ្ឌរដ្ឋបាលជលផល ជួបជុំគ្នាពិភាក្សាអំពីលទ្ធផលនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក្នុងរយៈពេល ៣ខែកន្លងមក និងលើកបញ្ហាដែលបានជួបប្រទះ ដើម្បីឱ្យអាជ្ញាធរស្រុក ជាពិសេស គណៈបញ្ជាការឯកភាពស្រុកផ្តល់

អនុសាសន៍ និងចាត់វិធានការដោះស្រាយលើបញ្ហាទាំងនោះឱ្យទាន់ពេលវេលា។ តំណាងរដ្ឋបាលជលផល និងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត គួរតែត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំនេះ ដើម្បីឱ្យដំណោះស្រាយកាន់តែមានប្រសិទ្ធភាព និងមានកិច្ចសហការខ្ពស់។

បន្ទាប់ពីកិច្ចប្រជុំនេះ ខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ ត្រូវរៀបចំរបាយការណ៍នៃការប្រជុំប្រចាំត្រីមាសនេះ និងបញ្ជូនរបាយការណ៍នេះទៅអភិបាលស្រុក ដើម្បីពិនិត្យ និងចុះហត្ថលេខាឯកភាព។ បន្ទាប់មក របាយការណ៍នេះនឹងត្រូវផ្ញើជូនទៅរដ្ឋបាលជលផល និងអង្គភាពពាក់ព័ន្ធទាំងអស់នៅថ្នាក់ខេត្ត ស្រុក និងឃុំ ដើម្បីជ្រាបជាព័ត៌មាន និងចាត់វិធានការអនុវត្ត។

**ឃ) ប្រជុំក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំ**

កិច្ចប្រជុំក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកប្រចាំខែ ដែលដឹកនាំដោយមេឃុំ និងមានការចូលរួមពីសង្កាត់រដ្ឋបាលជលផល គួរតែត្រូវបានរៀបចំឡើងជាទៀងទាត់ ដើម្បីចែករំលែកបទពិសោធន៍ដែលបានទទួលក្នុងចំណោមសមាជិកក្រុមល្បាត ហើយពិភាក្សាអំពីបញ្ហាប្រឈមនានា ដែលបានជួបប្រទះក្នុងពេលល្បាត និងស្វែងរកដំណោះស្រាយសមស្រប។

ដោយក្រុមល្បាតបានទទួលវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសល្បាត និងពន្លត់ភ្លើងឆេះព្រៃលិចរួចមកហើយ ក្រុមល្បាតបានយល់ដឹងអំពីតួនាទី និងភារកិច្ចរបស់ក្រុមល្បាត ការរៀបចំផែនការល្បាតប្រចាំសប្តាហ៍ និងប្រចាំខែ ការកត់ត្រាកំណត់ហេតុ វិធីសាស្ត្រ និងការប្រើប្រាស់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ និងច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធមួយចំនួនដូចជា៖ ច្បាប់ស្តីពីជលផល ច្បាប់ភូមិបាល អនុក្រឹត្យលេខ១៩៧។ល។ ដូច្នេះកិច្ចប្រជុំប្រចាំខែនេះក៏មានគោលបំណង រំលឹកឡើងវិញនូវចំណេះដឹងទាំងនោះ និងបន្ថែមនូវព័ត៌មានថ្មីៗដែលទើបនឹងទទួលបាន។

ទន្ទឹមនឹងនេះដែរ កិច្ចប្រជុំប្រចាំខែរបស់ក្រុមល្បាតក៏មានគោលបំណងពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមល្បាតដើម្បីពង្រឹងតួនាទី និងភារកិច្ចរបស់ក្រុមល្បាត ដែលអាចបណ្តាលមកពីមានសមាជិកក្រុមល្បាតមួយចំនួនអសកម្មដោយមូលហេតុផ្សេងៗ (មានជំងឺ មានធុរៈ ឬលាឈប់ពីក្រុម)។ ក្រៅពីនេះ កិច្ចប្រជុំប្រចាំខែក៏ត្រូវបានរៀបចំឡើងសម្រាប់ធ្វើការត្រួតពិនិត្យស្ថានភាពឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ ដើម្បីឱ្យដឹងថាឧបករណ៍ណានៅប្រើបាន បាត់បង់ត្រូវទិញថ្មី ខូចត្រូវជួសជុល ឬទិញឧបករណ៍ថ្មីបន្ថែម សំដៅធានាថាក្រុមល្បាតមានឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកគ្រប់គ្រាន់យកទៅតាមខ្លួនក្នុងពេលល្បាតសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹកជាបន្ទាន់។ ស្ត្រីត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងក្រុមល្បាតទៅតាមកាលៈទេសៈ និងស្ថានភាពជាក់ស្តែង។

កំណត់ហេតុនៃការប្រជុំប្រចាំខែត្រូវបានរៀបចំនៅពេលបញ្ចប់កិច្ចប្រជុំ ដើម្បីរាយការណ៍ទៅក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក និងនាយខណ្ឌរដ្ឋបាលជលផល ដើម្បីជ្រាបជាព័ត៌មាន និងចាត់វិធានការឆ្លើយតបនឹងបញ្ហាប្រឈម។

**ង) សាងសង់រចនាសម្ព័ន្ធសម្រាប់ការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក**

ដូចដែលបានរៀបរាប់ជូនខាងលើ រចនាសម្ព័ន្ធរូបវន្តចាំបាច់ដែលត្រូវសាងសង់សម្រាប់ការងារទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ដូចជា ការសាងសង់បង្គោលព្រំតំបន់៣បន្ថែម ការបោះបង្គោលនៅតាមព្រំប្រទល់ព្រៃលិចទឹកដែលបានឆេះ ការសាងសង់ប៉មត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក ការស្តារស្រះ/ត្រពាំង។ ដោយសារតែថវិកាមានកំណត់ ដូច្នេះរាល់តម្រូវការរូបវន្តនឹងត្រូវរៀបចំពីមួយឆ្នាំទៅមួយឆ្នាំ តាមតម្រូវការអាទិភាពដែលបានកំណត់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់រវាងអ្នកពាក់ព័ន្ធនៅថ្នាក់ ភូមិ-ឃុំ និងថវិកាដែលមាន។ យោងទៅតាមគោលការណ៍លទ្ធកម្ម និងបច្ចេកទេស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នឹងត្រូវបានអនុវត្តជាជំហានៗដូចខាងក្រោមនេះ៖

- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើកដំបូងជាមួយមេឃុំ មេភូមិ សហគមន៍នេសាទ និងក្រុមល្បាតភ្លើងឆេះព្រៃ ដើម្បីកំណត់ទីតាំងសម្រាប់សាងសង់ប៉មអង្កេតភ្លើងឆេះព្រៃលិចទឹក ស្តារបឹង/ត្រពាំង និងព្រៃឆេះដែលត្រូវបោះបង្គោល និងដាក់ស្លាកសញ្ញា
- សិក្សាពីទំហំ បច្ចេកទេស និងតម្លៃប៉ាន់ស្មានសម្រាប់ការស្តារបឹង/ត្រពាំង ប៉មអង្កេតភ្លើងឆេះព្រៃលិចទឹក បង្គោលស៊ីម៉ងត៍ដើម្បីការដេញថ្លៃ
- រៀបចំឯកសារ និងដំណើរការលទ្ធកម្ម (ឯកសារប្រកាសដេញថ្លៃ ការជ្រើសរើសក្រុមហ៊ុនវិស្វកម្មតាមរយៈការដេញថ្លៃ ត្រួតពិនិត្យការដេញថ្លៃ ប្រកាសក្រុមហ៊ុនវិស្វកម្មដែលត្រូវបានជ្រើសរើស) សម្រាប់ការស្តារស្រះ សាងសង់ប៉មយាម និងផលិតបង្គោលស៊ីម៉ងត៍
- ត្រួតពិនិត្យការសាងសង់ និងទូទាត់បញ្ជី។

ជាទូទៅ ការងារនេះជាការងារលទ្ធកម្ម ត្រូវបានអនុវត្តដោយក្រុមការងារលទ្ធកម្មនៃរដ្ឋបាលជលផលក្នុងកិច្ចសហការជាមួយអាជ្ញាធរស្រុក និងឃុំ។

**ច) បង្កើនចំណេះដឹង និងជំនាញល្បាតភ្លើងឆេះព្រៃលិចទឹក**

- រៀបចំឯកសារមេរៀនស្តីពីបច្ចេកទេសល្បាតភ្លើងឆេះព្រៃលិចទឹក៖ ការបណ្តុះបណ្តាលនេះផ្តោតលើប្រធានបទស្តីអំពី តួនាទី និងការទទួលខុសត្រូវរបស់ក្រុមល្បាត សារៈសំខាន់នៃព្រៃលិចទឹក ផលប៉ះពាល់នៃភ្លើងឆេះព្រៃលិចទឹកចំពោះប្រព័ន្ធអេកូឡូស៊ីនៃតំបន់ទំនាបបឹងទន្លេសាប និងមនុស្សជាតិ យុទ្ធសាស្ត្រល្បាតភ្លើងឆេះព្រៃលិចទឹក ការប្រើប្រាស់ឧបករណ៍វៃឆ្លាតដើម្បីធ្វើការត្រួតពិនិត្យ និងរាយការណ៍ (SMART Connection) ការប្រើប្រាស់ និងថែរក្សាឧបករណ៍ល្បាត ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមដោយប្រើទូរស័ព្ទ ច្បាប់ជលផល និងបទដ្ឋានច្បាប់ទាក់ទងនឹងភ្លើងឆេះព្រៃលិចទឹក ការធ្វើផែនការ និងការសរសេររបាយការណ៍ ដែលនឹងរៀបចំដោយអង្គការសមាគមន៍អភិរក្សសត្វព្រៃ (WCS)
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសល្បាតភ្លើងឆេះព្រៃលិចទឹក៖ វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងនៅថ្នាក់ឃុំ ដើម្បីផ្តល់ឱកាសដល់សមាជិកក្រុមល្បាតទាំងអស់បានចែករំលែក និងរៀនសូត្របទពិសោធន៍ពីគ្នាទៅវិញទៅមក ជាពិសេសគ្រូបង្គោល ស្តីអំពីវិធីសាស្ត្រគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយប្រើប្រាស់បច្ចេកទេសទំនើប
- ប្រជុំរៀបចំផែនការល្បាតប្រចាំខែ និងប្រចាំសប្តាហ៍នៅថ្នាក់ឃុំ៖ ដើម្បីអនុញ្ញាតឱ្យសមាជិកក្រុមល្បាតទាំងអស់ចូលរួមពិភាក្សាអំពីផែនការល្បាតដោយស្ម័គ្រចិត្ត និងម្ចាស់ការ យកទៅអនុវត្តក្រោយពីកិច្ចប្រជុំនេះ។ ផែនការល្បាតនេះត្រូវបានពិនិត្យ និងចុះហត្ថលេខាដោយមេឃុំសាមី
- តាមដាន និងកែលម្អការអនុវត្តចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសល្បាតភ្លើងឆេះព្រៃលិចទឹក" របស់ក្រុមល្បាត ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពល្បាត។

**ឆ) បំពាក់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកដល់ក្រុមល្បាត**

ឧបករណ៍ល្បាតសម្រាប់ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកប្រើប្រាស់ជារួម និងប្រើប្រាស់ជាបុគ្គលដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួនរួមមាន បំពង់ពន្លត់អគ្គិភ័យ ទូរស័ព្ទវៃឆ្លាត (BlackView) ប្រើប្រាស់សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃ ដ្រូន វិទ្យុទាក់ទង ប្រអប់សង្គ្រោះបឋម ម៉ាសបិទច្រមុះ វ៉ែនតាការពារភ្លើង ស្រោមដៃ ធុងបាញ់ទឹកចល័តដែលមានចំណុះ២៥លីត្រ មួកសុវត្ថិភាព កាបូបស្ពាយ ស្បែកជើងពន្លត់អគ្គិភ័យ អង្រឹង កាំបិតដងវែង ប៉ែល ពិល ម៉ូតូគោយន្តបំពាក់ដោយម៉ាស៊ីនបូមទឹក ស៊ីទែនទឹក ទុយោ និងក្បាលបាញ់ទឹក នឹងត្រូវទិញចែកជូនដល់ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកដើម្បីប្រើប្រាស់។

បទប្បញ្ញត្តិសម្រាប់ការប្រើប្រាស់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ ដែលត្រូវប្រើប្រាស់ដោយក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកត្រូវតែបង្កើត និងផ្សព្វផ្សាយដល់សមាជិកទាំងអស់តាមរយៈការប្រជុំនៅថ្នាក់ឃុំ ដើម្បីធានាថាឧបករណ៍ទាំងអស់នោះត្រូវបានប្រើប្រាស់តាមគោលការណ៍ណែនាំ និងត្រូវបានថែរក្សាសម្រាប់ការប្រើប្រាស់យូរអង្វែង។

ការបណ្តុះបណ្តាលបន្ថែមនៅថ្នាក់ឃុំស្តីពីការប្រើប្រាស់ និងថែរក្សាឧបករណ៍ពន្លត់ភ្លើងឆេះព្រៃឱ្យបានត្រឹមត្រូវនឹងត្រូវបានរៀបចំជូនសមាជិកក្រុមល្បាតទាំងអស់ ដើម្បីធានាថា ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកត្រូវបានប្រើប្រាស់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។

## ៥.២ ការពន្លត់ភ្លើងឆេះព្រៃលិចទឹក

ដំណាក់កាលនៃការធ្វើអន្តរាគមន៍នេះ ផ្តោតសំខាន់លើការពន្លត់ភ្លើងឆេះព្រៃលិចទឹក ការអនុវត្តច្បាប់ស្តីពីជលផល និងការល្បាតព្រៃលិចទឹកជាប្រចាំដោយក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក ក្រោមការគាំទ្រដោយផ្ទាល់ពីមេឃុំ និងនាយសង្កាត់រដ្ឋបាលជលផលក្នុងភូមិសាស្ត្រសាមី។ ក្នុងករណីដែលក្រុមល្បាតជួបប្រទះភ្លើងឆេះព្រៃលិចទឹកកំពុងកើតឡើងនៅក្នុងពេលល្បាត សមាជិកក្រុមល្បាតនីមួយៗត្រូវចាត់វិធានការពន្លត់ភ្លើងឆេះព្រៃតាមការណែនាំដូចខាងក្រោម៖

**ក) ករណីភ្លើងឆេះព្រៃលិចទឹកមានទ្រង់ទ្រាយតូច**

ក្នុងករណីដែលក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកជួបប្រទះនឹងភ្លើងឆេះព្រៃមានទ្រង់ទ្រាយតូច អាចគ្រប់គ្រងបានក្រុមល្បាតត្រូវប្រើប្រាស់ឧបករណ៍ចល័តដែលបានយកមកជាមួយ ឬវត្ថុដែលអាចរកបាននៅទីនោះ ដោយអនុវត្តតាមការណែនាំខាងក្រោម៖

- បិទមាត់ និងច្រមុះដោយប្រើម៉ាស់ ឬក្រម៉ា ដើម្បីកាត់បន្ថយការស្រូបយកផ្សែង ផេះ និងធូលី
- ប្រើមែកឈើដើម្បីវាយពន្លត់ភ្លើង
- ប្រើប៉ែល ឬចបកាប់ ដើម្បីជីកដីលប់ភ្លើង ឬកាយជាផ្លូវភ្លើងជុំវិញកុំឱ្យភ្លើងរាលដាលបន្ត
- ប្រើធុងបាញ់ទឹកចល័តដើម្បីពន្លត់ភ្លើង ហើយត្រូវប្រាកដថាភ្លើងបានរលត់ទាំងស្រុងមុននឹងចាកចេញពីកន្លែងកើតហេតុ ដើម្បីចៀសវាងកុំឱ្យភ្លើងឆេះឡើងវិញ
- ថតរូបភាព និងរាយការណ៍ពីហេតុការណ៍នេះជូនមេឃុំ នាយសង្កាត់រដ្ឋបាលជលផលដែលនៅជិតបំផុតតាមរយៈទូរស័ព្ទ វិទ្យុទាក់ទង ឬកម្មវិធីស្មាត (SAMRT-BalckView) ។

**ខ) ករណីភ្លើងឆេះព្រៃលិចទឹកមានទ្រង់ទ្រាយមធ្យម ឬធំ**

ប្រសិនបើភ្លើងឆេះព្រៃលិចទឹកមានទ្រង់ទ្រាយមធ្យម ឬធំ ទាំងក្រុមល្បាត និងអ្នកចូលរួមពន្លត់ភ្លើងឆេះព្រៃទាំងអស់ត្រូវមានការប្រុងប្រយ័ត្នដើម្បីរក្សាសុវត្ថិភាពផ្ទាល់ខ្លួន ដោយចាត់វិធានការពន្លត់ភ្លើងឆេះព្រៃលិចទឹកតាមវិធីសាស្ត្រដូចខាងក្រោម:

- រាល់សមាជិកក្រុមល្បាតត្រូវតែបិទមាត់ និងច្រមុះឱ្យបានរហ័សដោយប្រើម៉ាស់ ក្រម៉ា ឬអាវយឺតដើម្បីកាត់បន្ថយការស្រូបយកនូវផ្សែង ផេះ និងធូលី ដែលមានផលប៉ះពាល់អវិជ្ជមានដល់សុខភាព
- ជូនដំណឹងដល់មេភូមិ មេឃុំ និងសង្កាត់រដ្ឋបាលជលផលដែលនៅជិតបំផុតតាមរយៈទូរស័ព្ទ វិទ្យុទាក់ទង ឬកម្មវិធីស្មាត (SMART-BlackView) អំពីហេតុការណ៍ភ្លើងឆេះព្រៃលិចទឹក ដែលកំពុងកើតមានឡើង ដើម្បីទទួលបាននូវការជួយអន្តរាគមន៍ទាំងកម្លាំង និងសម្ភារសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹក ដែលមានស្រាប់នៅក្នុងឃុំ ព្រមទាំងជំនួយពីស្រុក ឬខេត្តបន្ថែម

- ប្រើឧបករណ៍ពន្លត់អគ្គិភ័យចល័តដែលបានយកមកជាមួយ ពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលអាចធ្វើទៅបានដើម្បីទប់ស្កាត់ការរាលដាលភ្លើងឆេះព្រៃ។ នៅក្នុងពេលពន្លត់ភ្លើង ត្រូវស្ថិតនៅឱ្យឆ្ងាយពីភ្លើងបន្តិចដើម្បីជៀសវាងគ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុ
- ស្នើដល់ក្រុមមនុស្សមួយចំនួនដែលកំពុងធ្វើស្រែ ចំការ ឬនេសាទ នៅក្បែរកន្លែងកើតហេតុឱ្យជួយពន្លត់ភ្លើងដោយប្រើឧបករណ៍ដែលមានស្រាប់ដូចជា ម៉ាស៊ីនបូមទឹក គោយន្ត ត្រាក់ទ័រ ស៊ីទែនទឹក ធុងទឹក ទុយោ ។ល។
- មេឃុំ ត្រូវជូនដំណឹងទៅលោកអភិបាលស្រុកជាបន្ទាន់ដើម្បីសុំជំនួយរថយន្តពន្លត់អគ្គិភ័យ និងកងកំលាំងពន្លត់អគ្គិភ័យមកកាន់កន្លែងកើតហេតុ រួមគ្នាគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក
- មេឃុំតាមរយៈប្រធានភូមិត្រូវកៀរគរប្រជាពលរដ្ឋដែលស្ថិតនៅភូមិជិតបំផុត ឱ្យយកឧបករណ៍ដែលអាចប្រើបានមកជាមួយ ដូចជាគោយន្ត ម៉ាស៊ីនបូមទឹក ទុយោ ធុងទឹក ជួយពន្លត់ភ្លើងឆេះព្រៃជាបន្ទាន់ និងត្រូវណែនាំឱ្យពួកគាត់បិទមាត់ និងច្រមុះដោយប្រើម៉ាស់ កន្សែង ឬក្រម៉ា ដើម្បីរក្សាសុខភាពផ្ទាល់ខ្លួន
- បើសិនជារថយន្តពន្លត់អគ្គិភ័យមិនអាចចូលទៅដល់ទីតាំងភ្លើងឆេះព្រៃលិចទឹកបាន យានយន្តទាំងនោះអាចត្រូវបានប្រើជាអ្នកផ្គត់ផ្គង់ទឹក បំពេញស៊ីទែនដែលផ្ទុកនៅលើគោយន្ត ឬយានយន្តកែច្នៃដើម្បីដឹកយកទៅពន្លត់ភ្លើងឆេះព្រៃលិចទឹក
- នៅក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹក គោយន្ត និងត្រាក់ទ័រអាចប្រើសម្រាប់ឈូសជាផ្លូវភ្លើង បោសសំអាតសំណល់សរីរាង្គស្ងួតដែលងាយឆេះ នៅកន្លែងដែលអាចធ្វើបាន (វាលស្មៅ ឬព្រៃស្បាត) ដើម្បីបញ្ឈប់ការរាលដាលនៃភ្លើងឆេះព្រៃលិចទឹក
- ត្រូវប្រាកដថាភ្លើងឆេះព្រៃលិចទឹកត្រូវបានពន្លត់ទាំងស្រុង ដើម្បីចៀសវាងការកើតឡើងវិញនូវភ្លើងឆេះព្រៃមុនពេលចាកចេញពីកន្លែងកើតហេតុ
- រៀបចំរបាយការណ៍ស្តីពីករណីភ្លើងឆេះព្រៃលិចទឹកដោយមានរៀបរាប់អំពីទីតាំងនៃភ្លើងឆេះព្រៃ ផ្ទៃដីព្រៃលិចទឹកដែលបានឆេះ មូលហេតុ អ្នកពាក់ព័ន្ធ និងចំនួនមនុស្សដែលបានចូលរួមក្នុងការពន្លត់ភ្លើងឆេះព្រៃ ឧបករណ៍ពន្លត់អគ្គិភ័យដែលបានប្រើប្រាស់ ទំហំនៃការខូចខាត និងអនុសាសន៍សម្រាប់ពិចារណាដើម្បីចាត់វិធានការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនាពេលខាងមុខ។

## ៥.៣ ការស្តារព្រៃលិចទឹក

ព្រៃលិចទឹកនៅជុំវិញបឹងទន្លេសាបមានចំណាត់ថ្នាក់បីប្រភេទ៖ ព្រៃលិចទឹក ព្រៃគុម្ពោត និងវាលស្មៅលិចទឹក។ ព្រៃលិចទឹកមានកម្ពស់ខ្ពស់ជា៤ម៉ែត្រ ហើយអាចកម្ពស់រហូតដល់១៥ម៉ែត្រ ដែលភាគច្រើនស្ថិតនៅតាមមាត់បឹងបឹងទន្លេសាប តំបន់ដីសើម និងនៅតាមដងទន្លេ ស្ទឹង និងអូរ។ ព្រៃគុម្ពោតលិចទឹកមានកម្ពស់ក្រោម៤ម៉ែត្រ និងមានព្រៃលិចទឹកនៅរាយប៉ាយ ក្នុងកម្រិតដង់ស៊ីតេឈើឈរប្រហែល ២៥-៣០ដើម/ហិកតា។

នៅរដូវវស្សាព្រៃលិចទឹក និងព្រៃគុម្ពោតលិចទឹកត្រូវបានលិចទាំងស្រុង មិនអាចលូតលាស់បាន ព្រោះវាមិនមានពន្លឺថ្ងៃគ្រប់គ្រាន់ដើម្បីធ្វើរស្មីសំយោគ។ ក្នុងដំណាក់កាលនេះ ស្លឹកឈើទាំងអស់ត្រូវជ្រុះ រលួយក្លាយជាចំណីត្រី និងធ្វើឱ្យបរិស្ថាននៃព្រៃលិចទឹកទាំងមូលមានជីវសាស្ត្រចម្រុះច្រើន។

ជារៀងរាល់ឆ្នាំ ព្រៃលិចទឹកបញ្ចេញបរិមាណសារធាតុបៃតង និងសារធាតុសរីរាង្គ (សំបក ឫស មែក និងផ្លែ) ជាច្រើន ដែលរលួយក្រោមឥទ្ធិពលនៃធម្មជាតិក្លាយទៅជាសារធាតុរ៉ែដូចជា កាល្យូម ប៉ូតាស្យូម ហ្វូសហ្វាត ស៊ុលហ្វាត ។ល។ ហើយបន្តបំបែកធាតុដោយអតិសុខុមប្រាណ ទៅជាអំបិល និងសារធាតុខនិជ សម្រាប់ការលូតលាស់របស់រុក្ខជាតិ និងរក្សាគុណភាពដីឱ្យល្អជាងមុន (ដីពណ៌ខ្មៅ)។ ក្រៅពីនេះព្រៃលិចទឹកជួយថែរក្សាគុណភាពទឹកដោយផ្តល់អុកស៊ីសែនទៅក្នុងទឹក ហើយស្រូបយកសារធាតុពុលដូចជានីត្រាត នីត្រូសែនឌីអុកស៊ីក និងកាល្យូមនីត្រាត។

នៅក្នុងតំបន់ទំនាបលិចទឹកមានគំទេចកំទីសរីរាង្គជាច្រើន ដែលមានប្រភពចេញពីព្រៃលិចទឹក និងព្រៃគុម្ពោតលិចទឹក ហើយនឹងផ្នែកខាងលើនៃរុក្ខជាតិ បានរលួយ រិវឌ្ឍន៍ជាពពួក សត្វ និងរុក្ខជាតិប្លង់តុង សម្រាប់ជាចំណីដល់ពពួកមច្ឆជាតិ។

នៅក្នុងខេត្តបន្ទាយមានជ័យ ព្រៃលិចទឹកដែលងាយឆេះគឺជាព្រៃគុម្ពោត/វនាមក្រាស់ មានគម្របព្រៃពី៧០ភាគរយទៅ៩០ភាគរយ និងកម្ពស់រហូតដល់ជិត៤ម៉ែត្រ។ ប្រភេទព្រៃគុម្ពោតរួមមាន ប្របួយ បាយដំណើប សុយ៉រ ថ្លើមអណ្តើក លៀង ទន្លា ទ្រទំអាអូដ្ឋ ភ្នំភ្លៀង ទៀនព្រៃ ញរទឹក ដង្កៀបក្តាម ភ្នែកក្រាប ។ល។)។ ដើមព្រៃលិចទឹកធំៗ (រាំង ខ្ទុំ ត្រស់ កន្សែង និងតួរ) មានដុះនៅរាយប៉ាយ ចម្ងាយប្រហែលជា២០-២៥ម៉ែត្រពីគ្នាក្នុងចន្លោះព្រៃគុម្ពោត។ នៅស្រទាប់ក្រោមនៃព្រៃគុម្ពោត មានតិណ្ឌជាតិ និងវល្លិ៍មួយចំនួន ហើយបន្លាយួនដុះច្រើននៅកន្លែងដែលគម្របព្រៃគុម្ពោតតិចជាង៥០ភាគរយ។ ជារួម ប្រភេទរុក្ខជាតិព្រៃគុម្ពោត រុក្ខជាតិស្រទាប់ក្រោម និងដើមបន្លាយួន នៅរដូវប្រាំងវានឹងក្រៀម និងជ្រុះស្លឹក ដូច្នេះព្រៃលិចទឹកប្រភេទបែបនេះងាយប្រឈមនឹងភ្លើងឆេះចាប់ពីខែមិនាទៅ។

នៅក្នុងតំបន់ព្រៃលិចទឹកដែលបានឆេះ២ ឬ៣ឆ្នាំមុន ស្ថិតនៅឆ្ងាយពីស្ទឹង/អូរ គេឃើញមានដំណុះធម្មជាតិដុះឡើងវិញជាច្រើន តែភាគច្រើនមានប្រភេទព្រៃគុម្ពោត និងបន្លាយួនដែលមានកម្ពស់ពី២-៣ម៉ែត្រ។ មានកូនរាំងតិចតួចណាស់ដុះលូតលាស់នៅក្រោមព្រៃគុម្ពោត និងដើមបន្លាយួន ជាមួយនឹងអត្រាលូតលាស់ទាប ដោយសារតែសម្ពាធនៃមីក្រូបរិយាកាស (ការដណ្តើមយកពន្លឺថ្ងៃ លំហ ទឹក និងអាហាររូបត្ថម្ភ)។ យោងទៅតាមថវិកាសម្រាប់ស្តារព្រៃលិចទឹកមានកំណត់ ស្ថានភាពរូបភូមិសាស្ត្រ និងជីវៈចម្រុះនៃតំបន់ព្រៃលិចទឹកដែលបានឆេះ វិធីសាស្ត្រស្តារព្រៃលិចទឹកនៅទីនោះគួរត្រូវពិចារណាលើជម្រើសពីរគឺ ការការពារ និងថែរក្សាដំណុះធម្មជាតិ និងការដាំកូនឈើព្រៃលិចទឹកនៅកន្លែងដែលមិនមាន ឬមានដើមមេពូជតិចតួច។

### ៤.៣.១ ការសិក្សាអំពីវិធីសាស្ត្រស្តារព្រៃលិចទឹកទៅតាមស្ថានភាពជាក់ស្តែង

**ក) ការសិក្សាអំពីវិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានឆេះ**

ការវាយតម្លៃតំបន់ភ្លើងឆេះព្រៃលិចទឹកដោយឆាប់រហ័សត្រូវបានអនុវត្ត ដើម្បីប្រមូលព័ត៌មានអំពីវិសាលភាពនៃការខូចខាត គូរផែនទីទីតាំងព្រៃលិចទឹកដែលត្រូវស្តារ ទិដ្ឋភាពភូមិសាស្ត្រ រូបវន្ត ជីវចម្រុះ និងអេកូឡូស៊ីនៃតំបន់ភ្លើងឆេះព្រៃលិចទឹក ប្រភេទពូជរុក្ខជាតិដែលត្រូវជ្រើសរើសសម្រាប់ដាំឡើងវិញ វិធីសាស្ត្រស្តារ និងការថែទាំដែលចំណាយតិច ដោយដាក់បញ្ចូលក្នុងផែនការស្តារព្រៃលិចទឹក និងចំណាយប៉ាន់ស្មាន។ ការវាយតម្លៃនេះនឹងត្រូវធ្វើឡើងនៅដើមរដូវប្រាំង (ខែធ្នូ ឬខែមករា) ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការរៀបចំ និងអនុវត្តការស្តារព្រៃលិចទឹកឡើងវិញ។

**ខ) ប្រជុំថ្នាក់ឃុំលើកទី១ដើម្បីរៀបចំផែនការស្តារព្រៃលិចទឹក**

នេះគឺជាការប្រជុំថ្នាក់ឃុំលើកទីមួយក្នុងចំណោមអ្នកពាក់ព័ន្ធរួមមាន សង្កាត់រដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ក្រុមល្បាតភ្លើងឆេះព្រៃ សហគមន៍នេសាទ និងអង្គការដៃគូមិនមែនរដ្ឋាភិបាល ដើម្បីពិភាក្សាអំពីផែនការសកម្មភាពស្តារព្រៃលិចទឹកដែលបានឆេះ ដោយសង្កត់ធ្ងន់ទៅលើការជ្រើសរើសទីតាំងស្តារ ការស្តារព្រៃលិចទឹកដោយការដាំកូនឈើព្រៃលិចទឹក និងដោយការការពារ និងថែរក្សាដំណុះធម្មជាតិ ការជ្រើសរើសប្រភេទរុក្ខជាតិព្រៃលិចទឹកសម្រាប់ដាំ ការបង្កើតថ្នាលបណ្តុះកូនឈើ ការផលិតកូនឈើដោយការបណ្តុះគ្រាប់ពូជ និងការប្រមូលកូនឈើព្រៃលិចទឹកធម្មជាតិ ការរៀបចំកន្លែងដាំកូនឈើ ការដឹកជញ្ជូនកូនឈើ ការកៀរគរប្រជាពលរដ្ឋឱ្យចូលរួមដាំកូនឈើ ការគាំទ្រ និងការតាមដានដំណើរការដាំកូនឈើ ការរៀបចំពិធីដាំដើមឈើ ការថែរក្សាកូនឈើដែលបានដាំ និងដំណុះធម្មជាតិ ការវាយតម្លៃអត្រារស់ និងលូតលាស់នៃកូនឈើ ការបង្កើតក្រុមការងារនៅមូលដ្ឋានដើម្បីគាំទ្រការស្តារព្រៃលិចទឹក តម្រូវការថវិកា និងការធ្វើរបាយការណ៍អំពីលទ្ធផលនៃការស្តារព្រៃលិចទឹក។

គ ) **ការកំណត់ព្រំប្រទល់ និងគូរផែនទីតំបន់ព្រៃលិចទឹកដែលត្រូវស្តារ**

មន្ត្រីខណ្ឌរដ្ឋបាលជលផល ធ្វើការជាមួយក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក និងសហគមន៍នេសាទ កំណត់ទីតាំងភ្លើងឆេះព្រៃលិចទឹកដែលត្រូវស្តារ និងប្រមូលនិយាមកាព្រំប្រទល់ដើម្បីគូរផែនទី បោះបង្គោល និងដាក់ស្លាកសញ្ញាតាមបណ្តោយព្រំប្រទល់ទីតាំងស្តារព្រៃលិចទឹក ដើម្បីទប់ស្កាត់ការប៉ុនប៉ងប្រើប្រាស់ដីក្នុងតំបន់នេះសម្រាប់ដាំស្រូវ ឬដំណាំផ្សេងៗ។ ផែនទីនេះត្រូវដាក់បញ្ចូលនិយាមកានៃចំណុចដែលត្រូវដាំបង្គោល និងដាក់ស្លាកសញ្ញា។

ជាមួយគ្នានេះ មេភូមិ និងមេឃុំគួរតែធ្វើការផ្សព្វផ្សាយជូនប្រជាពលរដ្ឋអំពីការកំណត់ និងការការពារតំបន់ភ្លើងឆេះព្រៃលិចទឹកទាំងអស់នៅក្នុងដែនរដ្ឋបាលគ្រប់គ្រងរបស់ខ្លួនសម្រាប់ការស្តារព្រៃលិចទឹក និងចាត់វិធានការតាមផ្លូវច្បាប់ចំពោះជនល្មើសណាដែលទន្ទ្រានដីព្រៃលិចទឹកធ្វើជាកម្មសិទ្ធិ តាមរយៈការប្រជុំនានានៅថ្នាក់ភូមិ និងថ្នាក់ឃុំ។

ឃ ) **ការការពារទីតាំងស្តារព្រៃលិចទឹក**

ការហាមឃាត់ និងការការពារទីតាំងស្តារព្រៃលិចទឹកពីការលែងសត្វគោ ក្របី ឱ្យចូលស៊ីស្មៅ គឺជាការចាំបាច់ព្រោះសត្វនឹងដើរជាន់បំផ្លាញកូនឈើព្រៃលិចទឹកតូចៗ ដូច្នេះត្រូវដាក់ស្លាកសញ្ញាដើម្បីជូនដំណឹងដល់អ្នកឃ្វាលគោក្របី អំពីការហាមឃាត់មិនឱ្យសត្វចូលក្នុងតំបន់ស្តារព្រៃលិចទឹក។ មេឃុំ និងមេភូមិពាក់ព័ន្ធទាំងអស់ ត្រូវជួយផ្សព្វផ្សាយព័ត៌មាន អំពីការការពារទីតាំងស្តារព្រៃលិចទឹកដល់ប្រជាពលរដ្ឋ ដើម្បីបង្កើនការចូលរួមក្នុងការស្តារព្រៃលិចទឹកសំដៅទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត។

ច ) **ការល្បាតតំបន់ស្តារព្រៃលិចទឹក**

ការល្បាតទីតាំងស្តារព្រៃលិចទឹកមានសារៈសំខាន់ណាស់ ដែលក្រុមល្បាតត្រូវបញ្ចូលទៅក្នុងផែនការល្បាតប្រចាំសប្តាហ៍ និងប្រចាំខែ ដើម្បីធានាថា ទីតាំងស្តារព្រៃលិចទឹកទាំងអស់មានសុវត្ថិភាព ជៀសផុតពីសកម្មភាពរំខាននានាដែលធ្វើឱ្យប៉ះពាល់ដល់ការរស់រាន និងលូតលាស់របស់កូនឈើ ដូចជាការលែងគោ ក្របីឱ្យស៊ីស្មៅ ការដាំដំណាំកសិកម្ម និងភ្លើងឆេះព្រៃជាដើម។

ទន្ទឹមនឹងនេះ នៅពេលត្រួតពិនិត្យទីតាំងស្តារព្រៃលិចទឹក ក្រុមល្បាតត្រូវរាយការណ៍ទៅនាយសង្កាត់រដ្ឋបាលជលផលសាមី អំពីផលប៉ះពាល់អវិជ្ជមានទៅលើកូនឈើដែលទើបនឹងដុះដូចជា ស្មៅក្រាស់ ឬកំប្លោកគ្របសង្កត់ពីលើកូនឈើ សត្វល្អិតបំផ្លាញកូនឈើ និងស្មៅរាតត្បាតធ្វើឱ្យកូនឈើស្រេស ឬងាប់ ដោយសារមិនមានពន្លឺថ្ងៃ ទឹក គម្លាត និងសារធាតុចិញ្ចឹមគ្រប់គ្រាន់ ដើម្បីចាត់វិធានការសង្គ្រោះកូនឈើតាមបែបសុវ្ឌ្ឍិកម្មព្រៃឈើដែលមានប្រយោជន៍ដល់ការធ្វើឱ្យប្រសើរឡើងនូវអត្រារស់ និងអត្រាកំណើនលូតលាស់នៃកូនឈើព្រៃលិចទឹក។

## ៤.៣.២ ការស្តារព្រៃលិចទឹកដោយវិធីសាស្ត្រជំនួយដំណុះធម្មជាតិ

ប្រសិនបើទីតាំងភ្លើងឆេះព្រៃលិចទឹកស្ថិតនៅក្បែរព្រៃលិចទឹកដែលមានដើមឈើពូជច្រើន ទីតាំងនោះមិនចាំបាច់ត្រូវស្តារឡើងវិញដោយការដាំកូនឈើបន្ថែមទេ ព្រោះថាដើមឈើមេពូជនឹងទម្លាក់ពង្រាយគ្រាប់ពូជពាសពេញទីតាំងព្រៃលិចទឹកដែលភ្លើងឆេះក្នុងខែធ្នូ និងមានកូនដំណុះធម្មជាតិក្នុងខែធ្នូ និងមករា បើសិនជាដីនៅសើម ប៉ុន្តែបើដីស្ងួត គ្រាប់ឈើព្រៃលិចទឹកនឹងពន្យារការចេញពន្លករហូតដល់ដើមរដូវវស្សា ក្រោយពីមានភ្លៀងធ្លាក់៣ ឬ៤ដង។ ទោះបីមានកូនដំណុះធម្មជាតិច្រើនក៏ដោយ ទីតាំងភ្លើងឆេះព្រៃលិចទឹកដែលត្រូវស្តារ ត្រូវការថែទាំ~~រក្សា~~ទៅតាមការណែនាំដូចខាងក្រោម៖

កូនឈើព្រៃលិចទឹកធម្មជាតិភាគច្រើនបានងាប់ក្រោមសម្ពាធនៃព្រៃស្បាត និងស្មៅក្រាស់ កំប្លោកជាន់ពេលទឹកស្រក និងភ្លើងឆេះព្រៃ។ ដូច្នេះការថែទាំ ឬរំដោះកូនឈើនៅក្នុងតំបន់ស្តារព្រៃលិចទឹកគឺត្រូវការសំអាតស្មៅក្នុងបរិវេណ១ម៉ែត្រជុំវិញវា ជាន់ពង្រាបស្មៅ យកចេញនូវកំប្លោកដែលគ្របសង្កត់លើកូនឈើ និងហាមឃាត់គោ និងក្របី

ចូលក្នុងទីតាំងស្តារព្រៃលិចទឹករយៈពេល៣ឆ្នាំដំបូងជាការជាចាំបាច់។ សកម្មភាពទាំងនេះមិនត្រឹមតែជួយសង្គ្រោះជីវិតកូនឈើពីសម្ពាធមីក្រូបរិយាកាសប៉ុណ្ណោះទេ ព្រមទាំងជួយបង្កើនការលូតលាស់នៃកូនឈើផងដែរ។

វិធីសាស្ត្រថែទាំកូនឈើបែបនេះហៅថា "ជំនួយដំណុះរុក្ខជាតិតាមបែបធម្មជាតិ "ដែលត្រូវអនុវត្តយ៉ាងតិចក្នុងរយៈពេល៣ឆ្នាំដំបូង ដើម្បីថែរក្សាកូនឈើឱ្យមានកម្លាំងគ្រប់គ្រាន់ ដើម្បីយកឈ្នះក្នុងការប្រកួតប្រជែងដណ្តើមយកពន្លឺថ្ងៃ លំហ ទឹក សារធាតុចិញ្ចឹម ប្រឆាំងនឹងស្មៅ និងរុក្ខជាតិនានាដែលនៅជុំវិញវា។

### ៤.៣.៣ ការស្តារព្រៃលិចទឹកដោយការដាំកូនឈើបន្ថែម

**ក) សិក្ខាសាលាស្តីពីការរៀបចំ និងការគ្រប់គ្រងថ្នាលបណ្តុះកូនឈើ និងវិធីសាស្ត្រស្តារព្រៃលិចទឹក**

មន្ត្រីជំនាញនៃរដ្ឋបាលជលផល សហការជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា ជាពិសេស អង្គការ FAO នឹងរៀបចំឯកសារ អំពីការគ្រប់គ្រងថ្នាលបណ្តុះកូនឈើព្រៃលិចទឹក និងវិធីសាស្ត្រស្តារព្រៃលិចទឹក។ ឯកសារនេះផ្តោតទៅលើ៖

- **ការគ្រប់គ្រងថ្នាលបណ្តុះកូនឈើ៖** ការជ្រើសរើសទីតាំង ការបង្កើតក្រុមបណ្តុះកូនឈើ (យ៉ាងតិច៤០ភាគរយនៃសមាជិកក្រុមជាស្ត្រី) ការគ្រោង និងសាងសង់ថ្នាលបណ្តុះកូនឈើខ្នាតតូច តម្រូវការសម្ភារសាងសង់ ការជ្រើសរើសដី ការលាយដីដាក់ក្នុងថង់ ការប្រមូលគ្រាប់ ការបណ្តុះគ្រាប់ ការប្រមូលកូនឈើដែលដុះដោយធម្មជាតិ ការថែទាំកូនឈើ ការដឹកជញ្ជូនកូនឈើ និងការកត់ត្រា។
- **វិធីសាស្ត្រស្តារព្រៃលិចទឹក៖** ការជ្រើសរើសទីតាំង ការផលិតផែនទីស្តារព្រៃលិចទឹក ការសិក្សាអំពីលក្ខណៈភូមិសាស្ត្រ រូបសាស្ត្រ ជីវៈចម្រុះ អេកូឡូស៊ីនៃទីតាំងស្តារព្រៃលិចទឹក ដើម្បីកំណត់វិធីសាស្ត្រស្តារព្រៃ ដូចជាជំនួយដំណុះធម្មជាតិ ការដាំជួស ការដាំបន្ថែម សមស្របទៅនឹងស្ថានភាពអេកូឡូស៊ី និងរូបវន្តនៃតំបន់ស្តារព្រៃលិចទឹកនីមួយៗ។ វិធីសាស្ត្រស្តារព្រៃលិចទឹកត្រូវគិតបញ្ចូលទាំងពេលវេលាអនុវត្ត ការរំដោះកូនឈើពីសម្ពាធរុក្ខជាតិដែលនៅជុំវិញ ការជ្រើសរើសប្រភេទកូនឈើដែលត្រូវដាំ គំលាតរវាងកូនឈើដែលត្រូវដាំ ទំហំ រណ្តៅ របៀបដាំ ការបង្កើតការងារក្រុមនៅមូលដ្ឋាន ដើម្បីជួយការងារស្តារព្រៃលិចទឹក ការការពារ និងថែទាំ និងទម្រង់ឯកសារសម្រាប់កត់ត្រាសកម្មភាពស្តារព្រៃលិចទឹក។

**ខ) ការគាំទ្រសហគមន៍លើការរៀបចំថ្នាលបណ្តុះកូនឈើព្រៃលិចទឹក**

កូនឈើព្រៃលិចទឹកសម្រាប់ការស្តារព្រៃលិចទឹក ត្រូវបានលើកទឹកចិត្តឱ្យមានការបណ្តុះដោយសហគមន៍នេសាទ ស្ថិតនៅក្បែរទីតាំងដាំស្តារ ព្រោះវាជាផ្នែកមួយនៃការអភិវឌ្ឍសមត្ថភាពសហគមន៍មូលដ្ឋានក្នុងការផលិតកូនឈើព្រៃលិចទឹក និងការធានានិរន្តរភាពនៃការស្តារព្រៃលិចទឹកឡើងវិញ។ ដូច្នេះមន្ត្រីខណ្ឌរដ្ឋបាលជលផលដែលបានចូលរួមសិក្ខាសាលា ត្រូវចុះទៅភូមិគោលដៅ ដើម្បីគាំទ្រសហគមន៍នេសាទរៀបចំថ្នាលបណ្តុះកូនឈើខ្នាតតូច និងផលិតកូនឈើព្រៃលិចទឹកទៅតាមការណែនាំដូចខាងក្រោម៖

- **ការជ្រើសរើសទីតាំងថ្នាលបណ្តុះកូនឈើព្រៃលិចទឹក៖** ជ្រើសរើសយកកន្លែងដែលសមស្របបំផុតសម្រាប់រៀបចំថ្នាលបណ្តុះកូនឈើ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំងថ្នាលបណ្តុះកូនឈើ រីឯទំហំនៃថ្នាលគឺអាស្រ័យទៅតាមចំនួនកូនឈើដែលនឹងត្រូវផលិត
- **ការបង្កើតក្រុមការងារបណ្តុះកូនឈើព្រៃលិចទឹក៖** យ៉ាងហោចណាស់ក៏មានមនុស្សយ៉ាងតិច១០នាក់ ក្នុងនោះស្ត្រីមានយ៉ាងតិច៥នាក់ ត្រូវបានជ្រើសរើស និងចងក្រងជាក្រុមបណ្តុះកូនឈើ។ រចនាសម្ព័ន្ធគ្រប់គ្រងថ្នាលបណ្តុះកូនឈើរួមទាំង តួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់សមាជិកក្រុម ការបែងចែកផលប្រយោជន៍ ត្រូវបានរៀបចំឡើងតាមរយៈការប្រជុំពិគ្រោះយោបល់ក្នុងចំណោមសមាជិកក្រុម ដើម្បីធានាថាការងារនេះត្រូវបានដំណើរការដោយរលូន និងមានតម្លាភាព

- **ការបង្កើនសមត្ថភាពក្រុមការងារថ្នាលបណ្ដុះកូនឈើ៖** ខណ្ឌរដ្ឋបាលជលផលនឹងផ្ដល់ការបណ្ដុះបណ្ដាលតាមរយៈការអនុវត្តផ្ទាល់ ស្ដីអំពីការគ្រប់គ្រងថ្នាលបណ្ដុះកូនឈើព្រៃលិចទឹក រួមទាំងសកម្មភាពតំឡើងថ្នាលបណ្ដុះកូនឈើ ការលាយដីច្រកថង់ ការប្រមូលគ្រាប់ពូជព្រៃលិចទឹក ការបណ្ដុះគ្រាប់ពូជ និងការថែរក្សាកូនឈើដល់សមាជិកទាំងអស់នៃក្រុមការងារបណ្ដុះកូនឈើដើម្បីធានាថា ក្រុមនេះអាចដំណើរការបណ្ដុះកូនឈើព្រៃលិចទឹកដោយខ្លួនឯងបាន។ នៅពេលជាមួយគ្នានេះដែរ មន្ត្រីខណ្ឌរដ្ឋបាលជលផលក៏ត្រូវផ្ដល់ចំណេះដឹងដល់ក្រុមការងារបណ្ដុះកូនឈើព្រៃលិចទឹកនូវការរៀបចំផែនការបណ្ដុះកូនឈើ រៀបចំបញ្ជី និងការកត់ត្រាតាមដានអំពីពេលវេលា និងសកម្មភាពដែលបានអនុវត្តដោយសមាជិកក្រុមនីមួយៗ សម្ភារដែលបានប្រើប្រាស់សម្រាប់ការងារបណ្ដុះកូនឈើ ចំនួនកូនឈើតាមប្រភេទ និងការចំណាយ។ ដោយសារតែសម្ភារសម្រាប់ការងារបណ្ដុះកូនឈើ ដែលអាចរកបាននៅមូលដ្ឋាននៅមានកម្រិត ខណ្ឌរដ្ឋបាលជលផលគួរតែផ្ដល់នូវសម្ភារមួយចំនួនដូចជា សំណាញ់ សសរឈើ ថង់ប្លាស្ទិច ធុងស្រោចទឹក ខ្សែលួស និងដី ដូចបានលើកឡើងក្នុងការបណ្ដុះបណ្ដាលដើម្បីគាំទ្រដល់ការរៀបចំថ្នាល និងបណ្ដុះកូនឈើព្រៃលិចទឹក។
- **ការគាំទ្របច្ចេកទេសដល់ក្រុមការងារបណ្ដុះកូនឈើ៖** ខណ្ឌរដ្ឋបាលជលផលត្រូវចាត់តាំងមន្ត្រីបង្គោលម្នាក់ចុះជួយក្រុមបណ្ដុះកូនឈើជាប្រចាំ ដើម្បីរៀបចំថ្នាលបណ្ដុះ និងថែរក្សាកូនឈើព្រៃលិចទឹកទៅតាមដំណាក់កាលជាក់ស្ដែង។

**គ) ការប្រជុំថ្នាក់ឃុំលើកទី២ដើម្បីរៀបចំផែនការសកម្មភាពស្ដារព្រៃលិចទឹក**

កិច្ចប្រជុំពិគ្រោះយោបល់លើកទី២នៅថ្នាក់ឃុំដើម្បីពិនិត្យ និងបញ្ចប់ផែនការស្ដារព្រៃលិចទឹកដែលបានរៀបចំក្នុងកិច្ចប្រជុំលើកទី១ គឺជាការចាំបាច់ដើម្បីយកផែនការនេះទៅអនុវត្តនៅខែបន្ទាប់។ កិច្ចប្រជុំនេះត្រូវពិនិត្យមើលលើការរៀបចំការងារនៅមូលដ្ឋាន ដែលបានបញ្ជាក់ក្នុងកិច្ច ប្រជុំលើកទី១ និងបញ្ជាក់អំពីការកៀរគរសហគមន៍មូលដ្ឋានឱ្យចូលរួមក្នុងព្រឹត្តិការណ៍ដាំកូនឈើនា។ អ្នកចូលរួមនៃកិច្ចប្រជុំនេះរួមមាន ក្រុមការងារមកពីខណ្ឌរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន សហគមន៍នេសាទ ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក និងក្រុមផលិតកូនឈើព្រៃលិចទឹក ព្រមទាំងអង្គការដៃគូ។

**ឃ) ការរៀបចំពិធីដាំកូនឈើព្រៃលិចទឹក**

ពិធីដាំឈើកូនឈើព្រៃលិចទឹក គួរត្រូវបានរៀបចំឡើងនៅក្នុងស្រុកគោលដៅនីមួយៗ ដើម្បីផ្សព្វផ្សាយឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ព្រមទាំងការស្ដារព្រៃលិចទឹកឡើងវិញសំដៅលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការទប់ស្កាត់ ការពារ ការស្ដារ និងការថែរក្សាព្រៃលិចទឹក។ ពិធីដាំព្រៃលិចទឹកនេះ នឹងប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់លោកអភិបាលស្រុក ឬតំណាង។

យ៉ាងណាមិញ ការចូលរួមជាគណៈអធិបតីរបស់ឯកឧត្តមអភិបាលខេត្ត និងឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលនឹងធ្វើឱ្យព្រឹត្តិការណ៍នេះកាន់តែមានសារៈសំខាន់ជាប្រវត្តិសាស្ត្រ និងត្រូវបានគេចាត់ទុកថាជាយុទ្ធនាការផ្សព្វផ្សាយដ៏ទូលំទូលាយសម្រាប់ការគ្រប់គ្រងធនធានជលផល និងការស្ដារព្រៃឈើលិចទឹកនៅទូទាំងប្រទេសកម្ពុជា។

ព័ត៌មាន សារ និងរូបភាពនៃពិធីដាំកូនឈើព្រៃលិចទឹក ត្រូវបានចែករំលែកឱ្យបានទូលំទូលាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈ ដូចជា ទូរទស្សន៍ វិទ្យុ ហ្វេសប៊ុក តេឡេក្រាម ។ល។ ដែលជាផ្នែកមួយនៃការអប់រំ បង្កើនការយល់ដឹងសាធារណៈ អំពីការគ្រប់គ្រងធនធានជលផល ជាពិសេសការគ្រប់គ្រងព្រៃលិចទឹកក្នុងតំបន់បឹងទន្លេសាប។

ខណ្ឌរដ្ឋបាលជលផលនឹងពិភាក្សាជាមួយអាជ្ញាធរស្រុក និងឃុំដើម្បីរៀបចំពិធីដាំកូនឈើព្រៃលិចទឹកនេះ រួមមាន ការអញ្ជើញភ្ញៀវកិត្តិយស ការរៀបចំទីកន្លែង និងវេទិកា ការដឹកជញ្ជូនកូនឈើ ការធ្វើពិធីការ សម្ភារសម្រាប់ដាំកូនឈើ អាហារសម្រន់ ការចែកចាយព័ត៌មានតាមប្រព័ន្ធផ្សព្វផ្សាយ សាធារណៈ និងភស្តុភារ។

**ង) ការគាំទ្រ និងត្រួតពិនិត្យការដាំកូនឈើព្រៃលិចទឹក**

ដើម្បីធានាថាការដាំកូនឈើព្រៃលិចទឹកអនុវត្តបានល្អ ក្រោយពីបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលាស្តីពី "**ការគ្រប់គ្រងថ្នាលបណ្តុះកូនឈើព្រៃលិចទឹក និងវិធីសាស្ត្រស្តារព្រៃលិចទឹក**" មន្ត្រីខណ្ឌរដ្ឋបាលជលផលដែលទទួលបន្ទុកគាំទ្រ និងត្រួតពិនិត្យការដាំកូនឈើព្រៃលិចទឹក ត្រូវអនុវត្តនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

- រំលឹកដោយសង្ខេបនូវបច្ចេកទេសដាំកូនឈើ ដោយបញ្ជាក់ពីការដឹកជញ្ជូនកូនឈើព្រៃលិចទឹកដោយសុវត្ថិភាព ទំហំរណ្តៅដែលត្រូវជីក គម្លាតនៃរណ្តៅ ការជីក ការហែកថង់ ការដាំ ការលុបរណ្តៅ ការបង្ហាប់ដីក្នុងរណ្តៅ ការពង្រឹងដើម និងការស្រោចទឹកបើសិនជាដីស្ងួតពេក
- ដោតកំណាត់ឈើ ឬឫស្សីដើម្បីសម្គាល់ចំណុចដែលត្រូវជីករណ្តៅ ជៀសវាងការដាំជិតគ្នាពេក នៅក្រោមម្លប់ដើមឈើ ឬក្នុងព្រៃគុម្ពោត
- ការដឹកកូនឈើពីថ្នាលទៅកន្លែងដាំត្រូវកត់ត្រាចំនួនកូនឈើតាមប្រភេទ និងចំនួនកូនឈើដែលបានខូចខាតក្នុងអំឡុងពេលដឹកជញ្ជូនដោយគោយន្ត ឬដោយទូក
- បែងចែកតំបន់ស្តារព្រៃលិចទឹកជាអនុតំបន់ សម្រាប់ដាំកូនឈើទៅតាមក្រុម ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យដោយក្រុមការងារដាំកូនឈើនៅមូលដ្ឋាន។ វិធីសាស្ត្រនេះនឹងជួយសម្រួលក្រុមការងារក្នុងការកំណត់ចំនួនកូនឈើដែលបានដាំ ចំនួនកូនឈើដែលបានដាំមិនត្រូវបច្ចេកទេស ចំនួនកូនឈើដែលបានខូចនៅពេលដាំ។ ក្រុមការងារដែលទទួលខុសត្រូវក្នុងការដាំនេះ ត្រូវធ្វើការដាំជួសឡើងវិញ
- គាំទ្រ និងតាមដានការដាំដើមឈើព្រៃលិចទឹកដោយប្រជាសហគមន៍ ដើម្បីធានាឱ្យបាននូវទំហំរណ្តៅដែលបានជីក ការដាំ និងការលប់រណ្តៅ ការពង្រឹងដើមកូនឈើ និងការប្រមូលថង់កូនឈើត្រូវបានអនុវត្តសមស្របទៅតាមការណែនាំ និងបទដ្ឋានបច្ចេកទេស
- មន្ត្រីបង្គោលនៃខណ្ឌរដ្ឋបាលជលផល នឹងរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការដាំកូនឈើ បន្ទាប់ពីការដាំកូនដើមឈើត្រូវបានបញ្ចប់។ របាយការណ៍នេះត្រូវបានពិនិត្យ និងឯកភាពដោយប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងចម្លងជូនក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត និងស្រុក និងមេឃុំពាក់ព័ន្ធ ដើម្បីជ្រាបជាព័ត៌មាន។

**ច) ការថែរក្សាទីតាំងស្តារព្រៃលិចទឹក**

ដើម្បីធានាបាននូវអត្រារស់ និងអត្រាលូតលាស់ខ្ពស់ ទាំងកូនឈើដែលបានដាំ និងកូនឈើដែលដុះដោយធម្មជាតិ (ដំណុះធម្មជាតិ) ទីតាំងស្តារព្រៃលិចទឹកចាំបាច់ត្រូវតែថែទាំ។ ផ្អែកលើស្ថានភាពជាក់ស្តែង និងជីវៈចម្រុះនៅក្នុងទីតាំងស្តារព្រៃលិចទឹក វិធីសាស្ត្រមួយចំនួននឹងត្រូវបានអនុវត្តដើម្បីថែទាំកូនឈើដាំ និងដំណុះធម្មជាតិនៅទីនោះ គឺ ការការពារតំបន់ស្តារព្រៃលិចទឹកពីការទន្ទ្រានយកដីដាំដំណាំ ការលុកលុយរបស់សត្វគោ ក្របី រំដោះកូនឈើឱ្យរួចផុតពីការសង្កត់ដោយស្មៅ ឬកំប្លោក និងការការពារកុំឱ្យមានភ្លើងឆេះព្រៃម្តងទៀត។ បច្ចេកទេសលម្អិតសម្រាប់ការការពារ និងថែរក្សាទីតាំងស្តារព្រៃលិចទឹកនឹងត្រូវបានដាក់បញ្ចូលនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពី **ការគ្រប់គ្រងថ្នាលបណ្តុះកូនឈើ និងវិធីសាស្ត្រស្តារព្រៃលិចទឹក**សម្រាប់មន្ត្រីបង្គោលរបស់ខណ្ឌរដ្ឋបាលជលផល។

### ឆ) ការវាយតម្លៃអត្រារស់ និងលូតលាស់នៃកូនឈើក្នុងទីតាំងស្តារព្រៃលិចទឹក

សកម្មភាពនេះមានការចាំបាច់ណាស់ក្នុងការត្រួតពិនិត្យអត្រារស់ និងអត្រាលូតលាស់របស់កូនឈើនៅដើមរដូវប្រាំងឆ្នាំទី២នៃអាយុកូនឈើព្រៃលិចទឹក ដើម្បីឱ្យបានដឹងពីអត្រាងាប់ រស់ និងលូតលាស់របស់កូនឈើតាមប្រភេទ និងទីតាំង។ ការវាយតម្លៃនេះគួរអនុវត្តរាល់២ឆ្នាំម្តង នៅលើទីតាំងសំណាកដដែល។

គោលបំណងចម្បងនៃការវាយតម្លៃនេះគឺ ការស្វែងយល់អំពីកត្តាដែលនាំឱ្យកូនឈើងាប់ និងលូតលាស់យឺត និងផ្តល់អនុសាសន៍អំពីវិធីសាស្ត្រដើម្បីធ្វើឱ្យកូនឈើដែលបានដាំ និងត្រូវដាំនៅពេលខាងមុខ មានអត្រារស់ និងកំណើនលូតលាស់ខ្ពស់ជាងមុន ទៅតាមល័ក្ខខ័ណ្ឌភូមិសាស្ត្រ និងជីវសាស្ត្រជាក់ស្តែងនៃតំបន់នីមួយៗ ដូចជាការការពារទីតាំងស្តារព្រៃលិចទឹកពីសកម្មភាពរំខាននានា ការការពារភ្លើងឆេះព្រៃ ការដាំជួស ការដាំបន្ថែម ការថែទាំ ការរំដោះកូនឈើ ។ល។

## ៦. សមភាពយេនឌ័រក្នុងការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក

នៅក្នុងការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ការបញ្ជ្រាបយេនឌ័រ និងការការពារកុមារនឹងត្រូវបានយកចិត្តទុកដាក់នៅគ្រប់សកម្មភាព រួមមាន ដំណើរការរៀបចំផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យការអនុវត្តនេះ ដោយអនុលោមតាមក្របខ័ណ្ឌការងារស្តីពីសមភាពយេនឌ័ររបស់រដ្ឋបាលជលផល នៃក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ ជាពិសេស ផែនការសកម្មភាពរបស់រដ្ឋបាលជលផលសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ និងកុមារ និងការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល (ឆ្នាំ២០១៦-២០២០)។

ដើម្បីរួមចំណែកលើកកម្ពស់ក្នុងការចូលរួមដោយសមភាពរវាងបុរស និងស្ត្រីនៅក្នុងសកម្មភាព និងការសម្រេចចិត្តនៅក្នុងក្រុមការងារទាំងបីថ្នាក់ (ឃុំ/សង្កាត់ ស្រុក/ក្រុង ខេត្ត) ជាពិសេសនៅថ្នាក់ឃុំ/សង្កាត់ដែលជាអ្នកអនុវត្តគម្រោងផ្ទាល់ នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល នឹងធ្វើការសម្របសម្រួលជាមួយក្រុមការងារយេនឌ័រនៃរដ្ឋបាលជលផល ដើម្បីធានាថា ផលប៉ះពាល់អវិជ្ជមាននៃវិសមភាពយេនឌ័រត្រូវបានដោះស្រាយនៅក្នុងការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដោយផ្តល់ឱកាសស្មើភាពគ្នារវាងបុរស និងស្ត្រី នៅក្នុងសមាសភាពរចនាសម្ព័ន្ធគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ស្រុក/ក្រុង និងឃុំ/សង្កាត់ ព្រមទាំងការគិតគូរពិចារណាអំពីតម្រូវការ និងឧបសគ្គរបស់ស្ត្រីនៅក្នុងដំណើរការអនុវត្តផែនការនេះ។

ការពិចារណាមួយចំនួនទាក់ទងនឹងការកំណត់យន្តការអនុវត្តច្បាស់លាស់ ដើម្បីសម្រេចបាននូវសមភាពយេនឌ័រតាមរយៈការផ្សព្វផ្សាយ សេវាកម្ម និងការគាំទ្រផ្លូវច្បាប់ មានដូចខាងក្រោម៖

- ធានាឱ្យមានការចូលរួមស្មើភាពគ្នារវាងស្ត្រី និងបយរសនៅក្នុងគ្រប់សកម្មភាពនៃការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងដំណើរការធ្វើសេចក្តីសម្រេចចិត្ត (ការរៀបចំផែនការ ការអនុវត្តសកម្មភាព និងការត្រួតពិនិត្យ) ដោយបញ្ជាក់ពីបន្ទុកការងាររបស់ស្ត្រីក្នុងការងារនេះ
- លើកទឹកចិត្តស្ត្រីឱ្យចូលរួមយ៉ាងសកម្ម នៅក្នុងក្រុមការងារទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ខេត្ត ក្រុង/ស្រុក ឃុំ/សង្កាត់ ដោយយកចិត្តទុកដាក់ចំពោះគោលបំណង និងផលប្រយោជន៍របស់ពួកគេ
- ផ្តល់ឱកាសស្មើភាពគ្នាដល់ស្ត្រី ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលជំនាញពិចារណាអំពីតម្រូវការ និងចំណាប់អារម្មណ៍របស់ពួកគេ
- ការជំរុញការអនុវត្តបច្ចេកវិទ្យាដែលសមស្របទៅនឹងការងាររបស់ស្ត្រី
- ការពារកុមារដែលមានអាយុក្រោម១៨ឆ្នាំ និងស្ត្រីមានផ្ទៃពោះពីការងារដែលអាចបង្កឱ្យមានគ្រោះថ្នាក់ និងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ និងជំនាញសម្រាប់យុវជន ដោយធានាបាននូវសុខភាព

និងសុវត្ថិភាពការងារទាំងនៅកន្លែងធ្វើការ និងនៅមូលដ្ឋានបង្ហាញពីតួនាទីដ៏មានតម្លៃរបស់ស្ត្រី និង បុរស នៅក្នុងវិស័យជលផល និងការអភិរក្សនៅក្នុងយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដោយមានការចូលរួម។

## ៧. ក្របខណ្ឌការងារនៃការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក

បច្ចុប្បន្ននេះ ខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ មិនទាន់មានផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកច្បាស់លាស់ ហើយក៏ពុំមានធនធានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងភ្លើងឆេះព្រៃលិចទឹកដែរ។ ព័ត៌មានអំពីភ្លើងឆេះព្រៃលិចទឹកជាច្រើនករណីត្រូវបានចែករំលែក និងរាយការណ៍ដោយសហគមន៍នេសាទ និងប្រជាពលរដ្ឋមូលដ្ឋានជូនអង្គភាពពាក់ព័ន្ធ ជាពិសេសខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែមិនមានការអន្តរាគមន៍បន្ទាន់ណាមួយបានអនុវត្តដោយមានប្រសិទ្ធភាពក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលបានរាយការណ៍នោះទេ ដោយសារទីតាំងឆេះស្ថិតនៅឆ្ងាយ មិនមានផ្លូវចេញចូល ព្រមទាំងមិនមានកម្លាំង ថវិកា និងឧបករណ៍គ្រប់គ្រាន់។ ថ្មីៗនេះ នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល នៃរដ្ឋបាលជលផល បានផ្តល់ជូននូវបំពង់ពន្លត់អគ្គិភ័យមួយចំនួនដល់សហគមន៍នេសាទ តាមរយៈខណ្ឌរដ្ឋបាលជលផល សម្រាប់ប្រើប្រាស់ពន្លត់ភ្លើងឆេះព្រៃលិចទឹក។

ដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដែលបានអនុវត្តកន្លងមកដោយអង្គភាពពាក់ព័ន្ធ នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល សហការជាមួយអង្គការ FAO នៃគម្រោង CAPFIS-Cature បានរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដែលមានរយៈពេល៥ឆ្នាំ (ឆ្នាំ២០២២-២០២៦) ជាមួយនឹងក្របខ័ណ្ឌការងារដូចខាងក្រោម។

### ៧.១ ពេលវេលាអនុវត្ត

ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក មានរយៈពេល៥ឆ្នាំ (ឆ្នាំ២០២២-២០២៦)។

### ៧.២ គោលបំណង

ព្រៃលិចទឹកក្នុងខេត្តបន្ទាយមានជ័យត្រូវបានគ្រប់គ្រង និងការពារបានល្អ ហើយគម្របព្រៃលិចទឹកបានកើនឡើងក្រោមការគ្រប់គ្រងរបស់យន្តការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកដ៏មានប្រសិទ្ធភាពនៅថ្នាក់ខេត្ត ស្រុក និងឃុំ ដោយមានការចូលរួមពីស្ថាប័ន/អង្គភាពពាក់ព័ន្ធទាំងអស់។

### ៧.៣ គោលដៅ

ដើម្បីឆ្លើយតបនឹងគោលបំណងខាងលើ ការសម្រេចបាននូវគោលដៅមួយចំនួនខាងក្រោមនេះនឹងចូលរួមចំណែកយ៉ាងសំខាន់ដើម្បីឈានដល់គោលបំណងដែលបានកំណត់៖

- ការយល់ដឹង និងការចូលរួមក្នុងការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹករបស់សហគមន៍ និងស្ថាប័ន/អង្គភាពពាក់ព័ន្ធត្រូវបានលើកកម្ពស់
- ផ្ទៃដីព្រៃលិចទឹក និងវាលស្មៅដែលរងផលប៉ះពាល់ដោយភ្លើងឆេះព្រៃបានថយចុះជាអតិបរមា
- ទីតាំងព្រៃលិចទឹកទាំងអស់ដែលរងការខូចខាតដោយភ្លើងឆេះ ត្រូវបានស្តារ តាមរយៈការការពារ ថែទាំ និងដាំកូនឈើឡើងវិញ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ទាំងប្រព័ន្ធអេកូឡូស៊ី និងប្រភពអាហារសរីរាង្គដែលមានសារធាតុចិញ្ចឹមខ្ពស់។

## ៧.៤ លទ្ធផលរំពឹងទុក

**<u>លទ្ធផលទី១៖</u> ការពិនិត្យឡើងវិញ ការកាត់បន្ថយហានិយភ័យ និងការត្រៀមរួចជាស្រេចសម្រាប់ទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកដ៏មានប្រសិទ្ធភាពបានរៀបចំឡើង**

លទ្ធផលទី១ឆ្លើយតបនឹង 3"R" នៅក្នុង 5"R" គឺការពិនិត្យឡើងវិញនូវបញ្ហាប្រឈមនៃភ្លើងឆេះព្រៃលិចទឹក ការកាត់បន្ថយហានិភ័យនៃភ្លើងឆេះព្រៃ និងការត្រៀមកម្លាំង និងសម្ភាររួចជាស្រេចដើម្បីធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃជាបន្ទាន់ ដោយមានកិច្ចសហការល្អជាមួយអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ និងសហគមន៍មូលដ្ឋាន។

សកម្មភាពដែលបានគ្រោងនឹងអនុវត្តដើម្បីសម្រេចបាននូវលទ្ធផលទី១នេះរួមមាន៖ ការប្រជុំជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីពិភាក្សាអំពីការបង្កើតក្រុមការងារទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក និងខេត្ត ការបង្កើតក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំ តម្រូវការសម្ភារផ្សព្វផ្សាយ ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់សហគមន៍មូលដ្ឋាន ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃ វគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសពន្លត់ភ្លើងឆេះព្រៃលិចទឹក ការគាំទ្រ និងពង្រឹងការងារល្បាតភ្លើងឆេះព្រៃលិចទឹក និងការពង្រឹងការអនុវត្តច្បាប់ជលផល ដើម្បីទប់ស្កាត់ការកាប់ទន្រ្ទានព្រៃលិចទឹក និងការបង្កឱ្យមានភ្លើងឆេះព្រៃ។

**<u>លទ្ធផលទី២៖</u> វិធានការ និងសកម្មភាពពន្លត់ភ្លើងឆេះព្រៃលិចទឹកមានភាពប្រសើរជាងមុន**

លទ្ធផលទី២នេះ ផ្តោតលើការសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ សហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងមូលដ្ឋាន ដើម្បីទទួលបាននូវការអន្តរាគមន៍ដ៏ឆាប់រហ័សក្នុងការពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលកំពុងឆេះ និងការគំរាមកំហែងលើព្រៃលិចទឹក និងវាលស្មៅឱ្យបានទាន់ពេលវេលា។ លទ្ធផលនេះក៏មានគោលបំណងពង្រឹងការអនុវត្តច្បាប់ជលផល និងបង្កើនតួលេខនៃភាពជោគជ័យចំពោះការកាត់ទោសលើជនល្មើសដែលអនុវត្តសកម្មភាពខុសច្បាប់នៅក្នុងតំបន់ព្រៃលិចទឹក ទាំងនៅក្នុង និងក្រៅប្រព័ន្ធតុលាការ។

**<u>លទ្ធផលទី៣៖</u> ព្រៃលិចទឹកដែលបានឆេះទាំងអស់បានស្តារឡើងវិញ**

លទ្ធផលទី៣គឺ ផ្តោតលើការធ្វើឱ្យគម្របព្រៃលិចទឹកមានភាពប្រសើរឡើងវិញនៅក្នុងតំបន់ព្រៃលិចទឹកដែលរងផលប៉ះពាល់ដោយភ្លើងឆេះ តាមរយៈការស្តារឡើងវិញតាមវិធីសាស្ត្រផ្សេងៗគ្នា ដូចជា ការការពារ និងទប់ស្កាត់ការទន្រ្ទានយកដីធ្វើកសិកម្ម ការលែងគោ ក្របីឱ្យស៊ីស្មៅនៅក្នុងតំបន់ស្តារព្រៃលិចទឹក ការទប់ស្កាត់កុំឱ្យមានភ្លើងឆេះព្រៃលិចទឹកកើតមានម្តងទៀត ដើម្បីទុកឱ្យរុក្ខជាតិដុះឡើងវិញតាមបែបធម្មជាតិ ការថែរក្សាកូនឈើនៅក្នុងតំបន់ស្តារព្រៃលិចទឹកតាមរយៈជំនួយដំណុះរុក្ខជាតិតាមបែបធម្មជាតិ និងការដាំឡើងវិញ។

## ៧.៥ ថវិកាប៉ាន់ស្មានសរុប

ថវិកាសម្រាប់អនុវត្តផែនការសកម្មភាពរយៈពេល៥ឆ្នាំ បានប៉ាន់ស្មានថាមានចំនួនប្រហែល៤៨០.៣៥០ដុល្លារអាមេរិក។

ផែនការនេះត្រូវបានចងក្រងដោយអនុលោមតាមគោលការណ៍ណែនាំស្តីពី **ការរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅក្នុងតំបន់បឹងទន្លេសាប** របស់គម្រោង CAPFISH-Capture និងគោលការណ៍ 5"R"៖ ការពិនិត្យឡើងវិញ (Review) ការកាត់បន្ថយហានិភ័យ (Risk Reduction) ភាពត្រៀមខ្លួនរួចជាស្រាច់ (Readiness) ការឆ្លើយតបទៅនឹងភ្លើងឆេះព្រៃ (Response) និងការស្តារឡើងវិញព្រៃលិចទឹកដែលរេចរឹលដោយសារភ្លើងឆេះព្រៃ (Recovery/ Restoration)។ គោលការណ៍នេះមានប្រយោជន៍ខ្លាំងណាស់សម្រាប់ការសរសេរផែនការទប់ស្កាត់ និង

គ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដើម្បីផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់អ្នកអនុវត្តដំណើរការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ព្រមទាំងការស្តារព្រៃលិចទឹកឡើងវិញ ដើម្បីធានាបាននូវការសម្រេចលទ្ធផលរំពឹងទុកទាំងបីខាងលើ។

ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកក៏ត្រូវបានបង្កើតឡើង ដោយផ្អែកទៅលើផែនការគ្រប់គ្រងរបស់សហគមន៍នេសាទ ដែលជាវិធីសាស្រ្តមួយបញ្ជ្រាបការសម្រេចចិត្តរបស់សហគមន៍ទៅក្នុងការអនុវត្តផែនការនេះ តាមរយៈការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទ។ ផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក មិនត្រឹមតែធ្វើឱ្យអង្គភាពពាក់ព័ន្ធទាំងអស់ ជាពិសេសសហគមន៍មូលដ្ឋាន ចូលរួមក្នុងយុទ្ធសាស្រ្តទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ព្រមទាំងវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសល្បាត និងពន្លត់ភ្លើងឆេះព្រៃលិចទឹកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនការយល់ដឹងអំពីផលប៉ះពាល់ដែលបណ្តាលមកពីភ្លើងឆេះព្រៃលិចទឹក វិធីសាស្រ្តស្តារព្រៃលិចទឹកដែលបានឆេះ និងលិខិតបទដ្ឋានគតិយុទ្ធដែលទាក់ទងនឹងការកាប់ឈូសឆាយព្រៃលិចទឹកដែលមានចែងក្នុងមាត្រាទី២៦ ២៧ និង ២៨ ជំពូកទី៦ និងមាត្រាទី៩៨ ជំពូកទី១៥ នៃច្បាប់ស្តីពីជលផល ព្រមទាំងអនុក្រឹត្យលេខ១៩៧ អនក្រ.បក ស្តីពីការកំណត់ដែនព្រៃលិចទឹកនៅក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប ។

ទាំងបុរស និងស្រ្តី ជាពិសេសក្រុមដែលងាយរងគ្រោះថ្នាក់ដោយសារភ្លើងឆេះព្រៃលិចទឹក មានតួនាទីសំខាន់ដូចគ្នាក្នុងការចូលរួមអនុវត្តដំណាក់កាលទាំង៥ (5Rs) នៃការទប់ស្កាត់ភ្លើង និងគ្រប់គ្រងឆេះព្រៃលិចទឹក។ ទោះបីយ៉ាងនេះក្តី នៅក្នុងបរិបទនេះ ការការពារស្រ្តី និងកុមារពីការងារដែលអាចបង្កឱ្យមានគ្រោះថ្នាក់ដោយភ្លើងឆេះព្រៃលិចទឹកត្រូវតែបានធានា។

មួយវិញទៀត សហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន ត្រូវរកវិធីសាស្រ្តសមស្រប ដើម្បីឱ្យប្រជាពលរដ្ឋយល់ដឹងអំពីសារៈសំខាន់នៃការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ដែលផ្សារភ្ជាប់នឹងធនធានជលផលនៅក្នុងតំបន់ ដោយហេតុថា សហគមន៍មូលដ្ឋានដែលរស់នៅក្នុងតំបន់នោះពឹងផ្អែកទាំងស្រុងទៅលើធនធានជលផល រួមទាំងការប្រើប្រាស់ដីសម្រាប់ផលិតកម្មកសិកម្មនៅក្នុងតំបន់ទាំងមូល។

## ៨. ការត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន និងវាយតម្លៃការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ត្រូវអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ។ ទន្ទឹមនឹងនេះ ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃមួយត្រូវបានបង្កើតឡើង ដោយមានសមាសភាពមកពីតំណាងអង្គភាពពាក់ព័ន្ធសំខាន់ៗនៅថ្នាក់ជាតិ និងក្រោមជាតិរួមមាន៖

- **ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិ៖** នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល នៃរដ្ឋបាលជលផលរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា។
- **អង្គភាពពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ៖** អាជ្ញាធរមូលដ្ឋាន (ថ្នាក់ខេត្ត ស្រុក និងឃុំ) មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខណ្ឌរដ្ឋបាលជលផល មន្ទីរពាក់ព័ន្ធ សហគមន៍នេសាទ និងដៃគូអភិវឌ្ឍន៍នានាក្នុងខេត្តបន្ទាយមានជ័យ។

រដ្ឋបាលជលផលត្រូវការទិន្នន័យ និងព័ត៌មានដើមបន្ថែម ដើម្បីប្រើប្រាស់ក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តផែនការនេះ។ ដើម្បីទទួលបានទិន្នន័យ និងព័ត៌មាននេះ រដ្ឋបាលជលផលត្រូវការការគាំទ្រទាំងបច្ចេកទេស និងថវិកាពីដៃគូអភិវឌ្ឍន៍នានា។

ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនឹងត្រូវបានអនុវត្តដោយក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីឱ្យដឹងអំពីកម្រិតនៃគោលបំណង និងគោលដៅរបស់ផែនការដែលសម្រេចបាន ប្រសិទ្ធភាពនៃការចំណាយ និងការអនុវត្តផែនការនេះនៅក្នុងខេត្តបន្ទាយមានជ័យ។

លើសពីនេះទៅទៀត ក្រុមការងារត្រួតពិនិត្យ និងវាយតម្លៃត្រូវប្រមូលព័ត៌មានថ្មីៗ អំពីចំនួនករណីភ្លើងឆេះព្រៃ ទីតាំង និងទំហំព្រៃលិចទឹកដែលបានឆេះ ប្រភេទរុក្ខជាតិដែលរងការឆេះ ជនសង្ស័យដែលពាក់ព័ន្ធនឹងការបង្កឱ្យមានភ្លើងឆេះព្រៃ កម្លាំងមនុស្ស ឧបករណ៍ដែលបានប្រើប្រាស់ ប្រសិទ្ធភាពនៃការធ្វើអន្តរាគមន៍ និងការចំណាយជាក់ស្តែង។ល។ ព្រមទាំងផ្តល់អនុសាសន៍ ជួយ តម្រែតម្រង់ទិសដល់ការអនុវត្តផែនការឱ្យមានភាពល្អប្រសើរជាងមុន។

ការវាយតម្លៃផ្ទៃក្នុងនឹងត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ រីឯការវាយតម្លៃដោយអ្នកជំនាញមកពីខាងក្រៅ គួរត្រូវបានធ្វើ២ដងគឺ នៅពាក់កណ្តាលអាណត្តិ និងនៅមុនពេលបញ្ចប់ការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ នាយកដ្ឋានអភិរក្សជលផល និងនាយកដ្ឋានកិច្ចការជលផល ជាអ្នករៀបចំសេចក្តីព្រាងអំពីតួនាទី និងភារកិច្ចរបស់អ្នកជំនាញវាយតម្លៃមកពីខាងក្រៅ និងគ្រប់គ្រងដំណើរការជ្រើសរើសអ្នកជំនាញ ដោយមានកិច្ចសហការ និងគាំទ្រដោយអង្គការ FAO។ លទ្ធផលដែលទទួលបានពីការវាយតម្លៃនឹងត្រូវបានប្រើប្រាស់ដើម្បីបង្កើនដំណេះដឹង និងបទពិសោធន៍សម្រាប់ការអនុវត្តផែនការយុទ្ធសាស្រ្តទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹកនៅក្នុងខេត្តនាពេលអនាគត។ រូបភាពដែលថតដោយដ្រូនក្នុងពេលចុះបំពេញការងារនៅទីវាល បានជួយសម្រួលដល់ការមើលលម្អិតនៅក្នុងតំបន់នីមួយៗអំពីសំណល់សរីរាង្គស្ងួតដែលងាយឆេះ តំបន់សំខាន់ៗដែលជាប្រភពបង្ក និងរាលដាលនៃភ្លើងឆេះព្រៃ ហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសប្រព័ន្ធផ្លូវទឹក ផ្លូវធ្វើដំណើរដោយថ្មើរជើង និងយានយន្ត សំណើមដី សណ្ឋានដីប្រើប្រាស់ និងគម្របព្រៃលិចទឹក។ រូបភាពនេះនឹងជួយសម្រួលដល់ការកំណត់អត្តសញ្ញាណនៃទីតាំង និងសមាសធាតុដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃលិចទឹក ផ្តល់ឱកាសងាយស្រួលដល់ការរៀបចំផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក និងការចេញចូលក្នុងតំបន់ដើម្បីធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក។

ថ្នាក់ដឹកនាំនៃរដ្ឋបាលជលផល អភិបាលខេត្ត អភិបាលស្រុក ដែលជាក្រុមការងារទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក នឹងចុះធ្វើការត្រួតពិនិត្យ និងវាយតម្លៃទៅតាមការចាំបាច់នៅទីតាំងអនុវត្តផ្ទាល់ ដោយប្រើប្រាស់ក្របខ័ណ្ឌការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ ការត្រួតពិនិត្យ និងវាយតម្លៃនេះ រួមបញ្ចូលការត្រួតពិនិត្យលទ្ធផល និងផលប៉ះពាល់ជាក់ស្តែង និងគណនេយ្យភាពនៅមូលដ្ឋាន។

## ៩. សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ខេត្តបន្ទាយមានជ័យ (២០២២-២០២៦)

| ល.រ | សកម្មភាព | សូចនករ (៥ឆ្នាំ) | អ្នកទទួលខុសត្រូវ | | ថវិកា (២០២២-២០២៦) | ២០២២ (ត្រីមាស) | | | | ២០២៣ (ត្រីមាស) | | | | ២០២៤ (ត្រីមាស) | | | | ២០២៥ (ត្រីមាស) | | | | ២០២៦ (ត្រីមាស) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អ្នកដឹកនាំ | អ្នកគាំទ្រ | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | **លទ្ធផលទី១៖ ការសិក្សាពិនិត្យឡើងវិញនូវការកាត់បន្ថយហានិភ័យ និងភាពត្រៀមខ្លួនរួចជាស្រេចក្នុងការបង្ការ ទប់ស្កាត់ និង ពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលមានប្រសិទ្ធភាព។** | | | | **២១១.៥២០** | | | | | | | | | | | | | | | | | | | | |
| ១.១ | **ការសិក្សាពិនិត្យឡើងវិញពីទម្រង់ បទពិសោធន៍ និងយុទ្ធសាស្ត្រនៃការទប់ស្កាត់ ការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹកឡើងវិញ ដែលបានអនុវត្តកន្លងមក។** | | | | **១២.៦០០** | | | | | | | | | | | | | | | | | | | | |
| ១.១.១ | ប្រជុំជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ឃុំដើម្បីប្រមូលពត៌មានបទពិសោធ និង យុទ្ធសាស្ត្រក្នុងការទប់ស្កាត់ និងការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹកដែលបានអនុវត្តកន្លងមក (១០០$ x ៦ប្រជុំ x ៥ឆ្នាំ ) | ៣០ប្រជុំថ្នាក់ឃុំ ១០របាយការណ៍ថ្នាក់ស្រុក | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៣.០០០ | ៦០០ | | | | ៦០០ | | | | ៦០០ | | | | ៦០០ | | | | ៦០០ | | | |
| | | | | | | ៦ប្រជុំ ២របាយការណ៍ | | | | ៦ប្រជុំ ២របាយការណ៍ | | | | ៦ប្រជុំ ២របាយការណ៍ | | | | ៦ប្រជុំ ២របាយការណ៍ | | | | ៦ប្រជុំ ២របាយការណ៍ | | | |
| | | | | | | H | | | | | | | | | | | | | | | | | | | |
| ១.១.២ | ចុះអង្កេតទីតាំងភ្លើងឆេះព្រៃលិចទឹកដើម្បីប្រមូលនិយាមកា និងព័ត៌មានពីទិដ្ឋភាពភូមិ-រូបសាស្ត្រ-ឋានលេខា ទំហំនៃការខូចខាត ការប្រើប្រាស់ដីគម្របព្រៃ និងគូរផែនទី [(១០០$x៣ថ្ងៃx៦ឃុំ)x (៦០x២ផែនទី)] x ៥ឆ្នាំ | ១០របាយការណ៍ថ្នាក់ស្រុក | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៩.៦០០ | ១.៩២០ | | | | ១.៩២០ | | | | ១.៩២០ | | | | ១.៩២០ | | | | ១.៩២០ | | | |
| | | | | | | ២របាយការណ៍ | | | | ២របាយការណ៍ | | | | ២របាយការណ៍ | | | | ២របាយការណ៍ | | | | ២របាយការណ៍ | | | |
| | | | | | | H | | | H | H | | | H | H | | | H | H | | H | H | | | | H |
| ១.១.៣ | ចូលប្រជុំថ្នាក់ខេត្តធ្វើបទបង្ហាញ និងអនុម័តលើផែនការទប់ស្កាត់ និង គ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក។ | ១ប្រជុំ | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ២០០ | ២០០ | | | | | | | | | | | | | | | | | | | |
| | | | | | | ១ប្រជុំ | | | | | | | | | | | | | | | | | | | |
| | | | | | | | H | | | | | | | | | | | | | | | | | | |
| ១.២ | **<u>ការកាត់បន្ថយហានិភ័យ</u>នៃភ្លើងឆេះព្រៃលិចទឹកតាមរយៈការលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សហគមន៍ មូលដ្ឋានក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **៥៨.២០០** | | | | | | | | | | | | | | | | | | | | |
| ១.២.១ | ផលិតផ្ទាំងរូបភាពផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍ មូលដ្ឋានស្តីពីការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក (១.៥$ x ១០០ សន្លឹក x ៦ឃុំ x ៥ឆ្នាំ) | ៣.០០០សន្លឹក | រដ្ឋបាលជលផល/FAO | អង្គការ FAO | ៤.៥០០ | ៩០០ | | | | ៩០០ | | | | ៩០០ | | | | ៩០០ | | | | ៩០០ | | | |
| | | | | | | ៦០០សន្លឹក | | | | ៦០០សន្លឹក | | | | ៦០០សន្លឹក | | | | ៦០០សន្លឹក | | | | ៦០០សន្លឹក | | | |
| | | | | | | | | | H | H | | | H | H | | | H | H | | | H | H | | | H |
| ១.២.២ | ដំឡើងស្លាកផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន និង អ្នកពាក់ព័ន្ធស្តីពីការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក (៣០០$ x ២ ផ្ទាំង x ៦ឃុំ) | ១២ផ្ទាំង | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣.៦០០ | | | | | ២.១០០ | | | | ១.៥០០ | | | | | | | | | | | |
| | | | | | | | | | | ៧ផ្ទាំង | | | | ៥ផ្ទាំង | | | | | | | | | | | |
| | | | | | | | | | | H | | | | H | | | | | | | | | | | |
| ១.២.៣ | រៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះក្រុមអ្នកពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានជលផលនៅក្នុងតំបន់២ និងតំបន់៣ (១០០$ x ១បញ្ជី x ៦ឃុំ x | ៣០ច្បាប់ | សង្កាត់រដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣.០០០ | ៦០០ | | | | ៦០០ | | | | ៦០០ | | | | ៦០០ | | | | ៦០០ | | | |
| | | | | | | ៦ច្បាប់ | | | | ៦ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | | ៦ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | | ៦ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | | ៦ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | |

| | | | | | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ | ឆ្នាំទី៥ |
|---|---|---|---|---|---|---|---|---|---|---|
| | ៥ឆ្នាំ) | | | | | H | H | H | H | H |
| ១.២.៤ | ផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍ស្តីពីការចូលរួមគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក ច្បាប់ជលផល គោលនយោបាយ អនុក្រឹត្យ លិខិតបទដ្ឋានពាក់ព័ន្ធ (១៥០$x២ប្រជុំx៦ឃុំx៥ឆ្នាំ) | ៦០ដង | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៩.០០០ | ១.៨០០<br>១២ដង<br>H H | ១.៨០០<br>១២ដង<br>H H | ១.៨០០<br>១២ដង<br>H H | ១.៨០០<br>១២ដង<br>H H | ១.៨០០<br>១២ដង<br>H H |
| ១.២.៥ | រៀបចំរចនាសម្ព័ន្ធក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ឃុំ និងផែនការចុះល្បាត (១០០$ x ៦ឃុំ x ១ឆ្នាំ) | ៦ក្រុម | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៦០០ | ៦០០<br>៦ក្រុម<br>H | | | | |
| ១.២.៦ | ចុះល្បាតឃ្លាំមើលភ្លើងឆេះព្រៃលិចទឹក៖ ៥ថ្ងៃ/ខែ (២៥០$ x ៤ខែ x ៦ឃុំ x ៥ឆ្នាំ) | ៦០០ថ្ងៃ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣៧.៥០០ | ៧.៥០០<br>១២០ថ្ងៃ<br>H H | ៧.៥០០<br>១២០ថ្ងៃ<br>H H | ៧.៥០០<br>១២០ថ្ងៃ<br>H H | ៧.៥០០<br>១២០ថ្ងៃ<br>H H | ៧.៥០០<br>១២០ថ្ងៃ<br>H H |
| **១.៣** | **<u>ការត្រៀមខ្លួនជាស្រេច</u>៖ រៀបចំរចនាសម្ព័ន្ធការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុក និងខេត្ត និងសម្ភារសម្រាប់ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **១៤០.៧២០** | | | | | |
| **១.៣.១** | **បង្កើត និងពង្រឹងទំនាក់ទំនងរវាងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុកនិងខេត្ត និងក្រុមល្បាតភ្លើងឆេះព្រៃថ្នាក់ឃុំ ដើម្បីជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក និងបំពាក់ឧបករណ៍ពន្លត់ភ្លើងដល់ក្រុមល្បាត** | | | | **៨៩.២២០** | | | | | |
| ១.៣.១.១ | ប្រជុំជាមួយរដ្ឋបាលខេត្ត និងស្រុកគោលដៅដើម្បីពិភាក្សាអំពីការបង្កើតក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ខេត្ត ស្រុក និងឃុំ (១៥០$ x ២ប្រជុំ x ២ស្រុក) | ១ក្រុមការងារថ្នាក់ខេត្ត និង២ក្រុមការងារថ្នាក់ស្រុក | មន្ទីរក.រ.ន និងរដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៩០០ | ៩០០<br>៦ប្រជុំ<br>H | | | | |
| ១.៣.១.២ | រៀបចំប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃថ្នាក់ខេត្តដើម្បីពិភាក្សាអំពីបញ្ហាប្រឈមក្នុងបទអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃ និងស្វែងរកដំណោះស្រាយបញ្ហា (១៧០០$ x ១ប្រជុំ x ៥ឆ្នាំ) | ៥ប្រជុំ<br>៥របាយការណ៍ | ខណ្ឌរដ្ឋបាលជលផល | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក | ៨.៥០០ | ១.៧០០<br>១ប្រជុំ<br>១របាយការណ៍<br>H H | ១.៧០០<br>១ប្រជុំ<br>១របាយការណ៍<br>H H | ១.៧០០<br>១ប្រជុំ<br>១របាយការណ៍<br>H H | ១.៧០០<br>១ប្រជុំ<br>១របាយការណ៍<br>H H | ១.៧០០<br>១ប្រជុំ<br>១របាយការណ៍<br>H H |
| ១.៣.១.៣ | រៀបចំប្រជុំក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុកប្រចាំត្រីមាសដើម្បីពិភាក្សាអំពីបញ្ហាប្រឈមក្នុងបទអន្តរាគមន៍ពន្លត់ ភ្លើងឆេះព្រៃលិចទឹក ស្វែងដំណោះស្រាយបញ្ហា និងលើកផែនការគាំទ្រការល្បាតនៅថ្នាក់ឃុំ (៤២០$ x ២ប្រជុំ x ២ស្រុក x ៥ឆ្នាំ) | ២០ប្រជុំ | ខណ្ឌរដ្ឋបាលជលផល | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក | ៨.៤០០ | ១.៦៨០<br>៤ប្រជុំ<br>H H | ១.៦៨០<br>៤ប្រជុំ<br>H H | ១.៦៨០<br>៤ប្រជុំ<br>H H | ១.៦៨០<br>៤ប្រជុំ<br>H H | ១.៦៨០<br>៤ប្រជុំ<br>H H |
| ១.៣.១.៤ | ទិញគោយន្តកន្ត្រៃបំពាក់ដោយម៉ាស៊ីនបូមទឹក២ ស៊ីទែនទឹកចំណុះ១០០០ L ទុយោ២ដុំ និងកាំភ្លើងបាញ់ទឹក២ដើម សម្រាប់ក្រុមល្បាត (៣.៨០០$ x ៥គ្រឿង) | ៥គ្រឿង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ១៩.០០០ | | ១១.៤០០<br>៣គ្រឿង<br>H | ៧.៦០០<br>២គ្រឿង<br>H | | |
| ១.៣. | ទិញម៉ូតូធំសម្រាប់ក្រុមល្បាត (៣.២០០$ x ៧គ្រឿង) | ៧គ្រឿង | រដ្ឋបាល | ខណ្ឌរដ្ឋបាល | ២២.៤០០ | | ៩.៦០០ | ៦.៤០០ | ៦.៤០០ | |

| | | | | | | ឆ្នាំ១ | ឆ្នាំ២ | ឆ្នាំ៣ | ឆ្នាំ៤ | ឆ្នាំ៥ |
|---|---|---|---|---|---|---|---|---|---|---|
| ១.៥ | | | ជលផល | ជលផល | | | ៣គ្រឿង<br>H | ២គ្រឿង<br>H | ២គ្រឿង<br>H | |
| ១.៣.១.៦ | ទិញម៉ូតូហុងដាឌ្រីមសម្រាប់ក្រុមល្បាត (២.៥០០$ x ៣គ្រឿង) | ៣គ្រឿង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៧.៥០០ | | ៤.៦០០<br>២គ្រឿង<br>H | ២.៣០០<br>១គ្រឿង<br>H | | |
| ១.៣.១.៧ | ទិញឧបករណ៍ពន្លត់អគ្គិភ័យ (ប្រអប់សង្គ្រោះបឋម តង់ កាបូបស្ពាយ ធុងទឹកស្ពាយ វ៉ែនតា ស្បែកជើង ដ្រូន កែវយឺត ឯកសណ្ឋាន GPS..) សម្រាប់ក្រុមល្បាត (១.២០០$ x ២ឈុត x ៦ឃុំ) | ១២ឈុត | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ១៤.៤០០ | | ៧.២០០<br>៦ឈុត<br>H | | ៧.២០០<br>៦ឈុត<br>H | |
| ១.៣.១.៨ | ប្រជុំក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកថ្នាក់ឃុំដើម្បីផ្តល់ការណែនាំអំពីរបៀបប្រើប្រាស់ និងលក្ខន្តិកៈនៃការប្រើប្រាស់ឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក (១០០$ x ២ប្រជុំ x ៦ឃុំ) | ១២ប្រជុំ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរឃុំ | ១.២០០ | | ៦០០<br>៦ប្រជុំ<br>H | | ៦០០<br>៦ប្រជុំ<br>H | |
| ១.៣.១.៩ | ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ខេត្តស្តីពីបច្ចេកទេសល្បាតភ្លើងឆេះព្រៃលិចទឹកសម្រាប់មន្ត្រីខណ្ឌរដ្ឋបាលជលផល និងក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក (៤៥$ x ៤ថ្ងៃ □ ២នាក់ □ ២ស្រុក □ ២វគ្គ) | ២វគ្គ | រដ្ឋបាលជលផល | អង្គការ WCS | ១.៤៤០ | | ៧២០<br>១វគ្គ<br>H | H | ៧២០<br>១វគ្គ<br>H | |
| ១.៣.១.១០ | រៀបចំវគ្គបណ្តុះបណ្តាលថ្នាក់ស្រុកស្តីពីបច្ចេកទេសល្បាតភ្លើងឆេះព្រៃលិចទឹកសម្រាប់ក្រុមល្បាតភ្លើងឆេះព្រៃលិចទឹក □(២០$ □២៥នាក់ □ ២ថ្ងៃ) + (៤៥$□២គ្រូបង្គោល□៣ថ្ងៃ)+(១០០$ សម្ភារបណ្តុះបណ្តាល)] □ ២ស្រុក □ ២វគ្គ | ៤វគ្គ | ខណ្ឌរដ្ឋបាលជលផល | ក្រុមការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក | ៥.៤៨០ | | ២.៧៤០<br>២វគ្គ<br>H | | ២.៧៤០<br>២វគ្គ<br>H | |
| **១.៣.២** | **សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសម្រាប់ប្រើប្រាស់ក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក** | | | | **៥១.៥០០** | | | | | |
| ១.៣.២.១ | សាងសង់ប៉មយាមសម្រាប់ក្រុមល្បាតឃ្លាំមើលភ្លើងឆេះព្រៃលិចទឹក (៨០០០$ x ២ប៉ម) | ២កន្លែង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ១៦.០០០ | | ១៦.០០០<br>២កន្លែង<br>H H | | | |
| ១.៣.២.២ | ស្តារបឹងធម្មជាតិដើម្បីរក្សាទឹកទុកសម្រាប់ពន្លត់ភ្លើងឆេះព្រៃលិចទឹក និងអភិរក្សត្រីធម្មជាតិ (៥.៥០០$ □ ៣ទីតាំង) | ៣ទីតាំង | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ១៦.៥០០ | | ១១.០០០<br>២កន្លែង<br>H H | ៥.៥០០<br>១កន្លែង<br>H H | | |
| ១.៣.២.៣ | រៀបចំ និងថែរក្សាផ្លូវភ្លើងទប់ស្កាត់ការរាលដាលភ្លើងឆេះព្រៃលិចទឹក (១.៦០០$ x ១០គ.ម) | ១០គ.ម | ខណ្ឌរដ្ឋបាលជលផល | សហគមន៍នេសាទ | ១៦.០០០ | | ៥.០០០<br>ថ្មី៥គ.ម<br>H H | ៥.០០០<br>ថ្មី៥គ.ម<br>H H | ៣.០០០<br>ថែទាំ១០គ.ម<br>H H | ៣.០០០<br>ថែទាំ១០គ.ម<br>H H |
| ១.៣. | ដំឡើងអង់តែនវិទ្យុទាក់ទងដើម្បីបង្កភាពងាយស្រួលដល់ក្រុមល្បាតក្នុង | ១អង់តែន | រដ្ឋបាល | ខណ្ឌរដ្ឋបាលជល | ៣.០០០ | | ៣.០០០ | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២.៤ | ការទាក់ទងគ្នា (៣.០០០$ x ១អង់តែន) | | ជលផល | ផល | | | ១អង់តែន<br>H H | | | |
| **២** | **លទ្ធផលទី២៖ ភាពប្រសើរឡើងនូវការជួយធ្វើអន្តរាគមន៍ពន្លត់ភ្លើងឆេះព្រៃលិចទឹក** | | | | **៥៦.៨២០** | | | | | |
| ២.១ | តាមដានរបាយការណ៍ប្រចាំថ្ងៃ និងត្រៀមចាំជួយពន្លត់ភ្លើងឆេះព្រៃលិចទឹកជាបន្ទាន់តាមសំណូមពររបស់ក្រុមល្បាត (៥០០$ x ៤៥ករណី) | ៤៥ករណី | សង្កាត់រដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ២២.៥០០ | ៦.៥០០<br>១៣ករណី<br>H H | ៥.៥០០<br>១១ករណី<br>H H | ៤.៥០០<br>៩ករណី<br>H H | ៣.៥០០<br>៧ករណី<br>H H | ២.៥០០<br>៥ករណី<br>H H |
| ២.២ | ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការប្រមូលភស្តុតាង និងការរៀបចំសំណុំរឿងបទល្មើសភ្លើងឆេះព្រៃលិច (៤៥$x៤នាក់x៤ថ្ងៃ) | ១ វគ្គ | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៧២០ | ៧២០<br>១វគ្គ<br>H | | | | |
| ២.៣ | ពង្រឹងការអនុវត្តច្បាប់បង្ក្រាបបទល្មើសដុត និងទន្ទ្រានដីព្រៃលិចទឹកខុសច្បាប់ (១៥០$ x ៦០ករណី) | ៦០ករណី | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៩.០០០ | ២.៧០០<br>១៨ករណី<br>H H | ២.២៥០<br>១៥ករណី<br>H H | ១.៨០០<br>១២ករណី<br>H H | ១.៣៥០<br>៩ករណី<br>H H | ៩០០<br>៦ករណី<br>H H |
| ២.៤ | ថវិកាសម្រាប់ថែរក្សា និងទិញបន្ថែមឧបករណ៍ពន្លត់ភ្លើងឆេះព្រៃលិចទឹកតាមតម្រូវការចាំបាច់ (១០០$ x ៥ខែ x ៦ឃុំ x ៥ឆ្នាំ) | កញ្ចប់រួម | សង្កាត់រដ្ឋបាលជលផល | អាជ្ញាធរឃុំ | ១៥.០០០ | ៣.០០០<br>កញ្ចប់រួម<br>H H | ៣.០០០<br>កញ្ចប់រួម<br>H H | ៣.០០០<br>កញ្ចប់រួម<br>H H | ៣.០០០<br>កញ្ចប់រួម<br>H H | ៣.០០០<br>កញ្ចប់រួម<br>H H |
| ២.៥ | ចូលរួមសិក្ខាសាលាថ្នាក់ខេត្តដើម្បីផ្លាស់ប្តូរចំណេះដឹង និងបទពិសោធស្តីពីបច្ចេកទេសទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក និងស្តារព្រៃលិចទឹកឡើងវិញ (៥.៦០០$) | ១សិក្ខាសាលា | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៥.៦០០ | | | | ៥.៦០០<br>១វគ្គ<br>H | |
| ២.៦ | ផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកដែលបានចូលរួមសកម្ម ឬមានរបួសនៅក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក ( ១០០$x៤០នាក់ ) | ៤០នាក់ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៤.០០០ | ១.២០០<br>១២នាក់<br>H H | ១.០០០<br>១០នាក់<br>H H | ៨០០<br>៨នាក់<br>H H | ៧០០<br>៧នាក់<br>H H | ៥០០<br>៥នាក់<br>H H |
| **៣** | **លទ្ធផលទី៣៖ ព្រៃលិចទឹកដែលបានទទួលរងការខូចខាតដោយភ្លើងឆេះត្រូវបានស្តារឡើងវិញ** | | | | **២០៥.៩១០** | | | | | |
| ៣.១ | ចូលរួមក្នុងការវាយតម្លៃដោយឆាប់រហ័សដើម្បីកំណត់វិធីសាស្ត្រស្តារព្រៃលិចទឹកដែលបានឆេះ និងគូរផែនទី (១០០$ x ៣ថ្ងៃ x ២ស្រុក x ៥ឆ្នាំ) | ១០របាយការណ៍ថ្នាក់ស្រុក | រដ្ឋបាលជលផល និងFAO | ខណ្ឌរដ្ឋបាលជលផល | ៣.៦០០ | ៧២០<br>២របាយការណ៍<br>H | ៧២០<br>២របាយការណ៍<br>H | ៧២០<br>២របាយការណ៍<br>H | ៧២០<br>២របាយការណ៍<br>H | ៧២០<br>២របាយការណ៍<br>H |
| ៣.២ | បោះបង្គោលស៊ីម៉ង់ត៍ និងដាក់ស្លាកសញ្ញានៅតាមព្រំប្រទល់តំបន់ភ្លើងឆេះព្រៃលិចទឹក (៦០$ □ ៦០០បង្គោល ) | ៦០០បង្គោល | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣៦.០០០ | ១០.៨០០<br>១៨០បង្គោល<br>H H | ៩.០០០<br>១៥០បង្គោល<br>H H | ៧.២០០<br>១២០បង្គោល<br>H H | ៥.៤០០<br>៩០បង្គោល<br>H H | ៣.៦០០<br>៦០បង្គោល<br>H H |
| ៣.៣ | ចូលរួមសិក្ខាសាលាថ្នាក់ខេត្តស្តីពីបច្ចេកទេសគ្រប់គ្រងថ្នាលបណ្តុះកូនឈើព្រៃលិចទឹក និងវិធីសាស្ត្រស្តារព្រៃលិចទឹក(១៧០០$ □ ២វគ្គ) | ២វគ្គ | រដ្ឋបាលជលផល និងFAO | ខណ្ឌរដ្ឋបាលជលផល | ៣.៤០០ | | ១.៧០០<br>១វគ្គ<br>H | | ១.៧០០<br>១វគ្គ<br>H | |
| ៣.៤ | ប្រជុំពិគ្រោះយោបល់នៅថ្នាក់ឃុំជាមួយអ្នកពាក់ព័ន្ធពិភាក្សាអំពីការ ស្តារព្រៃលិចទឹកដែលខូចខាតដោយភ្លើងឆេះ (១៥០$ x ៦ប្រជុំ x ៥ឆ្នាំ) | ៣០ប្រជុំ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៤.៥០០ | ៩០០<br>៦ប្រជុំ<br>H | ៩០០<br>៦ប្រជុំ<br>H | ៩០០<br>៦ប្រជុំ<br>H | ៩០០<br>៦ប្រជុំ<br>H | ៩០០<br>៦ប្រជុំ<br>H |

<table>
<tr><td rowspan="3">៣.៥</td><td rowspan="3">គាំទ្រសហគមន៍ក្នុងការរៀបចំថ្នាល និងបណ្តុះកូនឈើព្រៃលិចទឹក សម្រាប់ការស្តារព្រៃលិចទឹកដែលបានឆេះ (៨០០$ x ៣ថ្នាល x ៥ឆ្នាំ)</td><td rowspan="3">១០ថ្នាល</td><td rowspan="3">សង្កាត់រដ្ឋបាលជលផល</td><td rowspan="3">សហគមន៍នេសាទ</td><td rowspan="3">៨.០០០</td><td colspan="4">១.៦០០</td><td colspan="4">១.៦០០</td><td colspan="4">១.៦០០</td><td colspan="4">១.៦០០</td><td colspan="4">១.៦០០</td></tr>
<tr><td colspan="4">២ថ្នាល</td><td colspan="4">២ថ្នាល</td><td colspan="4">២ថ្នាល</td><td colspan="4">២ថ្នាល</td><td colspan="4">២ថ្នាល</td></tr>
<tr><td>H</td><td>H</td><td></td><td>H</td><td>H</td><td>H</td><td></td><td>H</td><td>H</td><td>H</td><td></td><td>H</td><td>H</td><td>H</td><td></td><td>H</td><td>H</td><td>H</td><td></td><td>H</td></tr>
<tr><td rowspan="3">៣.៦</td><td rowspan="3">គាំទ្រ និងត្រួតពិនិត្យការដាំកូនឈើព្រៃលិចទឹកដោយសហគមន៍មូលដ្ឋាន នៅក្នុងតំបន់ស្តារព្រៃលិចទឹក (៥.៨៥០$)</td><td rowspan="3">១៣០ហិកតា</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">អាជ្ញាធរមូលដ្ឋាន</td><td rowspan="3">៥.៨៥០</td><td colspan="4">១.១៧០</td><td colspan="4">១.១៧០</td><td colspan="4">១.១៧០</td><td colspan="4">១.១៧០</td><td colspan="4">១.១៧០</td></tr>
<tr><td colspan="4">២៦ហិកតា</td><td colspan="4">២៦ហិកតា</td><td colspan="4">២៦ហិកតា</td><td colspan="4">២៦ហិកតា</td><td colspan="4">២៦ហិកតា</td></tr>
<tr><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td></tr>
<tr><td rowspan="3">៣.៧</td><td rowspan="3">ចំណាយដាំកូនឈើព្រៃលិចទឹកគិតទាំងតម្លៃកូនឈើ ការដឹកជញ្ជូន និងការដាំ (១$ x ១.០០០ដើម x ១៣០ហិកតា)</td><td rowspan="3">១៣០ហិកតា<br>១៣០.០០០ដើម</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">សហគមន៍នេសាទ</td><td rowspan="3">១៣០.០០០</td><td colspan="4">២៦.០០០</td><td colspan="4">២៦.០០០</td><td colspan="4">២៦.០០០</td><td colspan="4">២៦.០០០</td><td colspan="4">២៦.០០០</td></tr>
<tr><td colspan="4">២៦.០០០ដើម</td><td colspan="4">២៦.០០០ដើម</td><td colspan="4">២៦.០០០ដើម</td><td colspan="4">២៦.០០០ដើម</td><td colspan="4">២៦.០០០ដើម</td></tr>
<tr><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td></tr>
<tr><td rowspan="3">៣.៨</td><td rowspan="3">ចំណាយថែទាំកូនឈើដែលបានដាំនៅក្នុងតំបន់ស្តារព្រៃលិចទឹកដោយសហគមន៍ (១០០$ x ៣១២ហិកតា)។</td><td rowspan="3">១៣០ ហិកតា</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">សហគមន៍នេសាទ</td><td rowspan="3">១២.៤៨០</td><td colspan="4">១.០៤០</td><td colspan="4">២.០៨០</td><td colspan="4">៣.១២០</td><td colspan="4">៣.១២០</td><td colspan="4">៣.១២០</td></tr>
<tr><td colspan="4">២៦ហិកតា</td><td colspan="4">៥២ហិកតា</td><td colspan="4">៧៨ហិកតា</td><td colspan="4">៧៨ហិកតា</td><td colspan="4">៧៨ហិកតា</td></tr>
<tr><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td></tr>
<tr><td rowspan="3">៣.៩</td><td rowspan="3">វាយតម្លៃអត្រារស់ និងលូតលាស់នៃកូនឈើព្រៃលិចទឹកនៅក្នុងតំបន់ស្តារព្រៃលិចទឹក (២.០៨០$/១០៤ហិកតា)</td><td rowspan="3">១០៤ហិកតា</td><td rowspan="3">រដ្ឋបាលជលផល និងFAO</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">២.០៨០</td><td colspan="4"></td><td colspan="4"></td><td colspan="4">៥២០</td><td colspan="4">៥២០</td><td colspan="4">១.០៤០</td></tr>
<tr><td colspan="4"></td><td colspan="4"></td><td colspan="4">២៦ហិកតា</td><td colspan="4">២៦ហិកតា</td><td colspan="4">៥២ហិកតា</td></tr>
<tr><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td></tr>
<tr><td>**៤**</td><td colspan="4">**ការចុះគាំទ្រ តាមដាន និងវាយតម្លៃការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក**</td><td>**៦.១០០**</td><td colspan="20"></td></tr>
<tr><td rowspan="3">៤.១</td><td rowspan="3">ចូលរួមនៅក្នុងការប្រមូលទិន្ន័យដើម (baseline survey) ដែលអនុវត្តដោយមន្ត្រីបច្ចេកទេសរដ្ឋបាលជលផល និងមន្ត្រីគំរោងFAO-CAPFISH (សរុប ១.២០០$)</td><td rowspan="3">១ដង</td><td rowspan="3">រដ្ឋបាលជលផល/FAO</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">៧០០</td><td colspan="4">១,២០០</td><td colspan="4"></td><td colspan="4"></td><td colspan="4"></td><td colspan="4"></td></tr>
<tr><td colspan="4">១ដង</td><td colspan="4"></td><td colspan="4"></td><td colspan="4"></td><td colspan="4"></td></tr>
<tr><td></td><td></td><td>H</td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td><td></td></tr>
<tr><td rowspan="3">៤.២</td><td rowspan="3">ចូលរួមក្នុងបេសកកម្មគាំទ្រប្រចាំខែរបស់មន្ត្រីបច្ចេកទេសរដ្ឋបាល ជលផលដើម្បីជួយតម្រង់ទិសការអនុវត្តផែនការគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹក (៤៥$ x ២នាក់ x ១លើក x ៦ខែ x ២ស្រុក x ៥ឆ្នាំ)</td><td rowspan="3">៦០ដង</td><td rowspan="3">រដ្ឋបាលជលផល</td><td rowspan="3">ខណ្ឌរដ្ឋបាលជលផល</td><td rowspan="3">៥.៤០០</td><td colspan="4">១.០៨០</td><td colspan="4">១.០៨០</td><td colspan="4">១.០៨០</td><td colspan="4">១.០៨០</td><td colspan="4">១.០៨០</td></tr>
<tr><td colspan="4">១០ដង</td><td colspan="4">១០ដង</td><td colspan="4">១០ដង</td><td colspan="4">១០ដង</td><td colspan="4">១០ដង</td></tr>
<tr><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td><td>H</td><td>H</td><td></td><td></td></tr>
<tr><td colspan="5">សរុប:</td><td>៤៨០.៣៥០</td><td colspan="20"></td></tr>
</table>

## ១០. សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកថ្នាក់ស្រុក ឆ្នាំ២០២២-២០២៦

### ១០.១ សកម្មភាព និងថវិកាផែនការទប់ស្កាត់ និងគ្រប់គ្រងភ្លើងឆេះព្រៃ ស្រុកព្រះនេត្រព្រះ ឆ្នាំ២០២២-២០២៦

| ល.រ | សកម្មភាព | សូចនករ (៥ឆ្នាំ) | អ្នកទទួលខុសត្រូវ | | ថវិកា (២០២២-២០២៦) | ២០២២ (ត្រីមាស) | | | | ២០២៣ (ត្រីមាស) | | | | ២០២៤ (ត្រីមាស) | | | | ២០២៥ (ត្រីមាស) | | | | ២០២៦ (ត្រីមាស) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អ្នកដឹកនាំ | អ្នកគាំទ្រ | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១ | **លទ្ធផលទី១៖ ការសិក្សាពិនិត្យឡើងវិញនូវការកាត់បន្ថយហានិភ័យ និងភាពត្រៀមខ្លួនរួចជាស្រេចក្នុងការបង្ការ ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹកដែលមានប្រសិទ្ធភាព។** | | | | **១៣៧.១៧៧** | | | | | | | | | | | | | | | | | | | | |
| ១.១ | **ការសិក្សាពិនិត្យឡើងវិញពីទម្រង់ បទពិសោធន៍ និងយុទ្ធសាស្ត្រនៃការទប់ស្កាត់ ការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹកឡើងវិញ ដែលបានអនុវត្តកន្លងមក។** | | | | **១០.៥០០** | | | | | | | | | | | | | | | | | | | | |
| ១.១.១ | ប្រជុំជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ឃុំដើម្បីប្រមូលពត៌មានបទពិសោធ និងយុទ្ធសាស្រ្តក្នុងការទប់ស្កាត់ និងការពន្លត់ភ្លើងឆេះព្រៃលិចទឹក និងការស្តារព្រៃលិចទឹកដែលបានអនុវត្តកន្លងមក (១០០$ x ៥ប្រជុំ x ៥ឆ្នាំ) | ២៥ប្រជុំថ្នាក់ឃុំ ៥របាយការណ៍ថ្នាក់ស្រុក | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ២.៥០០ | ៥០០ | | | | ៥០០ | | | | ៥០០ | | | | ៥០០ | | | | ៥០០ | | | |
| | | | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | | ៥ប្រជុំ ១របាយការណ៍ | | | |
| | | | | | | H | | | M | M | | | M | M | | | M | M | | | M | M | | | M |
| ១.១.២ | ចុះអង្កេតទីតាំងភ្លើងឆេះព្រៃលិចទឹកដើម្បីប្រមូលនិយាមកា និងព័ត៌មានពីទិដ្ឋភាពភូមិ-រូបសាស្រ្ត-ឋានលេខា ទំហំនៃការខូចខាត ការប្រើប្រាស់ដី និងគម្របព្រៃលិចទឹក [(១០០$x៣ថ្ងៃx៥ឃុំ)+(៦០$ x ១ផែនទី)] x ៥ឆ្នាំ | ៥របាយការណ៍ថ្នាក់ស្រុក | រដ្ឋបាលជលផល | ខណ្ឌរដ្ឋបាលជលផល | ៨.០០០ | ១.៦០០ | | | | ១.៦០០ | | | | ១.៦០០ | | | | ១.៦០០ | | | | ១.៦០០ | | | |
| | | | | | | ១របាយការណ៍ | | | | ១របាយការណ៍ | | | | ១របាយការណ៍ | | | | ១របាយការណ៍ | | | | ១របាយការណ៍ | | | |
| | | | | | | H | | | H | H | | | H | H | | | H | H | | H | H | | | | H |
| ១.២ | **<u>ការកាត់បន្ថយហានិភ័យ</u>នៃភ្លើងឆេះព្រៃលិចទឹកដោយការលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **៤៨.៥០០** | | | | | | | | | | | | | | | | | | | | |
| ១.២.១ | ផលិតផ្ទាំងរូបភាពផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធស្តីពីការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក (១.៥$ x ១០០សន្លឹក x ៥ឃុំ x ៥ឆ្នាំ) | ២.៥០០សន្លឹក | រដ្ឋបាលជលផល | អង្គការ FAO | ៣.៧៥០ | ៧៥០ | | | | ៧៥០ | | | | ៧៥០ | | | | ៧៥០ | | | | ៧៥០ | | | |
| | | | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | | ៥០០សន្លឹក | | | |
| | | | | | | | | | H | H | | | H | H | | | H | H | | | H | H | | | H |
| ១.២.២ | ដំឡើងស្លាកផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងរបស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធស្តីពីការទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹក (៣០០$ x ២ស្លាក x ៥ឃុំ) | ១០ស្លាក | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣.០០០ | | | | | ១.៥០០ | | | | ១.៥០០ | | | | | | | | | | | |
| | | | | | | | | | | ៥ស្លាក | | | | ៥ស្លាក | | | | | | | | | | | |
| | | | | | | | | | | H | | | | H | | | | | | | | | | | |
| ១.២.៣ | រៀបចំ និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះក្រុមអ្នកពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានជលផលនៅក្នុងតំបន់២ និងតំបន់៣ (១០០$ x ១បញ្ជី x ៥ឃុំ x ៥ឆ្នាំ) | ៥ច្បាប់ | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ២.៥០០ | ៥០០ | | | | ៥០០ | | | | ៥០០ | | | | ៥០០ | | | | ៥០០ | | | |
| | | | | | | ៥ច្បាប់ | | | | ៥ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | | ៥ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | | ៥ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | | ៥ច្បាប់ ធ្វើបច្ចុប្បន្នភាព | | | |
| | | | | | | | | | H | | | | H | | | | H | | | | H | | | | H |
| ១.២. | ផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍ស្តីពីការចូលរួមគ្រប់គ្រង | ៥០ប្រជុំ | ខណ្ឌរដ្ឋបាល | អាជ្ញាធរមូលដ្ឋាន | ៧.៥០០ | ១.៥០០ | | | | ១.៥០០ | | | | ១.៥០០ | | | | ១.៥០០ | | | | ១.៥០០ | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤ | ភ្លើងឆេះព្រៃលិចទឹក ច្បាប់ជលផល អនុក្រឹត្យ គោលនយោបាយ និងលិខិតបទដ្ឋានពាក់ព័ន្ធ (១៥០$x ២ប្រជុំx ៥ឃុំx ៥ឆ្នាំ) | | ជលផល | | | ១០ប្រជុំ<br>H H | ១០ប្រជុំ<br>H H | ១០ប្រជុំ<br>H H | ១០ប្រជុំ<br>H H | ១០ប្រជុំ<br>H H |
| ១.២.៥ | រៀបចំរចនាសម្ព័ន្ធក្រុមល្បាតភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ឃុំ និងផែនការចុះល្បាត (១០០$ x ៥ឃុំ x ១ឆ្នាំ) | ៥ក្រុម | ខណ្ឌរដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៥០០ | ៥០០<br>៥ក្រុម<br>H H | | | | |
| ១.២.៦ | ចុះល្បាតឃ្លាំមើលភ្លើងឆេះព្រៃលិចទឹក៖ ៤ថ្ងៃ/ខែ (២៥០$ x ៥ខែ x ៥ឃុំ x ៥ឆ្នាំ) | ៥០០ថ្ងៃ | ក្រុមល្បាត និងសង្កាត់រដ្ឋបាលជលផល | អាជ្ញាធរមូលដ្ឋាន | ៣១.២៥០ | ៦.២៥០<br>១០០ថ្ងៃ<br>H H | ៦.២៥០<br>១០០ថ្ងៃ<br>H H | ៦.២៥០<br>១០០ថ្ងៃ<br>H H | ៦.២៥០<br>១០០ថ្ងៃ<br>H H | ៦.២៥០<br>១០០ថ្ងៃ<br>H H |
| **១.៣** | **<u>ការត្រៀមខ្លួនជាស្រេច</u>៖ រៀបចំរចនាសម្ព័ន្ធការងារគ្រប់គ្រងភ្លើងឆេះព្រៃលិចទឹកនៅថ្នាក់ស្រុក និងខេត្ត និងសម្ភារសម្រាប់ ទប់ស្កាត់ និងពន្លត់ភ្លើងឆេះព្រៃលិចទឹក។** | | | | **៧៨.១៧៧** | | | | | |
